ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

# ការទប់ស្កាត់ការជួញដូរមនុស្ស



## បំណិនជីវិតសម្រាប់មធ្យមសិក្សាបឋមភូមិ
## គម្រោងកែលម្អអប់រំកម្រិតមូលដ្ឋាននៅកម្ពុជា

USAID
ជំនួយពីពលរដ្ឋអាមេរិក

អង្គការអប់រំពិភពលោក
WORLD EDUCATION

ឧបត្ថម្ភដោយ ទីភ្នាក់ងារសហរដ្ឋអាមេរិកដើម្បីអភិវឌ្ឍអន្តរជាតិ
រៀបចំដោយ អង្គការអប់រំពិភពលោក សហការជាមួយអង្គការសកម្មភាពសម្រាប់បឋមសិក្សានៅកម្ពុជា

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា
លេខ : ៩៥៥ អយក.ប្រក

# ប្រកាស
## ស្តីពី
## ការអនុញ្ញាតឱ្យបោះពុម្ពផ្សាយ
## សៀវភៅ " ការទប់ស្កាត់ការជួញដូរមនុស្ស "
## រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
-បានឃើញអនុក្រឹត្យលេខ ៨៤អនក្រ.បក ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០០៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
-យោងសេចក្តីណែនាំលេខ ០៣ អយក.សណន.ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០១៣ របស់ក្រសួងអប់រំ យុវជន និងកីឡា ស្តីពីប្រព័ន្ធអនុម័តសៀវភៅសិក្សា និងសម្ភារឧបទេស
-យោងសំណើរបស់អង្គការអប់រំពិភពលោក ចុះថ្ងៃទី០២ ខែតុលា ឆ្នាំ២០១២
-យោងកំណត់ហេតុប្រជុំរបស់លេខាធិការដ្ឋានក្រុមប្រឹក្សាអនុម័តសៀវភៅ និងសម្ភារឧបទេសនាថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០១៤
-តាមសំណើរបស់ប្រធានក្រុមប្រឹក្សាអនុម័តសៀវភៅសិក្សា និងសម្ភារឧបទេស

## សម្រេច

ប្រការ ១ - អនុញ្ញាតឱ្យបោះពុម្ពផ្សាយសៀវភៅ " ការទប់ស្កាត់ការជួញដូរមនុស្ស " ដែលជាស្នាដៃនិពន្ធ និងរៀបរៀងរបស់អង្គការអប់រំពិភពលោក សហការជាមួយក្រសួងអប់រំ យុវជន និងកីឡា ដើម្បីប្រើប្រាស់ជាឯកសារជំនួយក្នុងការបង្រៀននិងរៀនកម្មវិធីបំណិនជីវិត នៅតាមសាលារៀនមធ្យមសិក្សាបឋមភូមិ ។

ប្រការ ២ - អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកដ្ឋានអប់រំ នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា នាយកដ្ឋានមធ្យមសិក្សា ចំណេះទូទៅ និងអង្គការអប់រំពិភពលោក មានភារកិច្ចអនុវត្តប្រកាសនេះ។

រាជធានីភ្នំពេញ,ថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ២០១៤

បណ្ឌិត ហង់ ជួន ណារ៉ុន

កន្លែងទទួល:
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
  " ដើម្បីជូនជ្រាបជាព័ត៌មាន "
- ដូចប្រការ២
- កាលប្បវត្តិ
- ឯកសារនា. អកស.

អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣)៤២៧ ៣៩៦/២១៧ ២៥៣/៤២៦ ៩៥១ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០/២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / crsmeys@camnet.com.kh គេហទំព័រ: www.moeys.gov.kh

## គណៈកម្មការអភិវឌ្ឍសៀវភៅ
## "ការទប់ស្កាត់ការជួញដូរមនុស្ស"

**គណៈកម្មការនិពន្ធ និងរៀបរៀង**

១. លោក អេង  សុខ
២. លោកស្រី ស៊ូសាន ហ្វលីហ្វ៊ែរ
៣. លោក វីលៀម"វាន់ឌឺវ៉ាល់

**គណៈកម្មការកែសម្រួល**

១. លោក ឈុំ វណ្ណាឆន
២. លោក ប៊ុត សុភាន់
៣. លោក ផុក ចាន់ថុល

ឧបត្ថម្ភថវិកាដោយ ទីភ្នាក់ងារសហរដ្ឋអាមេរិកដើម្បីអភិវឌ្ឍអន្តរជាតិ( USAID )

សហការរៀបចំដោយ
អង្គការអប់រំពិភពលោក និង ក្រសួងអប់រំ យុវជន និងកីឡា

# មាតិកា


អារម្ភកថា.................................................................................................... ក

វត្ថុបំណងរួម.................................................................................................... ខ

ការត្រៀមលក្ខណៈមុនពេលបង្រៀន.................................................................... ខ

ខ្លឹមសារសង្ខេប.................................................................................................. គ

មេរៀនទី ១: ការជួញដូរមនុស្ស................................................................ ១

មេរៀនទី ២: ការជួញដូរមនុស្ស (ត)........................................................ ៥

មេរៀនទី ៣: តើអ្នកមកពីណា?................................................................ ១៤

មេរៀនទី ៤: សុវត្ថិភាព និងគ្មានសុវត្ថិភាព............................................. ២០

មេរៀនទី ៥: ផ្ទាំងរូបភាព........................................................................ ២៤

មេរៀនទី ៦: ទីក្រុងធំ........................................................................... ២៩

មេរៀនទី ៧: ផ្សព្វផ្សាយព័ត៌មាន.............................................................. ៣៦

មេរៀនទី ៨: ការមកដល់ទីក្រុង................................................................ ៣៨

មេរៀនទី ៩: ច្បាប់ស្តីពីការបង្ក្រាបអំពើពង្រាត់ និងជួញដូរមនុស្ស
និងអំពើធ្វើអាជីវកម្មលើមនុស្ស................................................... ៤៦

មេរៀនទី ១០: ការវាយតម្លៃចំណេះដឹង...................................................... ៥៣

# អារម្ភកថា

វិស័យអប់រំជាគន្លឹះមួយ រួមចំណែកយ៉ាងសំខាន់ក្នុងការអភិវឌ្ឍសង្គម និងសេដ្ឋកិច្ច ពិសេសការអភិវឌ្ឍធនធានមនុស្ស។ ដោយសង្គមជាតិយើងមានការអភិវឌ្ឍលើគ្រប់វិស័យ ការអប់រំក៏ត្រូវបានយកចិត្តទុកដាក់យ៉ាងខ្លាំង ដើម្បីបណ្តុះបណ្តាលធនធានមនុស្ស ប្រកបដោយគុណភាពនិងមានជំនាញខ្ពស់ ដើម្បីបំពេញលើគ្រប់លក្ខខណ្ឌការងារ។

ដើម្បីឆ្លើយតបនឹងតម្រូវការរីកចម្រើននៃទីផ្សារសេរីរបស់សង្គមជាតិ ក្រសួងអប់រំ យុវជននិងកីឡាបានបង្កើតគោលនយោបាយសម្រាប់អភិវឌ្ឍន៍កម្មវិធីចំណេះទូទៅ និងគោលនយោបាយអប់រំបំណិនជីវិត សម្រាប់អនុវត្តន៍នៅតាមសាលារៀនចំណេះទូទៅ។

កម្មវិធីបំណិនជីវិតនៅតាមមូលដ្ឋាន គឺជាស្នូលនៃការបង្កើនគុណភាព និងប្រសិទ្ធភាពក្នុងវិស័យអប់រំ ដែលនឹងផ្តល់ឱ្យសិស្សនូវចំណេះដឹងមូលដ្ឋានយ៉ាងជ្រៅជ្រះ និងពង្រឹងជំនាញផ្សេងៗ ដែលមានសារៈសំខាន់សម្រាប់ការស្រូបយកបទពិសោធន៍ល្អៗក្នុងការពង្រឹងចំណេះដឹង និងបំណិនចាំបាច់សម្រាប់បម្រើជីវភាពរស់នៅប្រចាំថ្ងៃ។

ម៉ូឌុលនេះផ្តល់ឱ្យលោកគ្រូអ្នកគ្រូនូវមេរៀនចំនួន១០ ដើម្បីជួយសម្រួលក្នុងការបង្រៀន និងការរៀនអំពីការទប់ស្កាត់ការជួញដូរមនុស្ស ដែលជាផ្នែកមួយនៃបំណិនជីវិត ទាក់ទងនឹងបញ្ហាសង្គមក្នុងមូលដ្ឋានដោយផ្តោតទៅលើសុវត្ថិភាពផ្ទាល់ខ្លួន។

ម៉ូឌុលនេះផ្សារភ្ជាប់ទៅនឹងតម្រូវការចាំបាច់នៅក្នុងជីវភាពរស់នៅ ដើម្បីជាជំនួយដល់យុវវ័យ ជៀសផុតពីការប្រឈមនឹងបញ្ហាគ្រោះថ្នាក់ និងការគម្រាមកំហែងជាច្រើនរបស់ជនខិលខូច( មេខ្យល់ មេបន អ្នកជួញដូរមនុស្ស...)។

គណៈកម្មការយើងសង្ឃឹមថា ឯកសារនេះនឹងក្លាយជាប្រយោជន៍មួយសម្រាប់ការអប់រំ និងសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះការចូលរួមកែលម្អលើឯកសារនេះ ពីសំណាក់អស់លោក លោកស្រី ដែលជាអ្នកអនុវត្ត និងអ្នកពាក់ព័ន្ធទាំងអស់។

## ១. វត្ថុបំណងរួម

*បំណិនជីវិត គឺជាបំណិនបញ្ញា បុគ្គលិកលក្ខណៈ អន្តរបុគ្គល និងវិជ្ជាជីវៈ ដែលអាចជួយដល់ការធ្វើការ សម្រេចចិត្ត ការធ្វើទំនាក់ទំនងប្រកបដោយប្រសិទ្ធភាព និងអាចដោះស្រាយបញ្ហាគ្រប់គ្រងខ្លួនឯងបាន ដើម្បីរួមចំណែកក្នុងការលើកស្ទួយសុខុមាលភាព និងជីវិតប្រកបដោយផលិតភាពក្នុងជីវិតប្រចាំថ្ងៃបានយ៉ាងជោគជ័យ។ (គោលនយោបាយបំណិនជីវិត ២០០៦)*

នៅក្នុងម៉ូឌុលនេះ បានអប់រំសិស្សានុសិស្សឱ្យមានចំណេះដឹង និងជំនាញដើម្បីៈ

- កំណត់ពីភាពខុសប្លែកគ្នារវាងការធ្វើបម្លាស់ទីទៅកាន់កន្លែងផ្សេងដែលមានសុវត្ថិភាព និងការធ្វើបម្លាស់ទីទៅកាន់កន្លែងផ្សេងដែលគ្មានសុវត្ថិភាពព្រមទាំងយុទ្ធវិធី ដែលត្រូវការដើម្បីធ្វើឱ្យប្រាកដថាការធ្វើបម្លាស់ទីទៅកាន់កន្លែងផ្សេងមានសុវត្ថិភាព
- កំណត់និយមន័យនៃការជួញដូរមនុស្ស មូលហេតុ និងផលវិបាករបស់វា
- ពណ៌នាពីរបៀបដែលការធ្វើបម្លាស់ទីទៅកាន់កន្លែងផ្សេងដោយគ្មានសុវត្ថិភាពអាចនាំទៅដល់ការជួញដូរមនុស្ស
- ពន្យល់ពីល្បិចកលដែលជាធម្មតាប្រើប្រាស់ដោយអ្នកជួញដូរមនុស្ស
- កំណត់ពីវិធីការពារកុំឱ្យមានការជួញដូរមនុស្ស។

## ២. ការត្រៀមលក្ខណៈមុនពេលបង្រៀន

ម៉ូឌុលនេះចែកចេញជាច្រើនផ្នែកផ្សេងៗគ្នា ហើយមានវត្ថុបំណងខុសៗគ្នា។ ការត្រៀមលក្ខណៈមុនពេលបង្រៀនសិស្ស ជាដំណាក់កាលត្រៀមរបស់គ្រូ។ ព័ត៌មានទាក់ទងនឹងការបង្រៀន និងរៀន ពិសេសមេរៀន ត្រូវបានគ្រូត្រៀមទុកជាមុន។

**● សម្ភារឧបទេស**

ផ្នែកនេះផ្តល់នូវសេចក្តីសង្ខេបពីសម្ភារឧបទេស។ ភាគច្រើនជាសម្ភារមូលដ្ឋាន ដូចជា ប៊ិច ឬក្រដាស។ សម្ភារផ្សេងទៀតនៅក្នុងមេរៀននេះនឹងត្រូវផ្តល់ឱ្យសិស្សសម្រាប់អនុវត្ត តាមរយៈឯកសារសម្រាប់សិស្ស ដែលបានភ្ជាប់នៅក្នុងម៉ូឌុលនេះ។

**● លទ្ធផលរំពឹងទុក**

គឺជាល្បះបញ្ជាក់នូវអ្វីនឹងត្រូវសម្រេចបាន និងវាយតម្លៃនៅខាងចុងមេរៀន។ ល្បះទាំងនេះទាក់ទងនឹង គោលដៅរួមរបស់បំណិនជីវិត ដែលបានកំណត់នៅក្នុងគោលការណ៍ណែនាំបំណិនជីវិតនៅមធ្យមសិក្សាបឋមភូមិ។

**● សញ្ញាសម្គាល់សម្រាប់សកម្មភាពនីមួយៗ**

ខាងក្រោមនេះ ជាសញ្ញាសម្គាល់សកម្មភាពងាយៗដើម្បីឱ្យគ្រូអនុវត្តបានជោគជ័យក្នុងការបង្រៀន និងរៀន។

 ធ្វើសកម្មភាព៖ គ្រូចាំបាច់ត្រូវធ្វើសកម្មភាពផ្ទាល់ខ្លួន

 សរសេរ ៖ ពេលខ្លះត្រូវការឱ្យគ្រូសរសេរនៅលើក្តារខៀន

 សួរ ៖ មានសំណួរ ដែលត្រូវសួរទៅកាន់សិស្ស

 ពន្យល់ ៖ ពន្យល់ចំណុចសំខាន់ៗ ឬ ប្រាប់សិស្សនៅក្នុងថ្នាក់

● **លំនាំបង្រៀន**

មេរៀននីមួយៗចែកជា៣ផ្នែក។ ផ្នែកទី១ គឺជាសេចក្ដីផ្ដើមដែលយើងព្យាយាមផ្សារភ្ជាប់ទៅនឹងចំណេះដឹងដែលសិស្សមានស្រាប់ ឬរំលឹកទៅមេរៀនចាស់។ ផ្នែកទី២ យើងនឹងបង្រៀនសកម្មភាពសំខាន់ៗដោយផ្អែកលើវិធីសាស្ត្របង្រៀនបែបការងារគម្រោង(ចុះស្រាវជ្រាវ ប្រមូលព័ត៌មាន សម្ភាស ចងក្រងឯកសារ និងបទបង្ហាញ...។) និងយុទ្ធវិធីបង្រៀនផ្សេងៗទៀត។ នៅផ្នែកទី៣ ដែលជាផ្នែកបញ្ចប់ យើងអាចធានាបានថា រាល់លទ្ធផលនៃការសិក្សារបស់យើង គឺបានឆ្លងកាត់នូវយុទ្ធវិធីខុសៗគ្នាជាច្រើន។

## ៣. ខ្លឹមសារសង្ខេប

មេរៀនសង្ខេបត្រូវបានផ្ដល់ជូនឱ្យគ្រូក្នុងផ្នែកនេះ ដើម្បីជាទុនខ្លះក្នុងការបង្រៀន ហើយក៏ជាសញ្ញាណមួយជាក់លាក់បញ្ជាក់ពីទំនាក់ទំនង និងសារៈសំខាន់រវាងមេរៀននីមួយៗ ។

ខាងក្រោមនេះ គឺជាសេចក្ដីសង្ខេបរួមទាំង ១០ មេរៀននៅក្នុងម៉ូឌុលបំណិនជីវិតនេះ ៖

| ចំណងជើងមេរៀន | ពេលវេលា | ខ្លឹមសារសង្ខេប | ទំព័រ |
|---|---|---|---|
| ១. ការជួញដូរមនុស្ស | ១ ម៉ោង ៣០នាទី | យើងសិក្សាពីនិយមន័យនៃ "ការជួញដូរមនុស្ស " និងភាពខុសប្លែកគ្នារវាងការជួញដូរមនុស្ស និងចំណាកស្រុក។ តាមរយៈករណីសិក្សា យើងនឹងទទួលបានបទពិសោធន៍នៃស្ថានភាពជួញដូរមនុស្សខុសៗគ្នា ព្រមទាំងកត្តាជំរុញ និងកត្តាអូសទាញសម្រាប់ការជួញដូរមនុស្សនេះ។ | ១ |
| ២. ការជួញដូរមនុស្ស (ត) | ១ ម៉ោង ៣០នាទី | បន្ទាប់ពីការសិក្សាបឋមនៃការជួញដូរមនុស្ស យើងនឹងសិក្សាបន្ថែមទៀតអំពីវិធីដែលឈ្មួញជួញដូរមនុស្សប្រើប្រាស់ និងមធ្យោបាយខុសៗគ្នានៃការកេងយកផលប្រយោជន៍។ យើងបង្រៀនឱ្យសិស្សត្រៀមខ្លួន និងគិតឱ្យបានស៊ីជម្រៅហើយនឹងសួរសំណួរដើម្បីរៀនបន្ថែមទៀតអំពីល្បិចកល ដែលអាចមានពីឈ្មួញជួញដូរមនុស្ស។ | ៥ |
| ៣. តើអ្នកមកពីណា? | ១ ម៉ោង ៣០នាទី | មេរៀននេះ រំលឹកពីចំណេះដឹងដែលមានស្រាប់អំពីការធ្វើបម្លាស់ទីទៅកាន់កន្លែងផ្សេង។ យើងកំណត់ពីមូលហេតុនៃ ការធ្វើបម្លាស់ទីទៅកាន់កន្លែងផ្សេង ហើយយើងលេងល្បែងកំសាន្ត ដែលយើងរៀនពីបញ្ហា សាមញ្ញចំពោះអ្នកការធ្វើបម្លាស់ទីទៅកាន់កន្លែងផ្សេងជួបប្រទះ។ បន្ទាប់ពីនោះ យើងពិភាក្សាពីគ្រោះថ្នាក់ និងគុណប្រយោជន៍ដែលអាច មាន។ | ១៤ |
| ៤. សុវត្ថិភាព និងគ្មានសុវត្ថិភាព | ១ ម៉ោង ៣០នាទី | ជាមួយចំណេះដឹងដែលសិស្សទទួលបានតាមរយៈការ ស្ទង់មតិ យើងនឹងធ្វើការអង្កេតបន្ថែមទៀតអំពីការធ្វើបម្លាស់ទីទៅកាន់កន្លែងផ្សេងមានសុវត្ថិភាព និងការធ្វើបម្លាស់ទីទៅកាន់កន្លែងផ្សេងគ្មានសុវត្ថិភាព។ យើងធ្វើការ ប្រមើលមើលចំណេះដឹងនេះតាមរយៈផ្ទាំង រូបភាពមួយ។ | ២០ |
| ៥. ផ្ទាំងរូបភាព | ១ ម៉ោង ៣០នាទី | ផ្ទាំងរូបភាពដែលបង្កើតឡើង ដោយសិស្សត្រូវបានធ្វើការវាយតម្លៃ។ យើង "ផ្ដល់មតិយោបល់ និងសរសើរ" គ្នាទៅវិញទៅមកអំពីកិច្ចការនេះ។ លើសពីនេះទៀត យើងស្វែងយល់ឱ្យកាន់តែស៊ីជម្រៅនូវចំណេះដឹងរបស់យើងអំពីការត្រៀមការការធ្វើបម្លាស់ទីទៅកាន់កន្លែងផ្សេងទៅកាន់ទីក្រុង។ តើការរៀបចំ និងជម្រើសណាមួយដែលអ្នកគួរតែជ្រើសរើស? | ២៤ |

| | | | |
|---|---|---|---|
| ៦. ទីក្រុងធំ | ១ ម៉ោង ៣០នាទី | ដោយសារអ្នកការធ្វើបម្លាស់ទីទៅកាន់ កន្លែងផ្សេងនៅជនបទភាគច្រើនទៅទីក្រុងភ្នំពេញ សិស្សនឹងសិក្សាបន្ថែមទៀតអំពីទីក្រុងនេះ។ ពួកគេកំណត់ភាពខុសប្លែកគ្នារវាងទីក្រុងធំមួយ និង ភូមិតូចមួយ។ ពួកគេក៏រៀនកត់ចំណាំទីតាំងមួយចំនួនក្នុងទីក្រុងព្រមទាំងរៀនពីមុខងារនិងប្រវត្តិរបស់ពួកវា។ | ២៩ |
| ៧. ផ្សព្វផ្សាយព័ត៌មាន | ១ ម៉ោង ៣០នាទី | សិស្សធ្វើយុទ្ធនាការលើកកម្ពស់ការយល់ដឹង នៅក្នុងសហគមន៍ដើម្បីបង្ហាញពីចំណេះដឹងរបស់ពួកគេអំពីចំណាកស្រុកមានសុវត្ថិភាព។ ពួកគេចែកខិត្តប័ណ្ណ ឬផ្ទាំងរូបភាពទៅឱ្យអ្នកភូមិព្រមទាំងផ្តល់ព័ត៌មានដល់ពួកគេ។ | ៣៦ |
| ៨. ការមកដល់ទីក្រុង | ១ ម៉ោង ៣០នាទី | បន្ទាប់ពីការរៀបចំទាំងនេះ សិស្សត្រូវសំដែងជាធ្វើដំណើរទៅទីក្រុងភ្នំពេញ។ ពួកគេរៀនអំពីជម្រើសសុវត្ថិភាពផ្សេងៗក្នុងការស្វែងរកផ្ទះជួល និងរៀនសម្របខ្លួនជាមួយជីវិតនៃអ្នកទីក្រុង។ នេះមានន័យថា រៀនពីរបៀបដែលធ្វើឱ្យមានអារម្មណ៍សប្បាយចិត្ត និងអ្វីដែលគួរដាក់បញ្ចូលទៅក្នុងកិច្ចសន្យាជួល។ | ៣៨ |
| ៩. ច្បាប់ស្តីពីការបង្ក្រាបអំពើពង្រាត់ និងជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មលើមនុស្ស | ១ ម៉ោង ៣០នាទី | តួនាទីរបស់រដ្ឋាភិបាល និងច្បាប់ប្រឆាំងការជួញដូរមនុស្សត្រូវបានសិក្សា។ យើងរៀនពីសេចក្តីដកស្រង់នៃច្បាប់ប្រឆាំងការជួញដូរមនុស្ស និងអំពីសិទ្ធិរបស់ជនរងគ្រោះ និងគ្រួសារ។ វាគ្មិនកិត្តិយសម្នាក់មកពីសហគមន៍នឹងត្រូវបានអញ្ជើញមកដើម្បីនិយាយអំពីករណីក្នុងមូលដ្ឋាន និងកិច្ចខំប្រឹងប្រែង និងយុទ្ធនាការប្រឆាំងការជួញដូរមនុស្ស។ | ៤៦ |
| ១០. ការវាយតម្លៃចំណេះដឹង | ១ ម៉ោង ៣០នាទី | សិស្សធ្វើបទបង្ហាញពីជំនាញ និងចំណេះដឹងរបស់ពួកគេតាមរយៈ ការធ្វើបទបង្ហាញណែនាំមួយនៅក្នុងថ្នាក់រៀន។ ពួកគេអញ្ជើញសិស្សពីថ្នាក់ទី៩/១២ផ្សេងទៀត ឬបងប្អូនណាម្នាក់មកទស្សនា។ បន្ទាប់ពីនោះ ចំណេះដឹងនឹងត្រូវបានវាយតម្លៃតាមរយៈសំណួរសរសេរមួយ។ | ៥៣ |

## ៤. ការវាយតម្លៃ

ការវាយតម្លៃមាន២ផ្នែកសំខាន់ៗ។ មួយផ្នែកជាការវាយតម្លៃនៅចុងបញ្ចប់នៃម៉ូឌុលនីមួយៗ និងជាវិញ្ញាសាសរសេរ ដែលយើងត្រូវបញ្ចូលនៅផ្នែកខាងចុងម៉ូឌុល ។ ផ្នែកមួយទៀត ជាការវាយតម្លៃទៅលើឥរិយាបថសិស្ស ដោយគ្រូជាអ្នកសង្កេត ផ្ទាល់រៀងរាល់ថ្ងៃ ហើយដាក់ពិន្ទុ។ វិធីវាយតម្លៃទាំងពីរចំណុចនេះមានសារៈសំខាន់ក្នុងការវាស់ចំណេះដឹង និងឥរិយាបថរបស់សិស្សម្នាក់ៗ ។ ចំពោះការវាយតម្លៃសិស្សនេះ យើងគិតពិន្ទុ ៥០ ស្មើទៅនឹងមុខវិជ្ជាមួយចំនួនផងដែរ គឺយើងឱ្យពិន្ទុ ៣៥ ទៅលើឥរិយាបថ និងពិន្ទុ ១៥ ទៅលើវិញ្ញាសាសរសេរ។

## ៥. ឯកសារបន្ថែម

ផ្នែកនេះផ្តល់នូវព័ត៌មានរួមសម្រាប់គ្រូប្រើប្រាស់ រួមទាំងផ្ទាំងរូបភាពសម្រាប់គ្រូប្រើប្រាស់នៅក្នុងមេរៀននេះ។

# មេរៀនទី ១: ការជួញដូរមនុស្ស

រយៈពេលបង្រៀន: ១ម៉ោង ៣០នាទី

**ការត្រៀមលក្ខណៈ**

មុនពេលបង្រៀនលោកគ្រូ អ្នកគ្រូត្រូវ

- អាន និងពិនិត្យមេរៀនដោយហ្មត់ចត់ និងធ្វើកិច្ចតែងការបង្រៀន
- ពិនិត្យមើលឯកសារសិស្ស ដើម្បីចង់ដឹងថាតើមានព័ត៌មាន និងសំណួរ សម្រាប់សកម្មភាពគ្រូវ នឹងការបង្រៀនដែរឬទេ
- សរសេរសំណួរលើក្តារខៀន ឬនៅលើក្រដាសផ្ទាំងធំ។ ប្រសិនបើសិស្សមានឯកសារ គេអាចមើលព័ត៌មាននេះនៅក្នុងសៀវភៅរបស់គេបាន
- មើលកាលវិភាគប្រចាំថ្ងៃ
- រៀបចំបន្ទប់រៀន (តុ កៅអី ក្តារខៀន...)។

**សម្ភារឧបទេស ធនធានដែលត្រូវការ**

- ករណីសិក្សារបស់ ចាន់ធី

**វត្ថុបំណង**

នៅពេលរៀនមេរៀននេះចប់ សិស្សនឹងអាចៈ

- ផ្តល់និយមន័យ ការជួញដូរមនុស្ស។
- កំណត់ពីវិធីដែលឈ្មួញជួញដូរមនុស្សប្រើប្រាស់។
- ស្វែងយល់ពីកត្តាជំរុញ និងកត្តាអូសទាញដែលរួមចំណែកដល់ការជួញដូរមនុស្ស។

## សេចក្តីផ្តើមៈ ចំណេះដឹងដែលមានស្រាប់

១៥ នាទី

តើមាននរណាម្នាក់នៅក្នុងថ្នាក់រៀននេះធ្លាប់បានឮពាក្យ "ការជួញដូរមនុស្ស" ដែរឬទេ ? ប្រសិនបើមាន តើអ្នកអាចពន្យល់ពីអត្ថន័យរបស់វាបានដែរឬទេ ? ប្រសិនបើមិនធ្លាប់ឮ តើអ្នកគិតថាវាមានអត្ថន័យយ៉ាងណា ?

បិទនិយមន័យ "ការជួញដូរមនុស្ស" ដែលបានត្រៀមរួចមកហើយនោះនៅលើក្តារខៀន

*និយមន័យ "ការជួញដូរមនុស្ស"*

*"ការជួញដូរមនុស្ស" ជាការដោះដូរដោយមានការបង្ខំ ការដើរខ្សែលើ ឬមានការបិទបាំងអ្វីមួយ។ វាមិនមែនជាជម្រើសរបស់ពួកគេទេ តែមានការកេងប្រវ័ញ្ចដោយភាពអវិជ្ជា ភាពក្រីក្រ ឬការ គ្មានទីពឹងពាក់របស់ពួកគេ។ ពួកគេត្រូវបានប្រើប្រាស់ដោយឈ្មួញទុច្ចរិតអាចទទួលបានផលប្រយោជន៍ជាប្រាក់កាស។ ការកេងប្រវ័ញ្ចអាចជាការកេងប្រវ័ញ្ចកម្លាំងពលកម្ម ប៉ុន្តែជាញឹកញយតែងយកចំណេញខាងផ្លូវភេទដែលកុមារ និងស្ត្រីជាអ្នកប្រឈមមុខខ្ពស់បំផុត។"*

ខ្ញុំនឹងអានឱ្យអ្នកទាំងអស់គ្នាស្តាប់នូវករណីសិក្សាមួយ អំពីស្ត្រីម្នាក់ ដែលមានឈ្មោះថា "ចាន់ធី"។ គាត់ត្រូវបានគេជួញដូរដោយស្ត្រីម្នាក់ឈ្មោះ "រំដួល"។ រំដួលជាមិត្តភក្តិរបស់បងស្រី ចាន់ធី ហើយរំដួលក៏នៅក្នុងភូមិជាមួយគ្នាផងដែរ។

តើអ្នកគិតថាចាន់ធីត្រូវបានគេជួញដូរដោយរបៀបណា?

អានករណីសិក្សានៅក្នុងសេចក្តីណែនាំគ្រូ។ អ្នកអាចផ្អាកបន្តិចនៅចុងកថាខណ្ឌនីមួយៗ ដើម្បីឱ្យសិស្សទាយថាអ្វីនឹងកើតឡើងបន្តទៀត។

## សកម្មភាពសំខាន់។: ករណីសិក្សា

៤៥ នាទី

ករណីរបស់ចាន់ធី

ហេតុអ្វីបានជាធ្លាក់ខ្លួនក្នុងការជួញដូរមនុស្ស?

ចម្លើយអាចមាន៖ *ការខ្វះគម្រោង ចំណេះដឹងអាចបង្កើតជាការប្រឈម និងធ្វើឱ្យអ្នកបំលាស់ទីទៅកាន់កន្លែងផ្សេងកាន់តែងាយរងគ្រោះ។*

ឈ្មួញជួញដូរមនុស្សអាចធ្វើការជួញដូរនៅកន្លែងជាច្រើន។ ពួកគេអាចមកភូមិរបស់យើង ហើយបោកបញ្ឆោតយើងដោយការនិយាយនូវអ្វីដែលយើងពិតជាចង់ឮ...។

តើអ្វីដែលពួកគេអាចប្រាប់យើងនិងធ្វើឱ្យយើងមានចំណាប់អារម្មណ៍? (ការងារនៅទីក្រុង ការផ្សងព្រេង ការធ្វើដំណើរ ។ល។)

ឈ្មួញជួញដូរមនុស្សក៏អាចធ្វើការជួញដូរ ខណៈពេលដែលយើងកំពុងធ្វើចំណាកស្រុកផងដែរ។ ពួកគេអាចនៅលើឡាន ពួកគេអាចរង់ចាំយើងនៅបេនឡាន ហើយព្យាយាមបោកបញ្ឆោតយើងដោយការសន្យាកុហក។ ពួកគេអាចជាមនុស្សដែលយើងមិនស្គាល់ ប៉ុន្តែភាគច្រើន ពួកគេជាអ្នកដែលយើងស្គាល់។

យើងបានស្តាប់រឿងរបស់ចាន់ធីម្តងរួចមកហើយ ខ្ញុំនឹងអានរឿងនេះឱ្យអ្នកស្តាប់ម្តងទៀត។ លើកនេះអ្នកត្រូវស្តាប់ដោយយកចិត្តទុកដាក់ និងឆ្លើយសំណួរខាងក្រោមនេះ៖

តើយើងអាចធ្វើបានអ្វីខ្លះ ដើម្បីការពារ ចាន់ធី កុំឱ្យគេជួញដូរ?

អ្នកអាចគិតរកចម្លើយសម្រាប់សំណួរនេះនៅគ្រប់ផ្នែកទាំងអស់នៃរឿង។ មានកិច្ចការ ជាច្រើនដែលអាចធ្វើដើម្បីការពារកុំឱ្យមានការជួញដូរមនុស្ស ប៉ុន្តែក៏នៅតែមានឱកាសជួយ បើទោះបីជាចាន់ធីត្រូវបានគេរំលោភបំពានរួចមកហើយ។

ចូរសរសេរសកម្មភាពទាំងនោះនៅក្នុងសៀវភៅរបស់អ្នក។

អានរឿងរបស់ចាន់ធីម្តងទៀត

ឥឡូវអ្នកកាន់សៀវភៅ និងទៅនិយាយប្រាប់មនុស្សចំនួនបីនាក់នៅក្នុងថ្នាក់អំពីជម្រើស(សកម្មភាព)របស់អ្នក។ អ្នកត្រូវពន្យល់ពួកគេ និងស្តាប់ចម្លើយរបស់ពួកគេ។ ប្រសិនបើអ្នកបានឮអ្វីដែលអ្នកអាចប្រើប្រាស់បាន (ចម្លើយដ៏ល្អដែលអ្នកមិនបាននឹកឃើញ) អ្នកអាចបន្ថែមវាចូលទៅក្នុងសៀវភៅរបស់អ្នក។

អនុញ្ញាតឱ្យសិស្សធ្វើសកម្មភាព និងចែករំលែកចម្លើយរបស់ពួកគេ។

តើដំបូន្មានណាខ្លះ (ទាក់ទងនឹងការជួញដូរមនុស្ស) ដែលអ្នកអាចផ្តល់ឱ្យនរណាម្នាក់ដែល ចង់*បំលាស់ទីទៅកាន់កន្លែងផ្សេង*?

វាពិតជាមានសារៈសំខាន់ណាស់ ជាពិសេសសម្រាប់ស្ត្រីដែលមិនត្រូវធ្វើដំណើរតែម្នាក់ឯង ទាល់តែសោះ!

**បញ្ចប់មេរៀនៈ ការសម្តែងរឿង** ៣០ នាទី

មិនមាននរណាម្នាក់ដែលប្រឈមមុខនឹងការជួញដូរដោយគ្មានអ្វីជំរុញ ឬអូសទាញនោះទេ។ វាតែងតែមានកត្តាមួយចំនួនដែលជះឥទ្ធិពលដល់ឱកាសដែលត្រូវបានគេជួញដូរ។ យើងហៅអ្វីទាំងអស់នោះថា"កត្តាជំរុញ និងកត្តាអូសទាញ"។ ខ្ញុំនឹងសរសេរ កត្តាខ្លះៗនៅលើក្តារខៀន។

- ភាពក្រីក្ររបស់គ្រួសារ
- ស្វែងរកការងារ
- ត្រូវការប្រាក់ដើម្បីទិញរបស់មានតម្លៃ
- ជម្លោះគ្រួសារ ឬគ្រួសារមានការបែកបាក់
- គ្រោះធម្មជាតិ ឬសង្គ្រាម។

នៅមានកត្តាជាច្រើនទៀត ហើយនេះគ្រាន់តែជាការបង្ហាញកត្តាខ្លះៗតែប៉ុណ្ណោះ។ ជាមួយកត្តាជំរុញ និងកត្តាអូសទាញទាំងនេះ ខ្ញុំចង់ឱ្យអ្នកធ្វើលំហាត់មួយជាដៃគូ អ្នកត្រូវរៀបចំការសម្តែងរឿងមួយ។ ម្នាក់ក្នុងចំណោមអ្នកទាំងពីរជាមនុស្សអាក្រក់ ហើយម្នាក់ទៀតជាជនរងគ្រោះ។ អ្នកត្រូវសម្តែងពីស្ថានភាពដែលនាំឱ្យមានការជួញដូរមនុស្ស។ មានវិន័យមួយ គឺអ្នកមិនអាចនិយាយបានទេ ប៉ុន្តែអាចប្រើសម្លេង ធ្វើគ្រាប់តាម និងធ្វើកាយវិការ។ សិស្សដទៃត្រូវសង្កេត និងទាយថាអ្វី កំពុងកើតឡើង។

ប្រសិនបើអាចផ្តល់ឧទាហរណ៍មួយអំពីក្មេងប្រុសម្នាក់ដែលកំពុងអង្គុយនៅតាមផ្លូវ។ ក្មេងនោះមានទឹកមុខស្រងូតស្រងាត់ និងមិនដឹងថាត្រូវធ្វើអ្វីទេ ព្រោះគាត់ជាមនុស្សក្រីក្រ និងគ្មានការងារធ្វើ។ រំពេចនោះ មានឡានមួយបើកមកឈប់ក្បែរគាត់។ បុរសម្នាក់បានចេញពីឡាន ហើយបក់ដៃហៅក្មេងនោះ។ ពួកគេបាននិយាយគ្នាមួយសន្ទុះ បន្ទាប់មកក្មេងប្រុសនោះក៏បានឡើងឡាន។ ពួកគេក៏បានបើកចេញទៅ...។

តើមានអ្វីកើតឡើងនៅទីនេះ?

ទុកពេល១០នាទី ឱ្យសិស្សពិភាក្សាជាដៃគូ។
*បន្ទាប់មក ឱ្យដៃគូមួយចំនួនឡើងបង្ហាញពីគំនិតរបស់ពួកគេ និងឱ្យសិស្សដទៃទៀតទាយថាតើមានរឿងអ្វីកំពុងកើតឡើង។*

អរគុណអ្នកទាំងអស់គ្នាដែលបានចូលរួមក្នុងថ្នាក់នេះ ខ្ញុំសង្ឃឹមថានឹងជួបអ្នកនៅសប្តាហ៍ក្រោយទៀត។

## សេចក្ដីណែនាំគ្រូ ករណីសិក្សាអំពីការជួញដូរមនុស្ស

### រឿងរបស់ ចាន់ធី

ខ្ញុំបានជួបរំដួលនៅឯវត្តក្នុងអំឡុងថ្ងៃចូលឆ្នាំថ្មី។ នាងគឺជាអ្នកភូមិជាមួយខ្ញុំ ហើយជាមិត្តភក្តិរបស់បងស្រីខ្ញុំ។ នាងបានចាកចេញពីភូមិកាលពីប៉ុន្មានឆ្នាំមុននេះ។ ខ្ញុំមិនដែលបានជួបនាងទាល់តែសោះតាំងពីពេលដែលនាងចាកចេញទៅ។ រំដួលមានការងារល្អ និងមើលទៅស្អាតបាត រួមទាំងសម្លៀកបំពាក់ និងសក់របស់នាង។ ខ្ញុំក៏ចង់ចាកចេញពីស្រុកកំណើតដែរ ព្រោះគ្រួសាររបស់ខ្ញុំក្រណាស់ ហើយឪពុករបស់ខ្ញុំគឺជាជនពិការ និងតែងតែស្រវឹងជារឿយៗ។ យើងស្ទើរតែគ្មានអ្វីចិញ្ចឹមប្អូនតូចៗ។ តាំងពីអាយុ១០ឆ្នាំមក ខ្ញុំតែងតែនៅផ្ទះ និងធ្វើការដាំស្ល មើលប្អូនៗ បោកសម្លៀកបំពាក់។ ខ្ញុំតែងតែអស់កម្លាំង និងធុញថប់ណាស់។ រំដួលបានសន្យាថានឹងរកការងារឱ្យខ្ញុំធ្វើក្នុងក្លឹបកំសាន្តទំនើបមួយក្នុងទីក្រុងភ្នំពេញ។ រំដួលមានឫកពារល្អដែលខ្ញុំគ្មានហេតុផលណាមិនជឿនាងនោះទេ។ នាងបានឱ្យលេខទូរស័ព្ទរបស់នាងមកខ្ញុំ និងឱ្យខ្ញុំខ្ចីលុយ ២០ដុល្លារទុកសម្រាប់ជិះរថយន្តឈ្នួល។ នាងបានប្រាប់ខ្ញុំថា មិនឱ្យប្រាប់អ្នកដទៃទេ ព្រោះខ្លាចគេច្រណែន។

បន្ទាប់ពីទុកប្រាក់១៥ដុល្លារឱ្យម្ដាយខ្ញុំរួច ខ្ញុំជិះរថយន្តឈ្នួល និងទូរស័ព្ទទៅប្រាប់រំដួលថានាងទៅជួបខ្ញុំនៅផ្សារធំថ្មី។ រំដួលបាននាំខ្ញុំទៅកាន់ក្លឹបកំសាន្តមួយ ហើយទុកខ្ញុំឱ្យនៅជាមួយម្ចាស់ហាងនោះ។ ម្ចាស់ហាងនោះបាននាំខ្ញុំទៅកាន់ហាងលក់សម្លៀកបំពាក់ ហើយទិញសម្លៀកបំពាក់ ២សម្រាប់ និងស្បែកជើង១គូឱ្យខ្ញុំ។ ខ្ញុំគិតថា ដំបូងខ្ញុំនឹងធ្វើជាអ្នកជូត គុសិន បន្ទាប់មកទើបធ្វើជាអ្នកបម្រើ។ ប៉ុន្តែនៅយប់ដំបូង ម្ចាស់ហាងបានប្រាប់ខ្ញុំឲ្យរង់ចាំនៅក្នុងបន្ទប់ ខណៈពេលដែលគាត់ទៅជួបអ្នកដែលត្រូវការខ្ញុំ។

ខ្ញុំមិនដែលបានធ្វើការជាអ្នកបម្រើទេ។ ផ្ទុយទៅវិញមានក្មេងទំនើង២នាក់របស់ម្ចាស់ហាង បានចាប់ផ្ដើមគំរាម និងវាយធ្វើបាបខ្ញុំ ហើយប្រាប់ខ្ញុំថា ខ្ញុំត្រូវបានគេលក់ឱ្យមកទីនេះ និងត្រូវតែរកប្រាក់សងគេវិញ។ ពួកគេប្រាប់ថា ខ្ញុំត្រូវតែរួមភេទជាមួយភ្ញៀវ ហើយប្រសិនបើខ្ញុំមិនព្រម ខ្ញុំនឹងទទួលរងការវាយដំជាទម្ងន់។ ខ្ញុំមិនអាចរត់គេចចេញបានទេ ព្រោះគេចាក់សោរខ្ញុំទុកនៅក្នុងបន្ទប់ ព្រមទាំងយាមខ្ញុំទៀតផង។ ខ្ញុំធ្លាប់ប្រាប់រឿងនេះដល់ភ្ញៀវមួយចំនួន ហើយមានអ្នកខ្លះថាពួកគេនឹងជួយខ្ញុំ តែគ្មាននរណាម្នាក់ធ្វើបានសោះ។

# មេរៀនទី ២: ការជួញដូរមនុស្ស(ត)

🕑 រយៈពេលបង្រៀន: ១ម៉ោង ៣០នាទី

☑ ការត្រៀមលក្ខណៈ

មុនពេលបង្រៀនលោកគ្រូ អ្នកគ្រូត្រូវ

- អាន និងពិនិត្យមេរៀនដោយហ្មត់ចត់ និងធ្វើកិច្ចតែងការបង្រៀន
- ពិនិត្យមើលឯកសារសិស្ស ដើម្បីចង់ដឹងថាតើមានព័ត៌មាន និងសំណួរ សម្រាប់សកម្មភាពត្រូវនឹងការបង្រៀនដែរឬទេ
- សរសេរសំណួរលើក្តារខៀន ឬនៅលើក្រដាសផ្ទាំងធំ  ប្រសិនបើសិស្សមានឯកសារ គេអាចមើលព័ត៌មាននេះនៅក្នុងសៀវភៅរបស់គេបាន
- មើលកាលវិភាគប្រចាំថ្ងៃ
- រៀបចំបន្ទប់រៀន (តុ កៅអី ក្តារខៀន...)។
- មើលកាលវិភាគប្រចាំថ្ងៃ
- រៀបចំបន្ទប់រៀន ៖ តុ កៅអី ក្តារខៀន។ ល។

📖 សម្ភារឧបទេស ធនធានដែលត្រូវការ

- ឯកសារ ២.១៖ សម្រាប់សិស្ស "ការពិតអំពីការជួញដូរមនុស្ស "
- ឯកសារ ២.១៖ សម្រាប់សិស្ស "ករណីសិក្សា"

☼ វត្ថុបំណង

នៅពេលរៀនមេរៀននេះចប់ សិស្សនឹងអាចៈ

- កំណត់កត្តាអូសទាញ និងកត្តាជំរុញ តួអង្គសំខាន់ៗ យុទ្ធវិធី និងល្បិចកលផ្សេងៗ ព្រមទាំងរបៀបកេងប្រវ័ញ្ចចំពោះជនរងគ្រោះដោយសារការជួញដូរ។
- បង្ហាញពីជំហានសំខាន់ៗដើម្បីការពារមិនឱ្យមានការជួញដូរមនុស្ស។

🕑 ១៥ នាទី

## សេចក្តីផ្តើម

👄 យើងនឹងលេងល្បែងកំសាន្តមួយនៅក្នុងថ្នាក់អំពីអគារ  និងទីតាំងមួយចំនួនក្នុងទីក្រុងភ្នំពេញ។ សិស្សម្នាក់ក្នុងចំណោមអ្នកទាំងអស់គ្នានឹងជ្រើសរើសប័ណ្ណមួយពីក្នុងប្រអប់។  អ្នកមិនអាចបង្ហាញរូបភាពនេះដល់សិស្សដទៃបានទេ ប៉ុន្តែអ្នកអាចប្រាប់នូវអ្វីដែលមាននៅលើរូបភាពនោះដោយការពណ៌នា។ អ្នកអាចរៀបរាប់ពីរូបរាង ទំហំ ទីតាំង និងពណ៌។

ឧទាហរណ៍ ៖ នៅចំកណ្តាលនៃរូបភាពគឺមានរូបការេពណ៌ក្រហមដ៏ធំមួយ។ នៅក្នុងការ៉េនោះ គឺមានបង្គួចមូល៥...។ សិស្សទាំងអស់អាចស្តាប់ការពន្យល់នេះ និងគូរវានៅក្នុងពេលដំណាលគ្នា។ នៅចំណុចណាមួយ អ្នកប្រហែលជានឹងអាចស្គាល់ពីអគារនោះ។ អ្នកទីមួយដែល ស្គាល់វាអាចស្រែកប្រាប់ចម្លើយបាន។ ប្រសិនបើអ្នកឆ្លើយត្រូវ អ្នកនឹងក្លាយជាអ្នកបន្ទាប់ដែលត្រូវជ្រើសរើសប័ណ្ណមួយទៀត។ *លេងល្បែងកំសាន្តនេះមួយសន្ទុះ។*

## សកម្មភាពសំខាន់។ ⌚ ៥៥ នាទី

តើនរណានៅចាំអ្វីដែលយើងបានរៀនពីសប្តាហ៍មុន?
បិទនិយមន័យ "ការជួញដូរមនុស្ស" នៅលើក្តារខៀនម្តងទៀត។
មានរឿងរ៉ាវជាច្រើនដែលទាក់ទងការជួញដូរមនុស្សនៅក្នុងប្រទេសកម្ពុជា។ លំហាត់បន្ទាប់គឺត្រូវធ្វើជាក្រុម។ ក្រុមនីមួយៗមានសមាជិក ៤នាក់ ហើយនឹងទទួលបានរឿងមួយ។ ខ្ញុំចង់ឱ្យអ្នកអានរឿងនេះដោយយកចិត្តទុកដាក់ ហើយឆ្លើយនឹងសំណួរ ខាងក្រោម ៖

- តើនៅក្នុងសាច់រឿងនិយាយអំពីអ្វី?
- ហេតុអ្វីប្រជាជនសម្រេចចិត្តចាកចេញពីផ្ទះ?
- តើវាជាស្ថានភាពនៃការជួញដូរមនុស្សឬ? ហេតុអ្វី?
- តើឈ្មួញជួញដូរមនុស្សជាអ្នកណាខ្លះ?
- តើគេប្រើប្រាស់វិធីបែបណាខ្លះក្នុងការទាក់ទាញចិត្ត?
- តើបុគ្គលនោះអាចធ្វើបានឬអត់ក្នុងស្ថានភាពនៃសាច់រឿង? ដើម្បីការពារខ្លួនកុំឱ្យធ្លាក់ជាជនរងគ្រោះនៃការជួញដូរ តើបុគ្គលត្រូវធ្វើដូចម្តេចខ្លះ?
- តាមរយៈរឿងនេះ តើអ្នកទទួលបាននូវបទពិសោធន៍អ្វីខ្លះ?

👄 ឱ្យសិស្សអង្គុយជាក្រុមតូចៗ និងពិភាក្សាពីរឿងដែលអ្នកបានឱ្យទៅពួកគេ។ ទុកពេលប្រហែល១០នាទីឱ្យពួកគេធ្វើកិច្ចការនេះ។
អ្នកបានអាន និងវិភាគរឿងមួយរួចមកហើយ ប៉ុន្តែដូចអ្វីដែលអ្នកទាំងអស់គ្នាបានដឹង គឺមានរបៀបជួញដូរមនុស្សខុសៗគ្នាជាច្រើន។ សម្រាប់កិច្ចការបន្ទាប់ អ្នកនឹងត្រូវការ ឯកសារ ២.១ សម្រាប់សិស្ស ផងដែរ។ ឯកសារនេះប្រាប់អ្នកអំពី៖

*កត្តាអូសទាញនិងកត្តាជំរុញ*

- *តួអង្គសំខាន់ៗ*
- *យុទ្ធវិធី និងល្បិចកលបោកបញ្ឆោត*
- *ការជួញដូរមនុស្ស និងការកេងប្រវ័ញ្ចពលកម្ម។*

ដំបូង យើងនឹងអានឯកសារនេះជាមួយគ្នា។
ចែកឯកសារសម្រាប់សិស្ស ៧.១ ទៅឱ្យសិស្ស និងឱ្យសិស្សមួយចំនួនអានឮៗដើម្បីឱ្យសិស្សដទៃស្តាប់។
ជាមួយព័ត៌មាននេះ យើងនឹងអង្កេតរឿងដទៃទៀត។ ក្រុមនីមួយៗ ត្រូវសង្កេតយ៉ាងតិចណាស់ ៤រឿងផ្សេងទៀត និងព្យាយាមកំណត់ :

១. កត្តាអូសទាញ និងកត្តាជំរុញ
២. តួអង្គសំខាន់ៗ
៣. យុទ្ធវិធីបោកបញ្ឆោត
៤. ការកេងប្រវ័ញ្ច

នៅក្នុងក្រុមរបស់អ្នក អ្នកអាចពិភាក្សាពីធាតុខុសៗគ្នាក្នុងសាច់រឿង ហើយសរសេរវាទុកក្នុងសៀវភៅរបស់អ្នក។ អ្នកអាចជ្រើសរើសករណីសិក្សាផ្សេងៗទៀតដោយខ្លួនរបស់អ្នក។ មានករណីសិក្សាចំនួន៩ខុសៗគ្នា។
អនុញ្ញាតឱ្យសិស្សដើរជុំវិញបន្ទប់រៀន និងជ្រើសរើសករណីសិក្សា។ ម្នាក់ក្នុងចំណោមពួកគេទាំងអស់គ្នា ជាអ្នកអាន រីឯអ្នកផ្សេងទៀត ជួយកំណត់ពីចំណុចទាំង៤ខុសៗគ្នា ដូចបានរៀបរាប់ខាងលើនេះ។ ក្រោយពេល២០នាទី ឬនៅ ពេលពួកគេបញ្ចប់ អ្នកអាចឱ្យសិស្សត្រឡប់ទៅកាន់កន្លែងរបស់ពួកគេវិញ។

ខ្ញុំនឹងជ្រើសរើសករណីសិក្សាមួយ ដោយខ្លួនរបស់ខ្ញុំនិងអានវាខ្លាំងៗ។ បន្ទាប់មក ខ្ញុំចង់ដឹងពីធាតុខុសៗគ្នាណាខ្លះដែលអ្នករកឃើញ។ យើងនឹងបង្កើតជាបញ្ជីដ៏ពេញលេញមួយនៃធាតុ ទាំងនោះជាមួយគ្នា។

សួរសិស្សអំពីកត្តាជម្រុញ និងអូសទាញ វិធីសាស្រ្ត តួអង្គ និងរបៀបក្នុងការកេងប្រវ័ញ្ច និងអនុញ្ញាតឱ្យពួកគេបំពេញបន្ថែមឱ្យគ្នាទៅវិញទៅមក។ ធ្វើដូចគ្នានេះជាមួយករណីសិក្សាផ្សេងៗទៀត និងព្យាយាមឱ្យសិស្សទាំងអស់ចូលរួមក្នុងការបន្ថែមព័ត៌មានថ្មីៗទៀត។

អរគុណអ្នកទាំងអស់គ្នាសម្រាប់ការសង្កេតដ៏ល្អរបស់អ្នក។ ខ្ញុំគិតថា យើងយល់បានយ៉ាងច្បាស់ហើយអំពីការជួញដូរមនុស្ស។ ការជួញដូរមនុស្សមានន័យថា ការជ្រើសរើស ការបង្ខាំងទុក ការបញ្ជូន ការលាក់បាំង ឬទទួលមនុស្សដោយមធ្យោបាយបង្ខិតបង្ខំ ការគំរាមកំហែង ការប្រើកម្លាំង ការបោកប្រាស់ ការបន្លំ និងការប្រើអំណាចក្នុងគោលបំណងដើម្បីកេងចំណេញ យកប្រយោជន៍ពីបុគ្គលនោះ ។ ឈ្មួញជួញដូរអាចប្រើប្រាស់វិធីសាស្រ្ត និងល្បិចកលផ្សេងៗ ព្រមទាំងការនិយាយលួងលោមអូសទាញ។ ល្បិចកលអាចកាន់តែខ្ពស់ទៅៗ(ពិបាកយល់)។ ប្រជាជនតែងតែគិតថាពួកគេដឹងអ្វីដែលពួកគេកំពុងធ្វើ នៅពេលណាដែលពួកគេចាប់ផ្តើមធ្វើបំលាស់ទីទៅកាន់កន្លែងផ្សេង ប៉ុន្តែពួកគេប្រហែលជាមិនដឹងពីចម្ងាយនៃគ្រោះថ្នាក់ និងការប្រឈមនានាទេ។ ការជួញដូរមនុស្ស អាចកើតឡើងនៅគ្រប់ដំណាក់កាលទាំងអស់ នៃការធ្វើបំលាស់ទីទៅកាន់កន្លែងផ្សេង (នៅពេលធ្វើដំណើរ និងពេលទៅដល់កន្លែងធ្វើការ)។ ខណៈពេលដែលបុរស ក៏ត្រូវបានគេជួញដូរដែរនោះ ក្មេងស្រី កុមារ និងយុវជនគឺជាជនរងគ្រោះភាគច្រើនបំផុត។

អ្នកធ្វើចំណាកស្រុក អាចការពារខ្លួនឯង កុំឱ្យក្លាយជាជនរងគ្រោះ ដោយការជួញដូរមនុស្សបានគឺត្រូវ៖
- ទទួលព័ត៌មានឱ្យបានច្រើនបំផុតតាមតែអាចធ្វើបាន អំពីដំណើរការធ្វើបំលាស់ទីទៅកាន់កន្លែងផ្សេង និងស្ថានភាពពិតប្រាកដ នៃកន្លែងការងារ មុនពេលសម្រេចចិត្តបំលាស់ទីទៅកាន់កន្លែងផ្សេង។
- យកឯកសារត្រឹមត្រូវ និងសមរម្យផ្សេងៗ សម្រាប់បំលាស់ទីទៅកាន់កន្លែងផ្សេងដោយសុវត្ថិភាព និងស្របច្បាប់
- រក្សាទំនាក់ទំនងជាមួយគ្រួសារ និងត្រូវមានព័ត៌មានរបស់បុគ្គល ឬភ្នាក់ងារដែលអាចជួយអ្នកបានក្នុងពេលមានវិបត្តិ។
- ឈ្លាសវៃ ប្រសិនបើមានការងារនៅកន្លែងថ្មីមានលក្ខខណ្ឌល្អដែលមិនគួរឱ្យជឿ វាប្រហែលជាការពិតថានឹងមានការជួញដូរ។
- គិតថាមនុស្សគ្រប់គ្នាមិនមែនសុទ្ធតែមានចេតនាល្អនោះទេ។ ការសន្យាមិនទាន់ល្អគ្រប់គ្រាន់នោះទេ។ ត្រួតពិនិត្យអ្វីគ្រប់យ៉ាងជាមុនសិន។

ទាំងនេះជាកត្តាសំខាន់ដែលត្រូវចងចាំ។ ប៉ុន្តែអ្នកត្រូវធ្វើអ្វី ប្រសិនបើអ្នកត្រូវបានគេជួញដូររួចទៅហើយ។ មនុស្សជាច្រើនបានយល់ថា វាមានភាពលំបាកក្នុងការគេចចេញពីការឃុំឃាំង ឬដោះស្រាយបញ្ហារបស់ពួកគេ។

◈ តើអ្នកមានដំបូន្មានសម្រាប់មនុស្សនៅក្នុងករណីសិក្សារបស់យើងដែរឬទេ ?

អនុញ្ញាតឱ្យសិស្សពិភាក្សារកចម្លើយ ដែលដោះស្រាយជាមួយគ្នា។

## បញ្ចប់មេរៀន

🕑 ២០ នាទី

យើងបានអានករណីសិក្សាជាច្រើន ដែលអ្វីៗមិនសូវដំណើរការល្អ។ ឥឡូវខ្ញុំចង់ឱ្យអ្នករិះរកមធ្យោបាយដើម្បីដោះស្រាយនៅពេលជួបជាមួយអ្នកជួញដូរមនុស្ស ។

សម្តែងជាអ្នកជួញដូរមនុស្ស ហើយចូលទៅជិតសិស្សម្នាក់ដោយនិយាយថា៖
*"សួស្តី ខ្ញុំត្រូវការមនុស្សប្រុសដែលមានកម្លាំងមាំមួនដើម្បីទៅធ្វើការនៅប្រទេសថៃ។ អ្នកនឹងទទួលបានប្រាក់ខែខ្ពស់។ សូមឱ្យប្រាក់ ៥០០ដុល្លារមកខ្ញុំជាមុនសិនដើម្បីរៀបចំទិដ្ឋាការ លិខិតឆ្លងដែន និងសំបុត្រជានា..."* សង្កេតមើលពីប្រតិកម្មរបស់សិស្ស។

ចំពោះបញ្ហាខាងលើនេះអ្នកត្រូវគិតពិចារណាឱ្យបានស៊ីជម្រៅ។ តើចំណុចសំខាន់អ្វីខ្លះ ដែលអ្នកត្រូវសួរ? តើចំណុចសំខាន់អ្វី ដែលអ្នកស្វែងយល់ទាក់ទងនឹងការជួញដូរមនុស្ស? តើអ្នកធ្វើដូចម្តេចដើម្បីបញ្ជាក់នូវភាពស្មោះ ត្រង់នៃមនុស្សដែលបបួលអ្នក ជាដៃគូ អ្នកអាចអនុវត្តវិធីខុសៗគ្នា ក្នុងការដោះស្រាយអំពីបញ្ហានេះ។ ម្នាក់ក្នុងចំណោមអ្នកទាំងពីរជាឈ្មួញជួញដូរមនុស្ស ដែលប្រើប្រាស់កលល្បិចដូចក្នុងករណីសិក្សា។ ម្នាក់ទៀតជាអ្នកភូមិ ដែលត្រូវធ្វើប្រតិកម្ម(ការឆ្លើយតប)ឱ្យបានល្អ។

អនុញ្ញាតឱ្យសិស្សអនុវត្តកិច្ចការនេះមួយសន្ទុះ និងពិនិត្យមើលឧទាហរណ៍ល្អរបស់គូនីមួយៗ។ អញ្ជើញសិស្សទាំងនោះឱ្យមកខាងមុខ និងបង្ហាញពីការសម្តែងរបស់ពួកគេដល់មិត្តរួមថ្នាក់ផ្សេងទៀត។

អរគុណដែលបានមករៀនថ្ងៃនេះ ខ្ញុំនឹងជួបអ្នកទាំងអស់គ្នាសាជាថ្មីនៅសប្តាហ៍ក្រោយ។

## សេចក្តីណែនាំគ្រូ

**១. ភាពខុសប្លែកគ្នារវាងការជួញដូរមនុស្ស និង ការឆ្លងដែនខុសច្បាប់**

នៅពេលដែលមនុស្សសម្រេចចិត្តបំលាស់ទីពីកន្លែងមួយទៅកន្លែងមួយដោយការស្ម័គ្រចិត្តនិងមានគោលបំណងផ្ទាល់ខ្លួន។ តែងតែពាក់ព័ន្ធជាមួយជម្រើស ចំណេះដឹង និងការ ពង្រឹងសេដ្ឋកិច្ច។ ការជួញដូរមនុស្ស និងការឆ្លងដែនខុសច្បាប់ ពាក់ព័ន្ធជាមួយបំលាស់ទីមិនទៀងទាត់របស់មនុស្សដែល តែងតែខ្វះការការពារ និង ងាយរងគ្រោះដោយការរំលោភបំពាន និងការកេងប្រវ័ញ្ចផ្សេងៗ។ ការជួញដូរមនុស្សគិត បញ្ចូលទាំងការបង្ខិតបង្ខំ ការប្រើកម្លាំងនិង/ឬការបោកប្រាស់ក្នុងបំណងកេងប្រវ័ញ្ចយកប្រយោជន៍ ចំណែកឯការឆ្លង ដែនខុសច្បាប់ប្រហែលជាមិនពាក់ព័ន្ធជាមួយការបង្ខិតបង្ខំ ឬការបោកប្រាស់នោះទេ។ ប្រភេទមនុស្សដែលធ្វើការឆ្លងដែនខុសច្បាប់គឺមិនមែនជាអ្នកក្រីក្រនោះទេ ព្រោះពួកគេត្រូវឱ្យប្រាក់មួយចំនួនធំទៅឱ្យ អ្នកនាំផ្លូវដើម្បីឆ្លងដែន។ ផ្ទុយមកវិញ ប្រភេទមនុស្សដែលត្រូវបានគេជួញដូរ គឺជាអ្នកមកពីគ្រួសារក្រីក្រ ជាញឹកញាប់គឺ អ្នកក្រីក្របំផុត និងគ្រួសារឬសហគមន៍ ដែលមិនសូវត្រូវបានគេយកចិត្តទុកដាក់។

**២. កត្តាជំរុញ និងកត្តាអូសទាញក្នុងការជួញដូរមនុស្ស**

មានកត្តាជាច្រើនដែលបានជំរុញមនុស្សឱ្យចាកចេញពីផ្ទះ និងបណ្តាលឱ្យពួកគេធ្លាក់ខ្លួនជាជនរងគ្រោះនៃការជួញដូរ។ ក្នុងចំណោមកត្តាជំរុញសាមញ្ញទាំងនោះមាន ៖

- ភាពក្រីក្រនៃគ្រួសារ
- ស្វែងរកការងារធ្វើ
- ការកើនឡើងនៃសម្ភារនិយម
- ជម្លោះគ្រួសារ ឬគ្រួសារបែកបាក់
- គ្រោះធម្មជាតិ ឬសង្គ្រាម
- ភាពអវិជ្ជា ភាពល្ងង់ខ្លៅ ការខ្វះការយល់ដឹងអំពីមនុស្ស
- ការខ្វះបណ្តាញជំនួយរបស់សហគមន៍
- ការរើសអើងចំពោះភេទ និង ឬជនជាតិ(ពូជសាសន៍)
- ការមិនស្មើភាពគ្នារវាងបុរស និងស្ត្រី ក្មេងប្រុស និងក្មេងស្រីក្នុងការអប់រំ និងការបណ្តុះបណ្តាល
- គោលនយោបាយអន្តោប្រវេសន៍ដោយជ្រើសរើសតាមភេទ។

ក្នុងចំណោមកត្តាអូសទាញសាមញ្ញទាំងនោះមាន៖

- តម្រូវការកម្លាំងពលកម្មថោកៗ និងអាចកេងប្រវ័ញ្ចបាន
- មធ្យោបាយធ្វើដំណើរ និងទំនាក់ទំនងមានភាពងាយស្រួល
- ការពង្រីកសេដ្ឋកិច្ចមិនផ្លូវការ និងទីផ្សារការងារមិនទៀងទាត់
- ការកើនឡើងនៃតម្រូវការមនុស្សស្រី និងក្មេងប្រុសតាមផ្ទះបនពេស្យា
- ការប្រឈមទាប តែទទួលបានគុណប្រយោជន៍ខ្ពស់ពីការជួញដូរមនុស្ស
- កម្សោយនៃការពង្រឹងច្បាប់ និងភាពពុករលួយនៃអាជ្ញាធរមានសមត្ថកិច្ច ។

*៣. តួអង្គសំខាន់ក្នុងការជួញដូរមនុស្ស*

ជាទូទៅឈ្មួញជួញដូរមនុស្សមិនមែនជាអ្នកប្លែកមុខសម្រាប់ជនរងគ្រោះទេ។ ជាញឹកញាប់ គឺនរណាម្នាក់ដែលជនរងគ្រោះបានស្គាល់យ៉ាងច្បាស់ ៖ មិត្តភក្តិ អ្នកជិតខាង ឬសូម្បីតែ បងប្អូន ដៃគូស្នេហាថ្មី និងប្តី/ប្រពន្ធ។ ពួកគេត្រូវបានប្រទះឃើញជាញឹកញយនៅក្នុងចំណោមក្រុមមនុស្សខាងក្រោម ៖

- ម្ចាស់រោងចក្រ ឬអ្នកជ្រើសរើសពលករយកទៅធ្វើការ
- ម្ចាស់បារ ក្លឹបកំសាន្ត មេបន
- អ្នកធ្វើការបញ្ជូនជនឆ្លងដែនខុសច្បាប់ត្រឡប់មកវិញ
- នរណាម្នាក់ដែលសន្យាថានឹងរៀបការ ឬសុំស្រឡាញ់អ្នក ប៉ុន្តែមានព័ត៌មានមិនច្បាស់លាស់
- នរណាម្នាក់ដែលសន្យាការងារនៅឯបរទេសដែលនឹងធ្វើឱ្យក្លាយជាអ្នកមានក្នុងពេលដ៏ខ្លី ។

*៤. វិធីសាស្ត្រ ល្បិចកល មធ្យោបាយ ដែលប្រើដោយឈ្មួញជួញដូរមនុស្ស*

- សន្យាថានឹងផ្តល់ការងារដ៏ល្អ
- សន្យាថាស្រឡាញ់ និងបង្កើតជីវិតថ្មីជាមួយអ្នក
- សន្យាថានឹងរៀបការ
- មកលេងបងប្អូនជីដូនមួយ
- សន្យាថានឹងផ្តល់ការអប់រំឱ្យបានកាន់តែខ្ពស់កាន់តែប្រសើរ
- សន្យាថានឹងផ្តល់អាហារឱ្យបានគ្រប់គ្រាន់ ឆ្ងាញ់ពិសា គ្រឿងអលង្ការស្អាត ល្អៗ
- គំរាមកំហែង
- ចាប់ពង្រត់
- ដាក់ថ្នាំសណ្តំ ។

៥. ការជួញដូរមនុស្ស និងការកេងប្រវ័ញ្ចកម្លាំងពលកម្ម

*ស្ត្រី និងកុមារត្រូវបានគេជួញដូរមិនត្រឹមតែដើម្បីធ្វើជាពេស្យាចារនោះទេ គឺដើម្បីកេងប្រវ័ញ្ចកម្លាំងពលកម្មផងដែរដែលមានដូចជា ៖*

- ការងាររោងចក្រ
- ការងារតាមផ្ទះ
- ការងារតាមកសិដ្ឋាន
- ការងារនៅក្នុងផ្នែកកំសាន្ត រួមបញ្ចូលទាំងភាពអាសអាភាស
- ពលកម្មក្នុងសណ្ឋាគារ ក្លឹបកំសាន្ត
- ការងារនៅកន្លែងម៉ាស្សា និងបារ ខារ៉ាអូខេ
- ការបង្ខំឱ្យរៀបការ

**១. ភាពខុសប្លែកគ្នារវាងការជួញដូរមនុស្ស ការឆ្លងដែនខុសច្បាប់**

ការជួញដូរមនុស្ស និងការរត់ពន្ធពាក់ព័ន្ធជាមួយការបំលាស់ទី ដោយមិនទៀងទាត់របស់មនុស្សដែលតែងតែខ្វះការការពារនិងងាយរងគ្រោះដោយការរំលោភបំពាន និងការកេងប្រវ័ញ្ចផ្សេងៗ។ ការជួញដូរមនុស្សគិតបញ្ចូលទាំង**ការបង្ខិតបង្ខំ ការប្រើកម្លាំង និង/ឬការបោកប្រាស់ក្នុងបំណងកេងប្រវ័ញ្ចយកប្រយោជន៍** ចំណែកឯការឆ្លងដែនខុសច្បាប់ប្រហែលជាមិនពាក់ព័ន្ធជាមួយការបង្ខិតបង្ខំ ឬការបោកប្រាស់នោះទេ។ ប្រភេទមនុស្សដែលឆ្លងដែនខុសច្បាប់គឺមិនមែនជាអ្នកក្រីក្រនោះទេ ព្រោះពួកគេត្រូវប្រាក់មួយចំនួនធំទៅឱ្យអ្នកនាំផ្លូវដើម្បីឆ្លងដែន។ ផ្ទុយមកវិញ ប្រភេទមនុស្សដែលត្រូវបានគេជួញដូរគឺជាអ្នកមកពីគ្រួសារក្រីក្រ ជាញឹកញាប់គឺអ្នកក្រីក្របំផុត ហើយគ្រួសារ និងសហគមន៍មិនសូវយកចិត្តទុកដាក់ចំពោះពួកគេ។

**២. កត្តាជំរុញ និងកត្តាអូសទាញក្នុងការជួញដូរមនុស្ស**

មានកត្តាជាច្រើនដែលបានជំរុញមនុស្សឱ្យចាកចេញពីផ្ទះ និងបណ្ដាលឱ្យពួកគេធ្លាក់ខ្លួនជាជនរងគ្រោះនៃការជួញដូរ។

ក្នុងចំណោមកត្តា**ជំរុញ**សាមញ្ញទាំងនោះមាន៖



- ភាពក្រីក្រនៃគ្រួសារ
- ស្វែងរកការងារធ្វើ
- ការកើនឡើងនៃសម្ភារៈនិយម
- ជម្លោះគ្រួសារ ឬគ្រួសារបែកបាក់
- គ្រោះធម្មជាតិ ឬសង្គ្រាម
- ភាពអវិជ្ជា ភាពល្ងង់ខ្លៅ ការខ្វះការយល់ដឹងអំពីមនុស្ស
- ការខ្វះបណ្ដាញជំនួយរបស់សហគមន៍
- ការរើសអើងចំពោះភេទ និង/ឬជនជាតិ(ពូជសាសន៍)
- ការមិនស្មើភាពគ្នារវាងបុរស និងស្ត្រី ក្មេងប្រុស និងក្មេងស្រីក្នុងការអប់រំ និងការបណ្ដុះបណ្ដាល
- គោលនយោបាយអន្តោប្រវេសន៍ដោយជ្រើសរើសតាមភេទ

ក្នុងចំណោមកត្តា**អូសទាញ**សាមញ្ញទាំងនោះមាន ៖

- តម្រូវការកម្លាំងពលកម្មថោកៗ និងអាចកេងប្រវ័ញ្ចបាន
- ងាយស្រួល និងអាចធ្វើដំណើរ និងទំនាក់ទំនងបានប្រសើរជាង
- ការពង្រីកសេដ្ឋកិច្ចមិនផ្លូវការ និងទីផ្សារការងារមិនទៀងទាត់
- ការកើនឡើងនៃតម្រូវការមនុស្សស្រី និងក្មេងប្រុសនៅតាម ផ្ទះបនពេស្យា
- ការប្រឈមទាប តែទទួលបានគុណប្រយោជន៍ខ្ពស់ពីការជួញដូរមនុស្ស
- កម្សោយនៃការពង្រឹងច្បាប់ និងភាពពុករលួយនៃអាជ្ញាធរមានសមត្ថកិច្ច

### ៣. តួអង្គសំខាន់ក្នុងការជួញដូរមនុស្ស



ជាទូទៅ ឈ្មួញជួញដូរមនុស្សមិនមែនជាអ្នកប្លែកមុខសម្រាប់ជនរងគ្រោះទេ។ ជាញឹកញាប់គឺនរណាម្នាក់ដែលជនរងគ្រោះបានស្គាល់យ៉ាងច្បាស់៖ មិត្តភក្តិ អ្នកជិតខាង ឬសូម្បីតែបងប្អូន ដៃគូស្នេហាថ្មី និងប្ដី/ប្រពន្ធ។ ពួកគេត្រូវបានប្រទះឃើញជាញឹកញយនៅក្នុងចំណោមក្រុមមនុស្សខាងក្រោម៖

- ម្ចាស់រោងចក្រ ឬអ្នកជ្រើសរើសពលករយកទៅធ្វើការ
- ម្ចាស់បារ/ក្លឹបកំសាន្ត/មេបន
- អ្នកធ្វើការបញ្ជូនជនចំណាកស្រុកត្រឡប់មកវិញ
- នរណាម្នាក់ដែលសន្យាថានឹងរៀបការ ឬសុំស្រលាញ់អ្នក ប៉ុន្តែមានព័ត៌មានមិនច្បាស់លាស់
- នរណាម្នាក់ដែលសន្យាការងារនៅឯបរទេស ហើយនឹងធ្វើឱ្យក្លាយជាអ្នកមានក្នុងពេលដ៏ខ្លី

### ៤. វិធីសាស្ត្រ ល្បិចកល/មធ្យោបាយ ដែលប្រើដោយឈ្មួញជួញដូរមនុស្ស

- សន្យាថានឹងផ្ដល់ការងារដ៏ល្អ
- សន្យាថាស្រលាញ់ និងបង្កើតជីវិតថ្មីជាមួយអ្នក
- សន្យាថានឹងរៀបការ
- មកលេងបងប្អូនជីដូនមួយ
- សន្យាថានឹងផ្ដល់ការអប់រំឱ្យបានកាន់តែខ្ពស់/កាន់តែប្រសើរ
- សន្យាថានឹងផ្ដល់អាហារឱ្យបានគ្រប់គ្រាន់/ឆ្ងាញ់ពិសា គ្រឿងអលង្ការស្អាត/ល្អៗ
- គំរាមកំហែង
- ចាប់ពង្រត់
- ដាក់ថ្នាំសណ្ដំ

### ៥. ការជួញដូរមនុស្ស និងការកេងប្រវ័ញ្ចកម្លាំងពលកម្ម

ស្ត្រី និងកុមារត្រូវបានគេជួញដូរមិនត្រឹមតែដើម្បីធ្វើជាពេស្យាចារនោះទេ គឺដើម្បីកេងប្រវ័ញ្ចកម្លាំងពលកម្មផងដែរ ដែលមានដូចជា៖



- ការងាររោងចក្រ
- ការងារតាមផ្ទះ
- ការងារតាមកសិដ្ឋាន
- ពលកម្មក្នុងសណ្ឋាគារ/ក្លឹបកំសាន្ត
- ធ្វើការនៅកន្លែងម៉ាស្សា និងបារ/ខារ៉ាអូខេ
- បង្ខំឱ្យរៀបការ
- ធ្វើការនៅក្នុងផ្នែកកំសាន្ត រួមបញ្ចូលទាំងភាពអាសអាភាស

**១.** នៅឯចំណតរថយន្ត បុរស ឬស្ត្រីដ៏ស្រស់ស្អាតម្នាក់ស្ម័គ្រចិត្តនាំអ្នកធ្វើដំណើរទៅរកការងារល្អមួយ។

---

**២.** អ្នកជិតខាងម្នាក់បានត្រឡប់មកផ្ទះវិញបន្ទាប់ពីការចាកចេញអស់រយៈពេលជាច្រើនឆ្នាំ។ នាងច្បាស់ជាមានការងារល្អ បើពិចារណាតាមសម្លៀកបំពាក់ ក្រវិលមាស ខ្សែក នាឡិកាមានតម្លៃ និងទូរស័ព្ទទំនើបរបស់នាង។ នាងនិយាយប្រាប់អំពីការងារនៅក្នុងទីក្រុងថា ពិតជាទទួលបានប្រាក់ចំណូលយ៉ាងច្រើនមិនគួរឱ្យជឿ។ នាងបន្ថែមថា នាងជាតំណាងឱ្យថៅកែក្នុងទីក្រុងភ្នំពេញ ហើយមានមនុស្សជាច្រើននៅក្នុងភូមិផ្សេងៗបានសម្រេចចិត្តទៅធ្វើការរួចហើយ។ មនុស្សវ័យក្មេងដែលចាប់អារម្មណ៍ត្រូវប្រញាប់រួសរាន់ឡើង ព្រោះចំនួនការងារមានកំណត់។

---

**៣.** ស្ត្រីម្នាក់មកពីភូមិផ្សេងដែលគេស្គាល់ថាជាមេអណ្តើក។ នាងមកក្នុងភូមិដើម្បីស្វែងរកប្រពន្ធឱ្យបុរសម្នាក់ដែលទើបតែមកពីបរទេស។ នាងនិយាយថា បុរសនោះពិតជាល្អណាស់។ គាត់សន្យាថានឹងឱ្យថ្លៃទឹកដោះទៅគ្រួសារ និងថែរក្សាប្រពន្ធរបស់គាត់ឱ្យបានល្អ។

---

**៤.** បុរសម្នាក់មកកាន់ទីក្រុង និងបាននិយាយថា គាត់ស្វែងរកកម្មករសាងសង់ជាច្រើននាក់ឱ្យទៅធ្វើការនៅប្រទេសអភិវឌ្ឍន៍។ អ្នកដែលចាប់អារម្មណ៍ត្រូវកក់ប្រាក់ដើម្បីធានាបានការងារ។ ដំណើរការចាំបាច់នានាក្នុងការធ្វើលិខិតឆ្លងដែន លិខិតអន្តោប្រវេសន៍ សញ្ញាប័ត្រជំនាញ និងការពិនិត្យសុខភាពនឹងត្រូវរ៉ាប់រងដោយភ្នាក់ងាររបស់គាត់។ មានមនុស្សជាច្រើនបានកក់ប្រាក់ ប៉ុន្តែមិនឃើញមានអ្វីកើតឡើងសោះ។

---

**៥.** ភ្នាក់ងាររៀបអាពាហ៍ពិពាហ៍តំណាងដោយស្ត្រីដែលរៀបការជាមួយជនបរទេសម្នាក់បានទទួលពាក្យសុំរៀបការជាមួយបុរសបរទេស។ ការដាក់ពាក្យត្រូវចំណាយលុយ និងត្រូវធ្វើដំណើរទៅបរទេសដើម្បីជួបជាមួយបុរសគូអនាគតនោះ។

---

**៦.** "ក" មានអាយុ១៦ឆ្នាំ ហើយត្រូវបានគេសន្យាថាឱ្យធ្វើការជាអ្នកបម្រើក្នុងគ្រួសារអ្នកមានមួយក្នុងទីក្រុងភ្នំពេញ។ គ្រួសារនោះពិតជាអ្នកមានខ្លាំងណាស់។ ការធ្វើដំណើរទៅកាន់គ្រួសារនោះមិនមានអ្វីកើតឡើងទេ តែពេលដែល "ក" ចូលដល់បរិវេណនៃគ្រួសារនោះ "ក" ចាប់អារម្មណ៍ដឹងថា នាងត្រូវធ្វើការងារលើសពីការបោសសម្អាតផ្ទះ ដែលរួមមាននាំពាក្យ និងយកវត្ថុផ្សេងៗទៅឱ្យមនុស្សប្រុសក្នុងផ្ទះ។ នាងមិនចូលចិត្តធ្វើការបែបនេះទេ ហើយមានអារម្មណ៍មិនស្មើភាព ប៉ុន្តែនាងគ្មានជម្រើសទេ។ "ក" មិនត្រូវបានអនុញ្ញាតឱ្យចាកចេញពីផ្ទះឡើយ។ ភរិយាម្ចាស់ផ្ទះនោះស្អប់នាង និងចូលចិត្តវាយដំនាងទៀតផង។

៧. ក្មេងប្រុសអាយុ ១២ឆ្នាំម្នាក់ មានឈ្មោះថា "ខ" មកជាមួយក្មេងប្រុសដទៃទៀតដើម្បីធ្វើការនៅរោងចក្រ។ "ខ" និងក្រុមគ្រួសាររបស់ក្មេងប្រុសនោះត្រូវបានគេប្រាប់ថា "ខ" នឹងធ្វើការនៅក្នុងរោងចក្រដែលមានថៅកែចិត្តល្អម្នាក់។ "ខ" នឹងមានអាហារគ្រប់គ្រាន់នៅក្នុងរោងចក្រ ហើយនឹងមានកន្លែងស្នាក់នៅដោយឥតគិតថ្លៃ ព្រមទាំងមានប្រាក់គ្រប់គ្រាន់ដើម្បីផ្ញើរមកផ្ទះ។ រយៈពេល ៦ខែកន្លងមកហើយដែល "ខ" និងមិត្តរបស់គាត់មិនដែលទទួលបានប្រាក់ខែនោះទេ ទោះបីជាពួកគេមានអាហារគ្រប់គ្រាន់ដើម្បីបរិភោគ និងមានកន្លែងស្នាក់ជាប់នឹងកន្លែងធ្វើការរបស់ពួកគេក៏ដោយ។ នៅពេលដែល "ខ" និងអ្នកដទៃទៀតសួរអំពីប្រាក់ខែ អ្នកគ្រប់គ្រងតែងតែនិយាយថា ថៅកែបានចំណាយលុយយ៉ាងច្រើនដើម្បីនាំពួកគេមករោងចក្រនេះ ដូច្នេះពួកគេត្រូវធ្វើការដើម្បីសងប្រាក់បំណុលទាំងអស់នោះសិន។ "ខ" មិនដឹងថាតើគាត់ជំពាក់ប្រាក់ថៅកែប៉ុន្មាននោះទេ។ អ្នកគ្រប់គ្រងរោងចក្រឱ្យ "ខ" និងមិត្តរបស់គាត់ធ្វើការ ១០-១២ម៉ោងជារៀងរាល់ថ្ងៃ ហើយពេលខ្លះអាចពី ១៤-១៦ម៉ោងក្នុងមួយថ្ងៃ។ គ្មានទីធ្លាសម្រាប់លេង និងកន្លែងដើរកំសាន្តទេ។ ដូចក្មេងៗដទៃទៀតដែលធ្វើការនៅទីនោះដែរ "ខ" និងមិត្តភក្តិរបស់គាត់មិនត្រូវបានគេអនុញ្ញាតឱ្យទៅខាងក្រៅរោងចក្រនោះទេ។ "ខ" នឹកគ្រួសាររបស់គាត់ ព្រមទាំងខ្វាយខ្វល់ថា គ្រួសាររបស់គាត់ច្បាស់ជាបារម្ភអំពីគាត់។

✂-----------------------------------------------------------

៨. "គ" ទៅបរទេសដើម្បីរៀបការជាមួយបុរសម្នាក់ដែលរស់នៅក្នុងប្រទេសជិតខាងហើយមានកម្រិតជីវភាពរស់នៅខ្ពស់ជាង។ មួយសប្តាហ៍បន្ទាប់ពីការរៀបការ នាងត្រូវបានគេប្រាប់ថា ពួកគេនឹងទៅប្រទេសអ្នកមាន។ "គ" ត្រូវបានគេផ្តល់ឱ្យនូវលិខិតឆ្លងដែនថ្មី(លិខិតឆ្លងដែនក្លែងក្លាយ)ដែលបញ្ជាក់ថានាងមានសញ្ជាតិដូចប្តីរបស់នាង ពីព្រោះប្តីនាងនិយាយថា នាងមិនមានឱកាសទទួលបានទិដ្ឋាការដើម្បីធ្វើដំណើរទៅកាន់ប្រទេសអ្នកមាន តាមរយៈលិខិតឆ្លងដែនចាស់របស់នាងនោះទេ។ ប្តីរបស់នាងធ្វើដំណើរទៅជាមួយនាង។ នៅពេលដែលមកដល់ប្រទេសថ្មីភ្លាមៗ ប្តីរបស់នាងបានបាត់ខ្លួន ហើយលិខិតឆ្លងដែនរបស់នាងត្រូវបានរក្សាទុកដោយថៅកែម្នាក់។ ថៅកែនោះបានបង្ខំ "គ"ឱ្យ "បម្រើ" ភ្ញៀវនៅក្នុងកន្លែងលក់ទឹកតែរបស់គាត់។ "គ" មិនអាចត្រឡប់ទៅផ្ទះវិញបានឡើយ ព្រោះនាងមិនមានទាំងលិខិតឆ្លងដែន ថ្មី ឬចាស់របស់នាងឡើយ។

✂-----------------------------------------------------------

៩. "ឃ" រស់នៅក្នុងទីក្រុងជាមួយឪពុកម្តាយ និងបងប្អូនប្រុសស្រីរបស់នាង។ នាងជួយកិច្ចការឪពុកម្តាយរបស់នាងដែលជាអ្នកលក់បាយតាមចិញ្ចើមផ្លូវ។ នាងបានឈប់រៀនតាំងពីពេលដែលនាងមានអាយុ ១៤ឆ្នាំ ដោយសារតែនាងមិនចាប់អារម្មណ៍ក្នុងការសិក្សា។ នាងចូលទៅរាំកំសាន្ត ប្រសិនបើនាងមានប្រាក់ ហើយនាងសង្ឃឹមថានឹងមានស្នេហាជាមួយអ្នកមានម្នាក់។ នៅយប់មួយ នាងបានជួបនឹងបុរសក្មេងសង្ហាម្នាក់ដែលមកពីប្រទេសជិតខាង ហើយនាងក៏បានស្រឡាញ់បុរសម្នាក់នោះ។ ក្រោយពេលការណាត់ជួបជាច្រើនខែ បុរសម្នាក់នោះចង់យកនាងទៅស្រុកកំណើតគាត់ដែលជាកំពង់ផែសមុទ្រដ៏មមាញឹកមួយ។ ក្រោយពេលមកដល់ភ្លាមៗ វាប្រែក្លាយជា គាត់មិនមានការងារធ្វើ ឬគ្រួសារអ្វីឡើយ។ ទោះជាយ៉ាងណា "ឃ" និងមិត្តប្រុសរបស់នាងរស់នៅជាមួយគ្នាយ៉ាងសប្បាយចិត្តដោយជួលបន្ទប់ថោកមួយរស់នៅ។ បន្ទាប់មក មិត្តប្រុសរបស់នាងក៏បានសុំឱ្យនាងរកប្រាក់ដោយការរួមភេទជាមួយបុរសដទៃ។

# មេរៀនទី ៣: តើអ្នកមកពីណា?

រយៈពេលបង្រៀនៈ ១ម៉ោង ៣០នាទី

## ☑ ការត្រៀមលក្ខណៈ

មុនពេលបង្រៀនលោកគ្រូ អ្នកគ្រូត្រូវ

- អាន និងពិនិត្យមេរៀនដោយហ្មត់ចត់ និងធ្វើកិច្ចតែងការបង្រៀន
- ពិនិត្យមើលឯកសារសិស្ស ដើម្បីចង់ដឹងថាតើមានព័ត៌មាន និងសំណួរ សម្រាប់សកម្មភាពត្រូវនឹងការបង្រៀនដែរឬទេ
- សរសេរសំណួរលើក្ដារខៀន ឬនៅលើក្រដាសផ្ទាំងធំ ប្រសិនបើសិស្សមានឯកសារ គេអាចមើលព័ត៌មាននេះនៅក្នុងសៀវភៅរបស់គេបាន
- មើលកាលវិភាគប្រចាំថ្ងៃ
- រៀបចំបន្ទប់រៀន (តុ កៅអី ក្ដារខៀន...)។

## សម្ភារឧបទេស ធនធានដែលត្រូវការ

- ក្រដាសរ៉ាម
- ផ្ទាំងរូបភាពនៃប្រទេសកម្ពុជា
- ក្រដាសតូចៗទុកបិទនៅលើផ្ទាំងរូបភាព
- ឯកសារ ៣.១ និង ៣.២ សម្រាប់សិស្ស ឡេវអារពណ៌ គ្រាប់ឡុកឡាក់។

## ☼ វត្ថុបំណង

នៅពេលរៀនមេរៀននេះចប់ សិស្សនឹងអាច ៖

- ចែករំលែកបទពិសោធន៍នៃមូលហេតុដែលមនុស្សធ្វើចំណាកស្រុក។
- បែងចែក និងបង្កើតបញ្ជីនៃគុណប្រយោជន៍ និងគ្រោះថ្នាក់នៃការធ្វើចំណាកស្រុក។

## ចំណងជើងមេរៀនទី ៣: តើអ្នកមកពីណា? ៤០ នាទី

### សេចក្ដីផ្ដើម

ស្វាគមន៍មកកាន់ថ្នាក់រៀននេះ។ យើងនឹងសិក្សាអំពីប្រធានបទសំខាន់ៗជាច្រើន ហើយយើងនឹងធ្វើសកម្មភាពជាមួយគ្នា។ បញ្ហាដំបូងដែលខ្ញុំចង់ឱ្យអ្នកធ្វើគឺយកក្រដាសរ៉ាម ពណ៌សមួយ សន្លឹក។

គ្រូចែកឱ្យសិស្សគ្រប់គ្នានូវក្រដាសរ៉ាម ពណ៌សមួយសន្លឹកម្នាក់ៗ

លំហាត់បន្ទាប់គឺគូរផែនទីនៃប្រទេសកម្ពុជាក្នុងរយៈពេល៥នាទី។ អ្នកមិនអាចប្រើឯកសារជំនួយទេ គឺអ្នកត្រូវព្យាយាមគូរតាមការចងចាំរបស់អ្នក។ វាជាល្បែងកំសាន្តមួយដូច្នេះ វាគ្មានបញ្ហាអ្វីទេប្រសិនបើអ្នកមានកំហុស។ ចូរព្យាយាម ប្រាប់ឈ្មោះខេត្ត ទន្លេ និងទីក្រុងផ្សេងៗ។ រយៈពេល ៥នាទីក្រោយ យើងនឹងធ្វើការចែករំលែក។

សកម្មភាពគ្រូអនុវត្ត

ទុកពេល ៥នាទី ឱ្យសិស្សគូរដោយខ្លួនឯង។ រកមើលឧទាហរណ៍ល្អដែលអ្នកអាចបង្ហាញនៅពេលបន្ទាប់។ អ្នកអាចបង្កើតជាក្រុមដែលមានសមាជិក៤នាក់ ហើយចែករំលែកកិច្ចការគ្នាទៅវិញទៅមក។ បន្ទាប់ពីនេះ អ្នកអាចកែលម្អគំនូររបស់អ្នកផ្ទាល់។ សិស្សបង្កើតជាក្រុមតូចៗ ហើយរៀនពីគ្នាទៅវិញទៅមក។ ក្រោយពេលអ្នកកត់សម្គាល់ថាសិស្សភាគច្រើនបានបញ្ចប់កិច្ចការរបស់ពួកគេ អ្នកគ្រូវសរសេរសំណួរខាងក្រោមលើក្ដារខៀន។

១. តើអ្នកមានបងប្អូនកំពុងរស់នៅកន្លែងផ្សេងៗ នៅប្រទេសកម្ពុជាដែរឬទេ?
២. តើមនុស្សណាខ្លះដែលបានធ្វើបំលាស់ទីទៅកន្លែងផ្សេង? ហេតុអ្វី?

បិទផ្ទាំងផែនទីនៃប្រទេសកម្ពុជានៅលើជញ្ជាំង ហើយឱ្យសិស្សគ្រប់គ្នាសរសេរឈ្មោះមនុស្សដែលបានធ្វើបំលាស់ទី និងមូលហេតុនៅលើក្រដាសសតូចមួយ។ បន្ទាប់ពីនេះ ពួកគេអាចបិទក្រដាសតូចនៅលើផ្ទាំងផែនទីនេះ។ ប្រសិនបើអ្នកមិនមានផែនទីនៃប្រទេសកម្ពុជា អ្នកគ្រាន់តែគូរទម្រង់តំណាងផែនទីនៅលើក្តារខៀនក៏បាន។

សិស្សជាច្រើន ដែលមានបងប្អូន ឬមិត្តភក្តិបានធ្វើបំលាស់ទីទៅកាន់តំបន់ ឬ ទីក្រុងផ្សេងៗ។ ការធ្វើរបៀបនេះផ្តល់នូវមូលហេតុល្អៗជាច្រើន (អានមូលហេតុមួយចំនួនដែល សិស្សបានសរសេរនៅលើក្រដាសតូច)។

តើល្បះ "ការធ្វើបំលាស់ទីទៅកាន់កន្លែងផ្សេង" មានន័យដូចម្តេច?

"ការធ្វើបំលាស់ទីទៅកាន់កន្លែងផ្សេង គឺជាការចាកចេញពីស្រុកកំណើតទៅតាំងទីលំនៅថ្មី ។ ការសមច្រេចិត្តចាកចេញពីស្រុកកំណើត អាច បណ្តាលមកពីកត្តាគ្រួសារ ការអប់រំ និងការស្វែងរកការងារធ្វើដើម្បីចិញ្ចឹមជីវិត ។ វាជាការសម្រេចចិត្តមួយ ដែលធ្វើឡើង ដោយបុគ្គលនោះគ្មានការបារម្ភ គ្មានការគាបសង្កត់ ឬការបង្ខិតបង្ខំក្នុងរូបភាពណាមួយឡើយ។ បំលាស់ទីទៅកាន់កន្លែងផ្សេងអាចមានរយៈពេលខ្លី នៅពេលដែលបុគ្គលនោះត្រឡប់មកផ្ទះវិញ ឬរយៈពេលវែង ប្រសិនបើការចាកចេញនោះមានលក្ខណៈជា អចិន្ត្រៃយ៍"។

## សកម្មភាពសំខាន់។

⌚ ៤០ នាទី

ដើម្បីទទួលបានគំនិតកាន់តែល្អប្រសើរអំពីបញ្ហាទាក់ទងនឹងការធ្វើបំលាស់ទីទៅកាន់កន្លែងផ្សេង យើងនឹងលេងល្បែងកំសាន្តមួយ។ វាមានឈ្មោះថា "ល្បែងជណ្តើរ និងបំលាស់ទីទៅកាន់កន្លែងផ្សេងរបស់ពស់"។ តាមរយៈការលេងល្បែងនេះ យើងអាចសិក្សាអំពីគុណ ប្រយោជន៍ និងគ្រោះថ្នាក់ផ្សេងៗ។ អ្នកត្រូវការឯកសារ ៣.១ និង ៣.២ សម្រាប់សិស្សក្នុងការលេងល្បែងនេះ។ ល្បែង អាចលេងជាក្រុម ដែលមានសមាជិក ៥ឬ៦នាក់។

**វិន័យ៖**

- បុគ្គលម្នាក់ៗយកឡេអារពណ៌មួយ ហើយដាក់វានៅក្នុងប្រអប់ដំបូង (លេខ១)
- លំដាប់នៃការចាប់ផ្តើមគឺត្រូវកំណត់ដោយអាយុ។ អ្នកដែលមានអាយុក្មេងជាងគេចាប់ផ្តើមមុន។ បន្ទាប់មកអ្នកក្មេងជាងគេទីពីរ ហើយធ្វើបន្តរហូតដល់គ្រប់គ្នាដឹងថាខ្លួននៅលេខរៀងទីប៉ុន្មានដែលត្រូវចាប់ផ្តើម
- អ្នកចាប់ផ្តើមដំបូងបង្វិលគ្រាប់ឡុកឡាក់ ហើយដើរឡេអាររបស់ខ្លួន តាមលេខគ្រាប់ឡុកឡាក់ដែលគេបង្វិលបាន។ ឧទាៈ ចេញលេខ ៣ ដើរបាន ៣ជំហាន។ បន្ទាប់ពីនោះ អ្នកបន្ទាប់អាចបង្វិលគ្រាប់ឡុកឡាក់ម្តង
- ប្រសិនបើដើរដល់ប្រអប់ដែលមានក្បាលពស់ អ្នកត្រូវធ្លាក់ទៅក្នុងប្រអប់កន្ទុយពស់វិញ (ប្រៀបដូចជាគេត្រូវបានលេបដោយពស់)
- ប្រសិនបើដើរដល់ប្រអប់ដែលមានជើងជណ្តើរ អ្នកត្រូវឡើងទៅចុងនៃជណ្តើរ ហើយចាប់ផ្តើមពីទីនោះនៅវេនបន្ទាប់
- ប្រសិនបើដើរដល់ប្រអប់ដែលគ្មានកន្ទុយពស់ ឬជណ្តើរទេ អ្នកគ្រាន់តែនៅទីនោះហើយរង់ចាំរហូតដល់វេនបន្ទាប់របស់អ្នក។
- គោលបំណងគឺទៅដល់ចុងបញ្ចប់នៃល្បែងកំសាន្ត (ប្រអប់លេខ ៦០)។

ចែកក្រុមនីមួយៗនូវឯកសារសម្រាប់សិស្ស ឡេវអារ និងគ្រាប់ឡុកឡាក់មួយ។

ខណៈពេលកំពុងលេងល្បែងនេះ ខ្ញុំចង់ឱ្យអ្នកកត់ត្រានូវដំណើររបស់អ្នក។ អ្នកអាចព្យាយាម ចង់ចាំវា ឬកត់វានៅក្នុងសៀវភៅដើម្បីជួយឱ្យចាំបានល្អ។ បន្ទាប់ពីល្បែងនេះ ខ្ញុំត្រូវការបទពិសោធន៍របស់អ្នក។

អនុញ្ញាតឱ្យសិស្សលេងល្បែងកំសាន្តនេះរយៈពេល ២០ ឬ៣០នាទី។ បន្ទាប់ពីនេះ សួរសិស្សមួយចំនួនអំពីបទពិសោធន៍របស់ពួកគេ។

- តើអ្នកបានជួបប្រទះស្ថានភាពណាមួយ?

តើទាំងនោះជាស្ថានភាពដែលគ្មានការរំពឹងទុកមែនទេ?

តើអ្នកនឹងធ្វើបែបណា ប្រសិនបើស្ថានភាពទាំងនោះកើតឡើងនៅក្នុងជីវិតពិតប្រាកដរបស់អ្នក?

នៅក្នុងក្រុមដូចគ្នាដែលអ្នកបានលេងល្បែងកំសាន្ត ខ្ញុំចង់ឱ្យអ្នកត្រិះរិះពិចារណារកគំនិតថ្មីៗ អំពីគុណប្រយោជន៍ និងគ្រោះថ្នាក់នៃការធ្វើបំលាស់ទីទៅកាន់កន្លែងផ្សេង អ្នកអាចបែងចែកវាតាមផ្នែក។ (នេះអាចដូចនឹងតារាងនៅក្នុងសេចក្តីណែនាំគ្រូ)នៅពេលធ្វើ ការក្នុងក្រុមវាមានសារសំខាន់ ដែលអ្នកទាំងអស់ចូលរួមក្នុងការសន្ទនា។ សម្រាប់កិច្ចការនេះ យើងអាចជ្រើសរើសអ្នកដឹកនាំក្រុមម្នាក់ ដែលត្រូវយកចិត្តទុកដាក់លើបញ្ហានេះ។ នៅក្នុងថ្នាក់របស់យើង អ្នកគ្រប់គ្នាអាចក្លាយជាអ្នកដឹកនាំក្រុម ដូច្នេះយើងនឹងជ្រើសរើសអ្នកដឹកនាំខុសៗគ្នានៅក្នុងមេរៀននីមួយៗ។ ថ្ងៃនេះ យើងនឹងជ្រើសរើសអ្នកដែល ខ្ពស់ជាងគេជាអ្នកដឹកនាំក្រុម។

គេអាចឱ្យសិស្សដទៃចូលរួមបានដោយការសួរសំណួរដូចជា៖

តើអ្នកគិតយ៉ាងដូចម្តេចអំពីបញ្ហានេះ?

តើអ្នកដឹងអ្វីផ្សេងទៀតដែលអាចបន្ថែមបានដែរឬទេ?

នៅចុងបញ្ចប់នៃសកម្មភាពត្រិះរិះពិចារណា អ្នកមានបញ្ជីមួយដែលធ្វើឡើងដោយ អ្នកទាំងអស់គ្នា។

ទុកពេល ១០ ឬ ១៥នាទី ឱ្យសិស្សធ្វើកិច្ចការនេះ។

ប្រហែលជាអ្នកបានកត់សម្គាល់រួចហើយថា យើងបានចែករំលែកគំនិត និងចំណេះដឹងជាច្រើនអំពីប្រធានបទនេះរួចហើយ។ យើងនឹងបន្តការអង្កេតរបស់យើងអំពីការធ្វើបំលាស់ទីទៅកាន់កន្លែងផ្សេងដោយ សុវត្ថិភាព ដោយការសួរមនុស្សអំពីបញ្ហានេះ ។ តាមរយៈចម្លើយ យើងប្រមូលផ្តុំបានព័ត៌មានពីប្រភពផ្សេងៗ។ នេះជាការសំខាន់ដើម្បីប្រៀបធៀបព័ត៌មាន និងជ្រើសរើសបញ្ហា ដែលសំខាន់បំផុត។



**បញ្ចប់មេរៀន** ១០ នាទី

នៅសប្តាហ៍បន្ទាប់ យើងនឹងសិក្សាបន្ថែមទៀតអំពី ការធ្វើបំលាស់ទីទៅកាន់កន្លែងផ្សេងមានសុវត្ថិភាព និងការធ្វើបំលាស់ទីទៅកាន់កន្លែងផ្សេងគ្មានសុវត្ថិភាព។ សម្រាប់គោលបំណងនេះ ខ្ញុំចង់ឱ្យអ្នករៀបចំការស្ទង់មតិមួយនៅក្នុងភូមិ។ អ្នកអាចរៀបចំជាការសម្ភាសតូចៗ សម្រាប់មនុស្ស ៥នាក់ដែលត្រូវការសួរពួកគេ អំពីការធ្វើបំលាស់ទីទៅកាន់កន្លែងផ្សេងមានសុវត្ថិភាព និងការធ្វើបំលាស់ទីទៅកាន់កន្លែងផ្សេងគ្មានសុវត្ថិភាព។ វាជាការល្អបំផុត ប្រសិនបើអ្នកធ្វើកិច្ចការនេះជាដៃគូ។ ក្នុងរយៈពេល១៥នាទីខាងមុខនេះ អ្នកអាចរៀបចំកម្រងសំណួរដែលអ្នកចង់សួរ។ ចូរចងចាំ អ្នកចង់ដឹងអំពីចំណេះដឹង និងបទពិសោធន៍របស់ពួកគេ អំពីប្រធានបទនេះ។ សំណួរ ដែលល្អអាចចាប់ផ្តើមជាមួយពាក្យ ពេលណា ហេតុអ្វី នៅឯណា អ្វី នរណា ឬ របៀបណា...។

អនុញ្ញាតឱ្យសិស្សធ្វើការជាដៃគូដើម្បីរៀបចំសំណួរ ពួកគេអាចធ្វើការសម្ភាសនេះដូចជា កិច្ចការផ្ទះ ហើយត្រូវយកវាមកសាលារៀននៅសប្តាហ៍បន្ទាប់។

## សេចក្តីណែនាំគ្រូ

| គុណសម្បត្តិនៃការធ្វើបំលាស់ទីទៅកាន់កន្លែងផ្សេង | គ្រោះថ្នាក់នៃការធ្វើបំលាស់ទីទៅកាន់កន្លែងផ្សេង |
|---|---|
| ● ឱកាសការងារកាន់តែប្រសើរ<br>● ទទួលបានប្រាក់ចំណូលកាន់តែច្រើនដើម្បីជួយគ្រួសារ<br>● ការអប់រំកាន់តែខ្ពស់ គុណភាពកាន់តែប្រសើរ<br>● ផ្សងព្រេង ឱកាសបានឃើញទីក្រុង<br>● ឱកាសក្នុងការរៀនជំនាញថ្មីៗ<br>● ឱកាសក្នុងការជួបមនុស្សប្លែកៗ<br>● ឱកាសរកស៊ីកាន់តែប្រសើរ<br>● ដើម្បីរស់នៅកន្លែងដែលមានសុវត្ថិភាព<br>● ដើម្បីបង្កើតចំណុចចាប់ផ្តើមថ្មីក្នុងជីវិត | ● ត្រូវបានបោកប្រាស់ដោយមេកើយ<br>● មិនត្រូវបានផ្តល់ប្រាក់ខែ ឬការងារតាមសន្យា<br>● ត្រូវបានបោកបញ្ឆោតឱ្យធ្វើការងារពិបាក កខ្វក់ ឬមានគ្រោះថ្នាក់។<br>● ត្រូវបានជួញដូរ ឬឆ្លងដែនខុសច្បាប់<br>● មិនទទួលបានព័ត៌មាន និងគ្មានជំនាញភាសាដើម្បីសុំជំនួយ។<br>● ... |

២. សំណួរដែលអាចប្រើក្នុងការស្រាវជ្រាវ សម្ភាសនៅក្នុងភូមិ៖

- តើអត្រានៃការធ្វើបំលាស់ទីទៅកាន់កន្លែងផ្សេងនៅក្នុងសហគមន៍យ៉ាងដូចម្តេចដែរ? តើមានប្រជាជនប៉ុន្មាននាក់បានធ្វើបំលាស់ទីទៅកាន់កន្លែងផ្សេង? ហេតុអ្វីបានជាពួកគេធ្វើបំលាស់ទីទៅកាន់កន្លែងផ្សេង? តើភាគច្រើនជា បុរស ស្ត្រី មនុស្សវ័យជំទង់ ឬយុវជន?
- តើប្រជាជនដែលបានធ្វើបំលាស់ទីទៅកាន់កន្លែងផ្សេងពិតជាទទួលបានសុវត្ថិភាព ឬអសុវត្ថិភាព? ហេតុអ្វី? តើអ្វីជាភាពប្រហែលគ្នាអំពីប្រភេទមនុស្សដែលធ្វើបំលាស់ទីទៅកាន់កន្លែងផ្សេងដោយគ្មានសុវត្ថិភាព?
- តើប្រជាជនភាគច្រើនការធ្វើបំលាស់ទីទៅកាន់កន្លែងផ្សេងតាមរដូវកាល ក្នុងរយៈពេលខ្លី ឬពួកគេធ្វើការបំលាស់ទីទៅកាន់កន្លែងផ្សេងជាអចិន្ត្រៃយ៍?
- តើប្រជាជនភាគច្រើននៅក្នុងសហគមន៍ទទួលបានផលចំណេញពីការធ្វើបំលាស់ទីទៅកាន់កន្លែងផ្សេង ឬក៏ពួកគេមានការខាតបង់ដែរឬទេ?
- តើប្រជាជននៅក្នុងសហគមន៍យល់ដឹងពីគ្រោះថ្នាក់នៃការធ្វើបំលាស់ទីទៅកាន់កន្លែងផ្សេងដែរឬទេ? ប្រសិនបើគេដឹង ហេតុអ្វីបានជា ប្រជាជនភាគច្រើននៅតែបំលាស់ទីទៅកាន់កន្លែងផ្សេង?
- តើប្រជាជនដឹងពីរបៀបនៃការធ្វើបំលាស់ទីទៅកាន់កន្លែងផ្សេងមានសុវត្ថិភាពដែរឬទេ?
- តើមានអ្វីដែលកំពុងត្រូវបានធ្វើដោយក្រុមប្រឹក្សាឃុំ-សង្កាត់ គណៈកម្មការអភិវឌ្ឍភូមិ វត្តអារាម សាលារៀន ឬអង្គការនានាដើម្បីផ្សព្វផ្សាយពីការយល់ដឹងអំពីចំណាកស្រុកមានសុវត្ថិភាព និងលើកតម្កើងពីបញ្ហានេះដែរឬទេ? តើមានអ្វីខ្លះ?

## រូបភាពនេះជាល្បែងលេង គឺចង់បង្ហាញដល់សិស្ស ឱ្យដឹងពីការធ្វើបំលាស់ទីទៅកាន់ទីកន្លែងផ្សេង



## រូបភាពនេះជាល្បែងលេង គឺចង់បង្ហាញដល់សិស្ស ឱ្យដឹងពីការធ្វើបំលាស់ទីទៅកាន់ទីកន្លែងផ្សេង



# មេរៀនទី ៤: សុវត្ថិភាព និងគ្មានសុវត្ថិភាព

🕑 រយៈពេលបង្រៀន: ១ម៉ោង ៣០នាទី

☑ ការត្រៀមលក្ខណៈ

មុនពេលបង្រៀនលោកគ្រូ អ្នកគ្រូត្រូវ

- អាន និងពិនិត្យមេរៀនដោយហ្មត់ចត់ និងធ្វើកិច្ចតែងការបង្រៀន
- ពិនិត្យមើលឯកសារសិស្ស ដើម្បីចង់ដឹងថាតើមានព័ត៌មាន និងសំណួរ សម្រាប់សកម្មភាពត្រូវនឹងការបង្រៀនដែរឬទេ
- សរសេរសំណួរលើក្តារខៀន ឬនៅលើក្រដាសផ្ទាំងធំ  ប្រសិនបើសិស្សមានឯកសារ គេអាចមើលព័ត៌មាននេះនៅក្នុងសៀវភៅរបស់គេបាន
- មើលកាលវិភាគប្រចាំថ្ងៃ
- រៀបចំបន្ទប់រៀន (តុ កៅអី ក្តារខៀន...)។

📖 សម្ភារឧបទេស ធនធានដែលត្រូវការ

- ខ្មៅដៃពណ៌ គូល័រទៀន
- ក្រដាស A4 ពណ៌ស ២០សន្លឹក
- ឯកសារសម្រាប់សិស្ស ៤.១ **"ករណីសិក្សា"**។

☼ វត្ថុបំណង

នៅពេលរៀនមេរៀននេះចប់ សិស្សនឹងអាច ៖

- ប្រមូលផ្តុំព័ត៌មានដែលបានប្រមូល និងធ្វើសេចក្តីសន្និដ្ឋានអំពីចំណាកស្រុកដែលមានសុវត្ថិភាព និងចំណាកស្រុកដែលគ្មានសុវត្ថិភាព។
- ធ្វើការជាមួយគ្នាអំពីបទបង្ហាញមួយដែលឆ្លុះបញ្ចាំងពីចំណេះដឹងរបស់ពួកគេដែលទទួលបាន។

🕑 ២០ នាទី

## សេចក្តីផ្តើម

លេងល្បែងកំសាន្តតូចមួយ ខ្ញុំនឹងចង្អុលទៅខេត្តមួយនៅលើផែនទី។ នរណាដែលមានបងប្អូនកំពុងរស់នៅ ឬធ្វើការនៅទីនោះត្រូវក្រោកឈរឱ្យបានលឿនបំផុតហើយប្រាប់ឈ្មោះខេត្តនោះ។ បន្ទាប់ពីនោះ ខ្ញុំនឹងចង្អុលទៅកាន់ខេត្តផ្សេងៗទៀត។

ល្បែងនេះលេងក្នុងរយៈពេល ២ឬ៣នាទី អ្នកអាចធ្វើឱ្យកាន់តែមានការប្រណាំងប្រជែង ដោយនិយាយថា សិស្សគួរតែប្រាប់ពីទីប្រជុំជននៃខេត្តនោះ។

កាលពីសប្តាហ៍មុន អ្នកបានស្ទង់មតិមួយនៅក្នុងភូមិ។ ថ្ងៃនេះ យើងនឹងធ្វើសេចក្តីសន្និដ្ឋាន ខ្លះៗ ព្រមទាំងចែករំលែកលទ្ធផលជាមួយគ្នាទៅវិញទៅមក។ គូនីមួយៗអាចជ្រើសរើសគូផ្សេង ទៀតដើម្បីសួរនាំអំពីការសម្ភាស។  ដូច្នេះអ្នកអាចប្រើសំណួរដែលមាននៅលើក្តារខៀន។

តើប្រជាជនណាខ្លះដែលអ្នកបានសម្ភាស?

តើអ្វីដែលបានដំណើរការល្អអំឡុងពេលធ្វើការសម្ភាស?

តើចម្លើយណាមួយដែលត្រូវបានឆ្លើយដូចគ្នាដោយអ្នកផ្តល់បទសម្ភាសលើសពីមួយនាក់?

សិស្សរំលឹកពីព័ត៌មានជាមួយគ្នាក្នុងរយៈពេល១០នាទី។

ដើម្បីទទួលបានគំនិតកាន់តែប្រសើរអំពីការធ្វើបំលាស់ទីទៅកាន់កន្លែងផ្សេង យើងត្រូវស្រាវជ្រាវក្នុងចំណោមប្រភពខុសៗគ្នាជាច្រើន។

## សកម្មភាពសំខាន់។ ⏲ ៤០ នាទី

តើអ្នកចង់បំលាស់ទីទៅកាន់កន្លែងផ្សេងដែរឬទេ? ហេតុអ្វី?

យើងធ្វើការជាក្រុមដែលមានសមាជិក ៤នាក់។ ខ្ញុំចង់ឱ្យអ្នកធ្វើការជាមួយគ្នា ដើម្បីត្រិះរិះពិចារណារកចម្លើយនៃសំណួរទាំងបីនេះ។

តើគ្រោះថ្នាក់ទាក់ទងនឹងការធ្វើបំលាស់ទីទៅកាន់កន្លែងផ្សេងមានអ្វីខ្លះ?

តើគុណសម្បត្តិ ឬគុណប្រយោជន៍នៃការធ្វើបំលាស់ទីទៅកាន់កន្លែងផ្សេងមានអ្វីខ្លះ?

តើរវាងការធ្វើបំលាស់ទីទៅកាន់កន្លែងផ្សេងដែលមានសុវត្ថិភាព និងការធ្វើបំលាស់ទីទៅកាន់កន្លែងផ្សេងគ្មានសុវត្ថិភាពមានលក្ខណៈខុសគ្នាដូចម្ដេចខ្លះ?

*អ្នកក៏អាចប្រើទិន្នន័យដែលប្រជាជនបានផ្ដល់ឱ្យអ្នកក្នុងការសម្ភាសផងដែរ។*

ទុកពេលឱ្យសិស្ស១០នាទីដើម្បីពិភាក្សាជាមួយគ្នា និងចូលរួមជាមួយក្រុមមួយចំនួនដើម្បី សង្កេតមើលពីដំណើរការពិភាក្សា។ ប្រសិនបើនៅសល់ពេលវេលា ឱ្យក្រុមមួយចំនួនធ្វើបទបង្ហាញពីចម្លើយរបស់ពួកគេទៅកាន់មិត្តរួមថ្នាក់ទាំងអស់។

ដើម្បីស្រាវជ្រាវអំពីបញ្ហានេះ ខ្ញុំឱ្យអត្ថបទរឿងពីរទៅអ្នក។ ទីមួយជារឿងរបស់ មុន្នី ហើយរឿងមួយទៀតជារបស់ ចន្ទ្រា។ ក្រុមដែលមានសមាជិក៤នាក់ត្រូវចែកជាពីរគូ។

គូនីមួយៗ អាចសិក្សាពីករណីខុសៗគ្នា។ ព្យាយាមឆ្លើយសំណួរដែលយើងបាននិយាយរួចមកហើយខាងលើនេះ។

សិស្សបន្ថែមព័ត៌មាន និងផ្លាស់ប្ដូរចម្លើយទៅកាន់ដៃគូដទៃ។

សរសេរនៅលើក្ដារខៀន ៖ គ្រោះថ្នាក់ - គុណសម្បត្តិ

ឱ្យសិស្សចាប់ផ្ដើមសរសេរពីប្រធានបទដែលអាចមាននៅខាងក្រោមពាក្យទាំងពីរនោះនៅលើក្ដារខៀន។ តារាងអាចដូចនឹងតារាងដែលមាននៅក្នុងសេចក្ដីណែនាំគ្រូ។

តើនរណាអាចប្រាប់ពីភាពខុសគ្នានៃការធ្វើបំលាស់ទីទៅកាន់កន្លែងផ្សេងដែលមានសុវត្ថិភាព និងការធ្វើបំលាស់ទីទៅកាន់កន្លែងផ្សេងដែលគ្មានសុវត្ថិភាព?

## បញ្ចប់មេរៀន ⏲ ៣០ នាទី

មកដល់ពេលនេះ យើងបានប្រមូលព័ត៌មានតាមមធ្យោបាយខុសៗគ្នា។ ដំបូង យើងបានចែករំលែកបទពិសោធន៍ផ្ទាល់ខ្លួនរបស់យើងទាក់ទងនឹងការធ្វើបំលាស់ទីទៅកាន់កន្លែងផ្សេង។ បន្ទាប់មក យើងបានលេងល្បែងកំសាន្តមួយ ហើយយើងបានជួបប្រទះ បញ្ហា និងស្ថានភាពខុសៗគ្នាដែលមានឥទ្ធិពលលើជីវិតរបស់យើង។ តមកទៀត យើងបានធ្វើសម្ភាសជាមួយប្រជាជននៅខាងក្រៅសាលារៀន របស់ពួកយើង ដែលពួកគេមានអាយុខុសៗគ្នា។ នៅផ្នែកចុងក្រោយនៃការអង្កេតរបស់យើង គឺការ សិក្សាករណីសិក្សា ហើយយើងបានវិភាគស្ថានភាពដែលបានកើតឡើងចំពោះមុន្នី និង ចន្ទ្រា។

វាមានសារៈសំខាន់នៅពេលស្រាវជ្រាវប្រមូលព័ត៌មានពីប្រភពផ្សេងៗគ្នា។ ឥឡូវនេះជាពេលវេលាដើម្បី ដំណើរការព័ត៌មានទាំងនេះ។ កិច្ចការរបស់ពួកយើងគឺ បង្កើតជាផ្ទាំងរូបភាពមួយនៅលើក្រដាសផ្ទាំង ដែលអាចប្រើដើម្បីប្រាប់ដល់សមាជិកសហគមន៍របស់យើង អំពីការធ្វើបំលាស់ទីទៅកាន់កន្លែងផ្សេងមានសុវត្ថិភាព។

? តើផ្ទាំងរូបភាពដែលត្រូវបង្កើតមានចំណុចសំខាន់អ្វីខ្លះ?

ចម្លើយអាចមាន៖ វាត្រូវមានភាពទាក់ទាញ អត្ថបទច្បាស់លាស់ងាយយល់ មានរូបភាព មានខ្លឹមសារច្បាស់លាស់។

នៅក្នុងក្រុមដែលមានគ្នា៤នាក់ការងារនិងកិច្ចការផ្ទះរបស់ក្រុមអ្នក គឺបង្កើតជាផ្ទាំងរូបភាព។នៅក្នុងផ្ទាំងរូបភាព នីមួយៗត្រូវមានមតិយោបល់ ឬគំនិតដែលផ្តល់ដោយសមាជិកក្នុងក្រុមទាំងអស់គ្នា។ នៅសប្តាហ៍ក្រោយ យើងនឹងបង្ហាញ ផ្ទាំងរូបភាពរបស់ពួកយើង ហើយនឹងនិយាយ អំពីវា។ តើអ្នកទាំងអស់គ្នាយល់ច្បាស់អំពីកិច្ចការនេះដែរឬទេ?

ចែកគូល័រទៀន ខ្មៅដៃពណ៌ឬសម្ភារៈសម្រាប់គូរផ្សេងៗទៀត ព្រមទាំងផ្តល់ក្រដាសផ្ទាំង ចំនួនពីរសន្លឹកទៅកាន់ក្រុម នីមួយៗ។ ចូរបញ្ជាក់ថា វាជាគំនិតដ៏ល្អមួយ ក្នុងការសរសេរសេចក្តីព្រាងជាមុនសិន មុនពេលចាប់ផ្តើមសរសេរសម្រេចនៅលើក្រដាស។ ដើរជុំវិញដើម្បីសង្កេតពីការសហការគ្នា។ វាជាឱកាសល្អមួយដើម្បីដាក់ពិន្ទុនៅក្នុងក្រដាសវាយតម្លៃពីឥរិយាបថរបស់សិស្សម្នាក់ៗ។

## សេចក្តីណែនាំគ្រូ

១. ចម្លើយដែលអាចមានសម្រាប់ករណីសិក្សា

| ១. គ្រោះថ្នាក់ទាក់ទង នឹងការធ្វើបំលាស់ទីទៅកាន់កន្លែងផ្សេង | ២. គុណសម្បត្តិនៃការធ្វើបំលាស់ទីទៅកាន់កន្លែងផ្សេង | ៣. ភាពខុសប្លែកគ្នារវាងការធ្វើបំលាស់ទីទៅកាន់កន្លែងផ្សេងមានសុវត្ថិភាព និងគ្មានសុវត្ថិភាព នៅក្នុងការធ្វើបំលាស់ទីទៅកាន់កន្លែងផ្សេង ដោយគ្មានសុវត្ថិភាព/ ដោយគ្មានការពិចារណាអាចមាន៖ |
|---|---|---|
| • អាចធ្លាក់ខ្លួនគ្មានការងារធ្វើ ឬក្រជាងមុន<br>• អាចចាញ់បោកគេ<br>• អាចជួបការងារមិនល្អដែលមានប្រាក់ខែទាប និងធ្វើការច្រើនម៉ោង<br>• ប៉ះពាល់សុខភាព<br>• ឯកោ<br>• ងាយទទួលរងការរំលោភបំពាន | • អាចទទួលបានការងារល្អ<br>• អាចផ្គត់ផ្គង់គ្រួសារ<br>• អាចធ្វើឱ្យជីវភាពបានប្រសើរ<br>• អាចទទួលបានបទពិសោធន៍ថ្មីៗ | • គ្មានគម្រោង គ្មានការគិតទុកជាមុន<br>• គ្មានការធានាចំពោះការងារ<br>• គ្មានចំណេះដឹងក្នុងការស្នាក់នៅ ឬតំបន់ដែលអ្នកនឹងរស់នៅ<br>• ងាយទទួលរងគ្រោះដោយ "ការអូសទាញ"<br>• គ្មានសុវត្ថិភាពក្នុងការធ្វើដំណើរមិនដឹងពីគោលដៅ ឬទិសដៅច្បាស់លាស់ |

## រឿងរបស់មុន្នី

"មុន្នីជាមិត្តម្នាក់របស់ខ្ញុំដែលបានត្រឡប់មក ចូលរួមបុណ្យចូលឆ្នាំថ្មី។ នាងបាននិយាយថា នៅក្នុងរោងចក្រកាត់ដេររបស់នាង នៅទីក្រុងភ្នំពេញមានការងារសម្រាប់ខ្ញុំ។ ខ្ញុំក៏បានសម្រេចចិត្តថា ជាដំបូងខ្ញុំត្រូវការស្វែងយល់ឱ្យបានច្រើនតាមតែអាចធ្វើបានដើម្បីធ្វើបំលាស់ទីទៅកាន់ទីកន្លែងផ្សេងមានសុវត្ថិភាព។ ខ្ញុំបានដឹងរឿងខ្លះរបស់ក្មេងស្រីដែលត្រូវបានគេបោក និងជួញដូរ ហើយខ្ញុំក៏មិនចង់ឱ្យខ្លួនរបស់ខ្ញុំធ្លាក់ទៅក្នុង គ្រោះថ្នាក់បែបនោះទេ។ ខ្ញុំជឿលើមិត្តរបស់ខ្ញុំ ហើយខ្ញុំក៏ស្គាល់គ្រួសាររបស់នាងដែរ។ ពួកគេដូចជាបងប្អូនខ្ញុំអីចឹង តែខ្ញុំចង់ស្វែងឱ្យកាន់តែប្រាកដ។ ខ្ញុំបានពិភាក្សាជាមួយឪពុករបស់ខ្ញុំ ដើម្បីទទួលបានការគាំទ្ររួចគាត់ក៏យល់ព្រម ហើយពួកយើងបានធ្វើការពិនិត្យមើលមុនពេលដែលខ្ញុំធ្វើការសន្យា។ ឪពុករបស់ខ្ញុំយល់ព្រមលក់ជ្រូកដើម្បីប្រមូលលុយសម្រាប់ធ្វើដំណើរទៅទីក្រុងភ្នំពេញជាមួយម្តាយរបស់ខ្ញុំ ក្នុងគោលបំណងស្វែងរកព័ត៌មានផ្សេងៗទាក់ទងនឹងការងារ និងកន្លែងដែលខ្ញុំត្រូវរស់នៅក្នុងពេលខ្ញុំធ្វើការងារ ផល្លាបានជួលបន្ទប់មួយនៅក្នុងអគារដែលបងប្អូនរបស់នាងក៏រស់នៅទីនោះដែរ។ យើងបានទៅជួបអ្នកគ្រប់គ្រងរោងចក្របន្ទាប់ពីញ៉ាំបាយថ្ងៃត្រង់រួច។ អ្នកគ្រប់គ្រង ដែលជាមិត្តប្រុសរបស់ផល្លាបាននិយាយថា មានការងារមួយសម្រាប់ខ្ញុំ ប៉ុន្តែខ្ញុំត្រូវបង់ថ្លៃចូលធ្វើការនេះ។ គាត់បានទាមទារ ១០០ដុល្លារ ប៉ុន្តែខ្ញុំមិនមានលទ្ធភាពក្នុងការផ្តល់ឱ្យគាត់ទេ។ ផល្លាបានប្រាប់គាត់ថា ប្រាក់នេះមានចំនួនច្រើនពេក ដូច្នេះយើងចរចាគ្នាត្រឹមតែ៥០ដុល្លារ ហើយផល្លាក៏បានឱ្យខ្ញុំខ្ចីប្រាក់នេះដោយមិនយកការប្រាក់ឡើយ។ យើងបានកត់ឈ្មោះអ្នកគ្រប់គ្រង និងរោងចក្រនោះ រួមទាំងអាសយដ្ឋានដែលខ្ញុំនឹងរស់នៅ មុនពេលយើងត្រឡប់មកភូមិវិញដើម្បីប្រាប់ព័ត៌មានលម្អិតដល់ឪពុករបស់ខ្ញុំ និង មិត្តភក្តិរបស់គាត់ដែលជាគណៈកម្មការអភិវឌ្ឍភូមិ។ យើងបានពិភាក្សារឿងនេះទាំងអស់គ្នា ហើយក៏សម្រេចថា ខ្ញុំគួរទៅធ្វើការនោះ។ មួយសប្តាហ៍ក្រោយមក ខ្ញុំបានចាកចេញពីភូមិទៅភ្នំពេញ។ ថ្វីបើការងារនោះលំបាកបន្តិចមែន តែខ្ញុំសម្រេចចិត្តបានត្រឹមត្រូវដែលខ្ញុំមកធ្វើការទីនេះ។ ខ្ញុំបានទិញជ្រូកមួយឱ្យឪពុកម្តាយរបស់ខ្ញុំ ចិញ្ចឹមដើម្បីបង្កាត់ពូជ និងលក់បានប្រាក់ច្រើនទៀត។ ខ្ញុំមានលទ្ធភាពជួយគ្រួសាររបស់ខ្ញុំ ដូច្នេះកម្រិតជីវភាពរបស់ខ្ញុំមានភាពប្រសើរជាងមុន។ ក្រុមគ្រួសាររបស់ខ្ញុំដឹងថា ខ្ញុំមានសុវត្ថិភាព ដោយសារតែខ្ញុំបានត្រួតពិនិត្យការងារ ទីកន្លែងស្នាក់នៅប្រកបដោយសុវត្ថិភាពជាមុន។"



---

## រឿងរបស់ចន្ទ្រា

ខ្ញុំបានចាកចេញពីភូមិកំណើតរបស់ខ្ញុំនៅក្នុងខេត្តព្រៃវែង មកទីក្រុងភ្នំពេញ ដើម្បីស្វែងរកការងារធ្វើជាមួយមិត្តភក្តិ របស់ខ្ញុំ។ បន្ទាប់ពីស្វែងរកការងារអស់រយៈពេលមួយសប្តាហ៍ដោយគ្មានក្តីសង្ឃឹម យើងបានចាយប្រាក់អស់រលីង ហើយមិត្តរបស់ខ្ញុំក៏បានត្រឡប់ទៅភូមិវិញ ប៉ុន្តែខ្ញុំមិនចង់អាប់មុខទេ ដូច្នេះខ្ញុំក៏បន្តនៅតទៅទៀត ។ ដោយខ្ញុំគ្មានប្រាក់ ខ្ញុំបានរកឱកាសមួយដើម្បីជួបជាមួយស្ត្រីលក់ស្រាបៀរមួយរូប ហើយសួរពីរបៀបដែលខ្ញុំអាចរកប្រាក់ចំណូលបានខ្លះៗ។ នាងបាននាំខ្ញុំទៅភោជនីយដ្ឋានមួយ និងណែនាំខ្ញុំទៅកាន់ភ្ញៀវម្នាក់ឈ្មោះរដ្ឋា។ គាត់បានប្រាប់ខ្ញុំអំពីការរកស៊ីរបស់គាត់ គឺនាំទូរស័ព្ទចូលពីប្រទេសថៃ ហើយគាត់អាចរកប្រាក់ចំណូលបានយ៉ាងច្រើន។ បន្ទាប់មក គាត់បានសួរខ្ញុំថា "តើអ្នកចង់ឱ្យខ្ញុំជួយរកការងារឱ្យអ្នកធ្វើដែរឬទេ? មិត្តភក្តិរបស់ខ្ញុំគឺជាម្ចាស់ហាងសម្លៀកបំពាក់។ គាត់ត្រូវការអ្នកលក់យ៉ាងប្រញាប់ដែលផ្តល់ប្រាក់៥០ដុល្លារក្នុងមួយខែ។" ខ្ញុំគិតថា "នេះជាឱកាសយ៉ាងល្អ!"។ ខ្ញុំក៏បានឡើងជិះឡានជាមួយគាត់ទៅកាន់ហាងនោះ។ ប៉ុន្តែជាអកុសល ម្ចាស់ហាងនិយាយថា គ្មានការងារសម្រាប់ខ្ញុំទេ ប៉ុន្តែដោយរដ្ឋាអាណិតខ្ញុំ គាត់និយាយថា ខ្ញុំអាចធ្វើការជាអ្នកបម្រើក្នុងគ្រួសាររបស់គាត់។ ដោយសារតែខ្ញុំគ្មានជម្រើស ខ្ញុំក៏បានទទួលយកការងារនោះ ហើយធ្វើការ ១៨ម៉ោងក្នុងមួយថ្ងៃ ហើយ៧ថ្ងៃក្នុងមួយសប្តាហ៍ ដែលគ្មានថ្ងៃឈប់សម្រាកទេ។ អ្នកបម្រើផ្សេងទៀត និងប្រពន្ធរបស់រដ្ឋាតែងតែប្រើខ្ញុំគ្រប់ពេលវេលា ហើយខ្ញុំធ្លាប់ដេកនៅលើកម្រាលឥដ្ឋក្នុងបន្ទប់ផ្ទះបាយផងដែរ។ ខ្ញុំទទួលបានប្រាក់ខែត្រឹមតែ១០ដុល្លារប៉ុណ្ណោះ ដែលនេះប្រសើរជាងមិនទទួលបានអ្វីសោះ ប៉ុន្តែខ្ញុំសង្ឃឹមថា ខ្ញុំមិនបានចាកចេញពីភូមិកំណើតរបស់ខ្ញុំទេ។



# មេរៀនទី ៥: ផ្ទាំងរូបភាព

រយៈពេលបង្រៀនៈ ១ម៉ោង ៣០នាទី

**ការត្រៀមលក្ខណៈ**

មុនពេលបង្រៀនលោកគ្រូ អ្នកគ្រូត្រូវ

- អាន និងពិនិត្យមេរៀនដោយហ្មត់ចត់ និងធ្វើកិច្ចតែងការបង្រៀន
- ពិនិត្យមើលឯកសារសិស្ស ដើម្បីចង់ដឹងថាតើមានព័ត៌មាន និងសំណួរ សម្រាប់សកម្មភាពត្រូវនឹងការបង្រៀនដែរឬទេ
- សរសេរសំណួរលើក្តារខៀន ឬនៅលើក្រដាសផ្ទាំងធំ ប្រសិនបើសិស្សមានឯកសារ គេអាចមើលព័ត៌មាននេះនៅក្នុងសៀវភៅរបស់គេបាន
- មើលកាលវិភាគប្រចាំថ្ងៃ
- រៀបចំបន្ទប់រៀន (តុ កៅអី ក្តារខៀន...)។

**សម្ភារឧបទេស ធនធានដែលត្រូវការ**

- ស្កុតសម្រាប់បិទផ្ទាំងរូបភាពរបស់សិស្សទៅនឹងជញ្ជាំង
- ក្រដាសតូចដែលមានជ័រស្អិតទុកសម្រាប់សរសេរមតិយោបល់ និងការសរសើរ
- ផ្ទាំងរូបភាព "ការរៀបចំល្អ" ធ្វើតាមសេចក្តីណែនាំគ្រូ។

**វត្ថុបំណង**

នៅពេលរៀនមេរៀននេះចប់ សិស្សនឹងអាច ៖

- ផ្តត់មតិយោបល់វិជ្ជមានទៅលើខ្លឹមសារ និងការរចនាផ្ទាំងរូបភាពរបស់សិស្សដទៃ។

៥០ នាទី

## សេចក្តីផ្តើម

អ្នកទាំងអស់គ្នាបានឃើញផ្ទាំងរូបភាពនៅលើជញ្ជាំង។

តើនរណាអាចប្រាប់ខ្ញុំបានថា ផ្ទាំងរូបភាពនេះនិយាយអំពីអ្វី?
តើអ្នកគិតថាអត្ថន័យរបស់រូបភាពនេះច្បាស់លាស់ឬទេ? ហេតុអ្វី?
តើអ្នកអាចយល់រូបភាពនេះដោយគ្មានអត្ថបទបានដែរឬទេ?
*ព្យាយាមនិយាយជាមួយសិស្ស អំពីមតិយោបល់ និងការសរសើរដែលអាចមានអំពីផ្ទាំងរូបភាពនេះ។*

នៅពេលអ្នកកំពុងធ្វើការនៅក្នុងក្រុម អ្នកត្រូវការប្រាស្រ័យទាក់ទងជាមួយគ្នាទៅវិញទៅមក អំពីការងាររបស់អ្នក និងការងាររបស់អ្នកដទៃ។ នេះគឺជាការពិតណាស់ ប្រសិនបើអ្នកចង់ធ្វើ ឱ្យគុណភាពកាន់តែប្រសើរ។ មនុស្សពីរនាក់ដឹងច្រើនជាងម្នាក់។ ផ្ទុយមកវិញ វាក៏មានសារៈសំខាន់ក្នុងការធ្វើកិច្ចការនេះដោយឬកពាល្អសមសួន។
ឧទាហរណ៍៖ ប្រសិនបើមិត្តរួមការងាររបស់អ្នកមករកអ្នក ហើយបង្ហាញការងាររបស់គេដល់អ្នក។ អ្នកដឹងថាគេបានព្យាយាមយ៉ាងខ្លាំង ប៉ុន្តែគេនៅតែមានកំហុសខ្លះៗ។ តើអ្នកនឹងឆ្លើយតបដោយរបៀបណា?

តើអ្នកនិយាយថា៖ អ៊ឺ... នេះខុសហើយ!

យើងធ្វើការតាមរយៈ *មតិយោបល់ និង ការសរសើរ*។ នេះមានន័យថា យើងអាចផ្តល់មតិយោបល់ឱ្យគ្នាទៅវិញទៅមកប៉ុន្តែយើងក៏ត្រូវលើកសរសើរគ្នាទៅវិញទៅមកផងដែរ។ ដោយមានតុល្យភាពរបស់ធាតុទាំងពីរនេះ អ្នកគ្រប់គ្នាជាសមាជិកវិជ្ជមាននៃក្រុមរបស់យើង។ កាលពីសប្តាហ៍មុន យើងមានកិច្ចការមួយគឺការបង្កើតផ្ទាំងរូបភាពការធ្វើបំលាស់ទីទៅកាន់កន្លែងផ្សេងមានសុវត្ថិភាព។ ថ្ងៃនេះ យើងផ្តល់និងព្រមទាំងទទួលយកមតិយោបល់អំពីកិច្ចការនេះ។

សំណួរសម្រាប់កិច្ចការនេះគឺ ៖

តើអ្នកចូលចិត្តផ្ទាំងរូបភាពនេះនូវចំណុចណាខ្លះ ?

តើអ្នកមិនយល់ត្រង់ចំណុចណាខ្លះ ?

តើអ្នកមានដំបូន្មានអ្វីខ្លះសម្រាប់អ្នកបង្កើតផ្ទាំងរូបភាពនេះ ?

ដំបូង អ្នកគ្រប់គ្នាបិទផ្ទាំងរូបភាពនៅលើជញ្ជាំង នៅកន្លែងខុសៗគ្នាក្នុងថ្នាក់រៀន។ បន្ទាប់ពីនេះ អ្នកគ្រប់គ្នាអាចដើរជុំវិញរួចផ្តល់មតិយោបល់ និងធ្វើការសរសើរដល់ផ្ទាំងរូបភាពទាំងអស់។ មតិយោបល់ និងការសរសើរអាចបិទនៅជិតផ្ទាំងរូបភាព ដោយការសរសេរវានៅលើក្រដាស តូចដែលមានជ័រស្អិត។

អនុញ្ញាតឱ្យសិស្សបង្កើតជាក្រុម និងសង្កេតមើលផ្ទាំងរូបភាពទាំងអស់ ។ មួយរយៈក្រោយមក នៅពេលពួកគេបញ្ចប់ការពិភាក្សាឱ្យសិស្សទាំងអស់ឈរនៅជិតផ្ទាំងរូបភាពរបស់ពួកគេនិងអានមតិយោបល់និងការសរសើរទាំងអស់នោះ។

តើចំណុចណាដែលមិនច្បាស់ ( សំណួរទី២ ) តើអ្នកអាចបញ្ជាក់ទៅកាន់មិត្តរួមថ្នាក់បានឬទេ ?

តើការសរសើរណាមួយដែលអ្នកពេញចិត្តជាមួយស្នាដៃរបស់អ្នក ?

តើមតិយោបល់ណាខ្លះជួយអ្នកឱ្យគិតឃើញពីរបៀបកែលម្អផ្ទាំងរូបភាពរបស់អ្នក ?

យោងតាមមតិយោបល់ និងការសរសើរ ក្រុមនីមួយៗអាចកែលម្អផ្ទាំងរូបភាពបាន ប្រសិនបើពួកគេចង់។ នៅក្នុងពេលពីរ ឬបីសប្តាហ៍ទៀត យើងនឹងទៅក្នុងភូមិ និងបិទផ្ទាំងរូបភាពរបស់យើងនៅកន្លែងខុសៗគ្នាដើម្បីប្រាប់សមាជិកភូមិរបស់យើងអំពីការធ្វើបំលាស់ទីទៅកាន់កន្លែងផ្សេងមានសុវត្ថិភាព។ នៅសប្តាហ៍ក្រោយ អ្នកត្រូវការយកផ្ទាំងរូបភាពកែលម្អចុងក្រោយនេះមក រៀបចំការពន្យល់ អំពីវា។

## សកម្មភាពសំខាន់។

២០ នាទី

ខ្ញុំនឹងផ្តល់ឱ្យអ្នកនូវរឿងមួយស្តីពីសិស្សម្នាក់កំពុងនិយាយជាមួយគ្រូ។ រឿងនេះមានព័ត៌មានសំខាន់ៗ សម្រាប់អ្នកដែលមានគម្រោងនៃការធ្វើបំលាស់ទីទៅកាន់កន្លែងផ្សេង។ អ្នកគ្រប់គ្នាគួរអានវារៀងៗខ្លួន។ បន្ទាប់ពីអានរួច ខ្ញុំចង់ឱ្យអ្នក បង្កើតជាសំណួរទាក់ទងនឹងបញ្ហានៅលើក្រដាស។ បង្កើតជាសំណួរដែលអាចឆ្លើយ "បាទ ចាស" និង "ទេ"។

ចែកឯកសារ ៥.១ សម្រាប់សិស្ស គ្រប់ៗគ្នា និងអនុញ្ញាតឱ្យពួកគេអានវា។ បន្ទាប់មក ពួកគេអាចគិតរកសំណួរអំពីឯកសារសម្រាប់សិស្សនេះ។ ប្រសិនបើអ្នកចង់ អ្នកអាចសួរសំណួរទៅកាន់សិស្សដើម្បីឱ្យពួកគេគិត។

នៅក្នុងឯកសារសម្រាប់សិស្ស វ៉ាន់ និយាយអំពីការសិក្សាជំនាញវិជ្ជាជីវៈ ឬបំណិនជីវិត។ ប្រសិនបើអ្នកចង់ទៅទីក្រុង តើវិជ្ជាជីវៈ ឬបំណិនជីវិតបែបណាដែលអ្នកត្រូវការ ?

## បញ្ចប់មេរៀន

២០ នាទី

យើងនឹងលេងល្បែងកំសាន្តមួយជាមួយសំណួររបស់អ្នក។ ខ្ញុំត្រូវការអ្នកចោទសួរបីនាក់ដែលមានសំណួរជាច្រើន។ អ្នកចោទសួរទាំងនោះនឹងដឹកនាំល្បែង "បាទ ចាស ឬទេ"។ ល្បែងនេះនឹងលេងនៅក្រៅថ្នាក់ដោយសិស្សទាំងអស់ត្រូវឈរជាមួយគ្នា។ ខ្ញុំនឹងគូសបន្ទាត់មួយឱ្យឈរ ។ នៅខាងឆ្វេងនៃបន្ទាត់គឺជាផ្នែកចម្លើយ "ទេ" ហើយនៅខាងស្តាំគឺជា ផ្នែកចម្លើយ"បាទចាស"។ គ្រប់សំណួរទាំងអស់ដែលបានសួរគឺមានចម្លើយមួយនៃចម្លើយទាំងពីរនេះ ។ ប្រសិនបើអ្នកដឹងពីចម្លើយ អ្នកអាចទៅឈរនៅខាងផ្នែកត្រឹមត្រូវ ។ ក្រោយពេល១០វិនាទី យើងនឹងប្រាប់ពីចម្លើយដែលត្រឹមត្រូវ ។ ប្រសិនបើអ្នកឈរនៅផ្នែកត្រឹមត្រូវតាមចម្លើយ អ្នកអាចលេងបន្តទៀតបាន ប៉ុន្តែប្រសិនបើអ្នកឈរមិនត្រឹមត្រូវអ្នកត្រូវមកឈរនៅខាងមុខអ្នកចោទសួរនិងមើលអ្នកដទៃលេងបន្ត។នៅចុងបញ្ចប់នឹងមានអ្នកលេងម្នាក់ ឬពីរ- បីនាក់ ដែលជា "អ្នកធ្វើចំណាកស្រុកមានសុវត្ថិភាពបំផុត"។

ទៅខាងក្រៅ ហើយគូសបន្ទាត់ដើម្បីឈរពីលើ។ ពិនិត្យសំណួរខ្លះរបស់អ្នកចោទសួរដើម្បីដឹងថាតើពួកគេយល់ពីអ្វីដែលត្រូវធ្វើ។ ប្រសិនបើមិនយល់ ប្រើសំណួរខ្លះនៅក្នុងសេចក្តីណែនាំគ្រូ។ ក្រោយពេល ១៥នាទី (អ្នកអាចលេងល្បែងនេះជាច្រើនដង) បញ្ឈប់ល្បែងកំសាន្ត។

នៅសប្តាហ៍បន្ទាប់ អ្នកត្រូវការផ្ទាំងរូបភាពចុងក្រោយដើម្បីផ្សព្វផ្សាយនៅក្នុងភូមិ ដូច្នេះត្រូវប្រាកដថា អ្នកអាចធ្វើទាន់ពេលវេលាប្រសិនបើអ្នកចង់កែសម្រួល ឬកែលម្អវា។

### សេចក្តីណែនាំគ្រូ

ពន្យល់សិស្សថា គ្មានសេចក្តីណែនាំមួយជំហានម្តងៗ សម្រាប់ការធ្វើបំលាស់ទីទៅកាន់កន្លែងផ្សេងដោយ សុវត្ថិភាពទេ។ កាលៈទេសៈគឺខុសគ្នាពីទីក្រុងមួយទៅទីក្រុងមួយទៀត និងពីការងារមួយទៅការងារមួយ។ ដូច្នេះ សេចក្តីណែនាំនៅក្នុងមេរៀនមិនទាន់ពេញលេញទេ គឺអាចត្រូវការជំហានខុសៗ គ្នា ឬត្រូវការជំហានបន្ថែមទៀត។
*អាស្រ័យលើកម្រិតរបស់សិស្ស អ្នកអាចសម្រេចប្រើព័ត៌មានខាងក្រោមដើម្បីបញ្ចូលទៅក្នុងផ្ទាំងរូបភាព។*

ព័ត៌មានសម្រាប់អ្នកធ្វើការធ្វើបំលាស់ទីទៅកាន់កន្លែងផ្សេងមានសុវត្ថិភាព

*មុនពេលចេញដំណើរ*

- ស្វែងរកការពិគ្រោះយោបល់ជាមួយមេភូមិ ឬអ្នកធ្វើការធ្វើបំលាស់ទីទៅកាន់កន្លែងផ្សេងដែលមានបទពិសោធន៍មុនពេលចេញដំណើរ។
- សួរ
  - តើសហគមន៍ស្គាល់ និងជឿទុកចិត្ត "មេខ្យល់" ដែរឬទេ?
  - តើខ្ញុំអាចធ្វើការងារនោះបានទេ? តើខ្ញុំចេះភាសានោះទេ? តើសុខភាពខ្ញុំល្អដែរឬទេ?
  - តើខ្ញុំនឹងធ្វើដំណើរដោយរបៀបណា? តើខ្ញុំនឹងប្រថុយគ្រោះថ្នាក់គ្រប់ពេលវេលាឬ?
  - តើខ្ញុំនឹងស្នាក់នៅឯណា? តើនរណា ឬអង្គការណាអាចជួយខ្ញុំបាន ប្រសិនបើមានបញ្ហា?

- ប្រាប់បងប្អូន និងអ្នកជិតខាងអំពីមូលហេតុនៃការធ្វើបំលាស់ទីទៅកាន់កន្លែងផ្សេងរបស់អ្នក លក្ខខណ្ឌដែលយល់ព្រមជាមួយមេខ្យល់និងទីកន្លែងដែលត្រូវទៅ។
- ពិចារណាឱ្យបានដិតដល់អំពីការងារ ប្រាក់ឈ្នួល ប្រាក់ខែ ឬប្រាក់ចំណូល ដែលអ្នកសង្ឃឹមថា នឹងទទួលបាន និងសួរខ្លួនឯងថាតើដំណើរនេះមានប្រយោជន៍ឬទេ?
- កុំទាន់ឱ្យលុយទៅមេខ្យល់ ប្រសិនបើអ្នកមិនទាន់ទទួលបានការធានាអំពីការងារ។
- មុនពេលអ្នកខ្ចីប្រាក់គេដើម្បីធ្វើដំណើរ ពិចារណាថា តើអ្នកនឹងអាចសងប្រាក់បំណុលវិញបានដែរឬទេ?ប្រសិនបើអ្វីៗមិនដំណើរការតាមគម្រោង តើអ្នកនឹងសងប្រាក់បំណុលទាំងនោះដោយរបៀបណាក្នុងពេលអនាគត?
- តើគ្រួសាររបស់ខ្ញុំនឹងមានសុវត្ថិភាពដែរឬទេ ខណៈពេលដែលខ្ញុំមិននៅ? តើខ្ញុំត្រូវធ្វើអ្វីខ្លះដើម្បីឱ្យប្រាកដថា ពួកគេនឹងមិនជួបប្រទះបញ្ហាណាមួយនោះ?

ពិចារណា៖ តើមានជម្រើសដែលអាចផ្លាស់ប្តូរបានដើម្បីធ្វើចំណាកស្រុកក្នុងប្រទេសវិញដែរឬទេ? សួរប្រធានភូមិ អ្នកដឹកនាំមូលដ្ឋាន និងអាជីវករ ឬអ្នកជិតខាង។ ប្រាប់គ្រួសារ អ្នកជិតខាង និងមេភូមិអំពីព័ត៌មានលម្អិតពិតប្រាកដនៃទិសដៅទីកន្លែងធ្វើការ អាស័យដ្ឋាន លេខទូរស័ព្ទ។ ចូរប្រាកដថា អ្នកស្គាល់ទូរស័ព្ទទាន់ហេតុការណ៍សម្រាប់ទាក់ទង៖ លេខទូរស័ព្ទទាន់ហេតុការណ៍របស់ប៉ូលីស៖ ០២៣ ៩៩៧ ៩១៩ លេខទូរស័ព្ទទាន់ហេតុការណ៍សុវត្ថិភាពកុមារ ០១២ ៣១១ ១១២។

*នៅតាមផ្លូវ*

សម្រេចចិត្តថានរណាដែលអ្នកនឹងធ្វើដំណើរទៅជាមួយ ។ តើនឹងនៅជាមួយមេខ្យល់ដូចមុន ឬដូរមេខ្យល់ថ្មី? តើអ្នកមិនស្គាល់គេសោះនៅក្នុងក្រុម ឬតើអ្នកនឹងនៅជាមួយមនុស្សដែលអ្នកស្គាល់?ចូរប្រាកដថា អ្នកដឹងពីរបៀបក្នុងការធ្វើដំណើរ។

ពិចារណា៖ តើមានភាពប្រថុយប្រថាន (ការឆ្លងដែនខុសច្បាប់) នៅក្នុងការធ្វើដំណើរដែរ ឬទេ? តើខ្ញុំនឹងក្លាយជាអ្នក រត់ពន្ធឬ?

តើខ្ញុំស្គាល់លេខទូរស័ព្ទទាន់ហេតុការណ៍សម្រាប់ទាក់ទងពេលមានបញ្ហាកើតឡើងដែរឬទេ? លេខទូរស័ព្ទទាន់ហេតុការណ៍របស់ប៉ូលីស៖ ០២៣ ៩៩៧ ៩១៩ លេខទូរស័ព្ទសុវត្ថិភាពកុមារ ០១២ ៣១១ ១១២។

*នៅកន្លែងធ្វើការ*

ពិនិត្យ ៖ តើអ្នកស្គាល់លេខទូរស័ព្ទទាន់ហេតុការណ៍ ឬលេខទូរស័ព្ទផ្សេងៗទៀតដែលអាច ប្រើដើម្បីសុំជំនួយដែរឬទេ?

នៅពេលទៅដល់ សួរមិត្តរួមការងារថា តើពួកគេយល់ថាការងារនេះអាចទទួលយកបានដែរឬទេ? តើលក្ខខណ្ឌគួរឱ្យពេញចិត្តទេ? និងពិនិត្យជាមួយពួកគេថា គ្មានការកេងប្រវ័ញ្ចកើតឡើង។

ប្រាប់ក្រុមគ្រួសារ និងអ្នកជិតខាងអំពីការមកដល់ដោយសុវត្ថិភាព និងការពេញចិត្តចំពោះលក្ខខណ្ឌ។

ពិនិត្យថា វាមានសុវត្ថិភាពក្នុងការផ្ញើលុយមកផ្ទះ។

*សម្រាប់ការធ្វើដំណើរទៅក្រៅប្រទេស ឯកសារស្របច្បាប់ខាងក្រោមប្រហែលជាត្រូវការ៖*

លិខិតឆ្លងដែន
ទិដ្ឋាការ (វីសា)
សំបុត្រឆ្លងដែន

សំណួរដែលអាចមានសម្រាប់ល្បែង "បាទ ចាស ឬ ទេ" ៖

- ទេ បញ្ចប់បឋមសិក្សា គឺមានគុណប្រយោជន៍ចំពោះឱកាស ទទួលបានការងារល្អមួយសម្រាប់ខ្ញុំ ។
- បាទ ចាស ទោះបីជាអ្នកនឹងកាន់តែមានឱកាសល្អជាងនេះ នៅពេលអ្នកបញ្ចប់មធ្យមសិក្សា។ បំណិនជីវិតអាចជា "ជំនាញជួសជុលកង់"។
- បាទ ចាស ការដែលអាចធ្វើកិច្ចការនេះ ជួយឱ្យអ្នកមានឯករាជ និងអាច សន្សំប្រាក់បាន។

ប្រសិនបើមេភូមិស្គាល់មេខ្យល់យើងអាចទុកចិត្តបាន។ - ទេ អ្នកត្រូវការប្រេកតដែលអាចទុក ចិត្តបានបន្ថែមទៀត។

## ការនិយាយជាមួយគ្រូ

វ៉ាន់: ឥឡូវ ខ្ញុំដឹងថាមានបញ្ហាប្រឈមជាច្រើនដែលពាក់ព័ន្ធនឹងការធ្វើបំលាស់ទីទៅកាន់ទីកន្លែងផ្សេង ប៉ុន្តែតើខ្ញុំធ្វើការបំលាស់ទីទៅកាន់ទីកន្លែងផ្សេងដោយសុវត្ថិភាព និងស្វែងរកការងារដោយរបៀបណា?

គ្រូ: ការបន្តការសិក្សាគឺជាមធ្យោបាយដ៏ល្អដើម្បីបង្កើតឱកាសការងាររបស់អ្នក ប៉ុន្តែខ្ញុំដឹងថា វាមិនមែនជាជម្រើសសម្រាប់អ្នកទាំងអស់គ្នាទេ។ ប្រសិនបើគិតអំពីការធ្វើការធ្វើបំលាស់ទីទៅកាន់ទីកន្លែងផ្សេង មានលក្ខខណ្ឌមូលដ្ឋានមួយចំនួនដែលជួយធ្វើឱ្យប្រាកដអំពីសុវត្ថិភាពរបស់អ្នក.....



**ចំណុចសំខាន់សម្រាប់ការធ្វើបំលាស់ទីទៅកាន់ទីកន្លែងផ្សេងដោយសុវត្ថិភាព**

* កុំធ្វើបំលាស់ទីទៅកាន់ទីកន្លែងផ្សេង ប្រសិនបើអ្នកមានអាយុក្រោម ១៦ឆ្នាំ
* រៀនយ៉ាងតិចណាស់ឱ្យចប់ថ្នាក់ទី ៩ នៃកម្មវិធីចាំបាច់របស់សាលា
* រៀនពីបំណិនជីវិត និងជំនាញវិជ្ជាជីវៈមូលដ្ឋានខ្លះ
* ត្រូវតែដឹងពីបញ្ហាប្រឈមនៃការធ្វើបំលាស់ទីទៅកាន់ទីកន្លែងផ្សេង ជាពិសេសការជួញដូរមនុស្ស និងការកេងប្រវ័ញ្ច

វ៉ាន់: ខ្ញុំបានចុះឈ្មោះចូលរៀនវគ្គបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈក្នុងរយៈពេលវិសមកាលនេះ។ នៅពេលដែលខ្ញុំបញ្ចប់វគ្គនេះ តើវាមានន័យថាខ្ញុំនឹងត្រៀមខ្លួនរួចរាល់ក្នុងការធ្វើចំណាកហើយឬ?

គ្រូ: មិនទាន់ទេ! ពេលដែលអ្នកច្បាស់ថា អ្នកត្រូវធ្វើចំណាកស្រុក អ្នកគួរធ្វើឱ្យប្រាកដថាអ្នកបានបំពេញជំហានសំខាន់ៗមុនពេលអ្នកចេញដំណើរ.....

? ការចូលរៀនវគ្គបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈបង្កើននូវឱកាសរកបានការងារធ្វើរបស់អ្នកក្នុងទីក្រុង។ តើអ្វីដែលអ្នកគួររកមើលពេលអ្នកជ្រើសរើសវគ្គបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈណាមួយ?

**តើខ្ញុំអាចធ្វើអ្វីបានខ្លះ?**

⇒ ស្វែងរកដំបូលន្មាននិងព័ត៌មានអំពីការធ្វើបំលាស់ទីទៅកាន់ទីកន្លែងផ្សេង និងទីផ្សារការងារពីប្រភពផ្សេងៗឱ្យបានច្រើនតាមតែអាចធ្វើបាន (ឧ: WF, LB ឬភ្នាក់នាំពលកររប្រឡប់មកវិញ)

⇒ ត្រូវមានការយល់ដឹងអំពីសិទ្ធិរបស់អ្នកនៅកន្លែងធ្វើការ និងដឹងពីរបៀបការពារសិទ្ធទាំងនោះ។

⇒ ត្រូវមានការយល់ដឹងយ៉ាងច្បាស់អំពីសុវត្ថិភាពសង្គមដែលមានសម្រាប់អ្នក (ដូចជាមណ្ឌលសុខភាព) និងរបៀបដែលអាចទៅដល់ទីនោះ។

⇒ ថតចម្លងអត្តសញ្ញាតិប័ណ្ណ សំបុត្រកំណើត និងសញ្ញាប័ត្រជំនាញ ឬការអប់រំផ្សេងៗ។

⇒ ប្រសិនបើអ្នកមិនទាន់មានការងារធ្វើ អ្នកត្រូវប្រាកដថាអ្នកមានប្រាក់គ្រប់គ្រាន់ដើម្បីធ្វើដំណើរ និងចិញ្ចឹមខ្លួនឯងបានក្នុងរយៈពេលពីរបីសប្តាហ៍ដំបូងក្នុងទីក្រុង។

____________________

____________________

____________________

____________________

នេះគ្រាន់តែជាតារាងត្រួតពិនិត្យ ហើយវាមិនទាន់គ្រប់គ្រាន់នោះទេ។ ពិនិត្យមើលផ្ទាំងរូបភាពសម្រាប់តារាង **ពេញលេញ**។

**តើអ្វីជាការធ្វើបំលាស់ទីទៅកាន់ទីកន្លែងផ្សេងដោយសុវត្ថិភាព?**

ការធ្វើបំលាស់ទីទៅកាន់ទីកន្លែងផ្សេងដោយសុវត្ថិភាពមានន័យថា អ្នកបានជ្រើសជំហានជាច្រើនដើម្បីការពារខ្លួនរបស់អ្នកចាប់តាំងពីមុនពេលចេញដំណើរ រហូតដល់ពេលដែលអ្នកត្រឡប់មកវិញ។ ប្រសិនបើការរៀបចំ និងការប្រុងប្រយ័ត្នសមរម្យត្រូវបានប្រព្រឹត្ត ទាំងអ្នកធ្វើចំណាកស្រុកផ្លូវការ និង ការធ្វើបំលាស់ទីទៅកាន់ទីកន្លែងផ្សេងក្រៅផ្លូវការអាចមានសុវត្ថិភាព។

ការធ្វើបំលាស់ទីទៅកាន់ទីកន្លែងផ្សេងផ្លូវការគឺមានការចុះបញ្ជី និងប្រព្រឹត្តឡើងដោយភ្នាក់ងារការងារដែលមានអាជ្ញាប័ណ្ណ ដោយមានការព្រមព្រៀងជាមួយសហគ្រាស និងសាលាវិជ្ជាជីវៈ ឬការិយាល័យការងារក្នុងស្រុក។ ថ្វីបើការធ្វើបំលាស់ទីទៅកាន់ទីកន្លែងផ្សេងផ្លូវការកាន់តែមានលក្ខខណ្ឌជាធម្មតាក៏ដោយ ក៏អ្នកធ្វើបំលាស់ទីទៅកាន់ទីកន្លែងផ្សេងភាគច្រើនបំផុតចូលចិត្តការធ្វើបំលាស់ទីក្រៅផ្លូវការដែលរួមបញ្ចូលទាំងទំនាក់ទំនងផ្ទាល់ខ្លួន ភ្នាក់ងារមិនមានអាជ្ញាប័ណ្ណ ឬឈ្មួញកណ្តាល ហើយនិងការធ្វើបំលាស់ទីទៅកាន់ទីកន្លែងផ្សេងដោយខ្លួនឯង។ ប្រមាណជា ៨៨%នៃអ្នកធ្វើបំលាស់ទីដើម្បីការងារនៅតែរកការងារតាមរយៈមិត្តភក្តិ បងប្អូន និងមនុស្សដែលស្គាល់។ អ្នកធ្វើបំលាស់ទីទៅកាន់ទីកន្លែងផ្សេងទុកចិត្តបណ្តាញផ្ទាល់ខ្លួនទាំងនោះ ប៉ុន្តែព័ត៌មានដែលពួកគេផ្តល់ឱ្យប្រហែលជាមិនអាចទុកចិត្តបាន ឬត្រឹមត្រូវនោះទេ ព្រមទាំងមានកំណត់ទៀតផង។

# មេរៀនទី ៦: ទីក្រុងធំ

🕑 រយៈពេលបង្រៀនៈ ១ម៉ោង ៣០នាទី

☑ ការត្រៀមលក្ខណៈ

មុនពេលបង្រៀនលោកគ្រូ អ្នកគ្រូត្រូវ

- អាន និងពិនិត្យមេរៀនដោយហ្មត់ចត់ និងធ្វើកិច្ចតែងការបង្រៀន
- ពិនិត្យមើលឯកសារសិស្ស ដើម្បីចង់ដឹងថាតើមានព័ត៌មាន និងសំណួរ សម្រាប់សកម្មភាពត្រូវនឹងការបង្រៀនដែរឬទេ
- សរសេរសំណួរលើក្ដារខៀន ឬនៅលើក្រដាសផ្ទាំងធំ  ប្រសិនបើសិស្សមានឯកសារ គេអាចមើលព័ត៌មាននេះនៅក្នុងសៀវភៅរបស់គេបាន
- មើលកាលវិភាគប្រចាំថ្ងៃ
- រៀបចំបន្ទប់រៀន (តុ កៅអី ក្ដារខៀន...)។

📖 សម្ភារឧបទេស ធនធានដែលត្រូវការ

- ឯកសារ ៦.១ សម្រាប់សិស្ស
- ឯកសារ ៦.២ សម្រាប់សិស្ស។

☼ វត្ថុបំណង

នៅពេលរៀនមេរៀននេះចប់ សិស្សនឹងអាច ៖

- ចែករំលែកបទពិសោធន៍អំពីការធ្វើដំណើរទៅកាន់ទីក្រុងភ្នំពេញ។
- ពណ៌នាពីគុណវិបត្តិ និងគុណសម្បត្តិនៃការរស់នៅក្នុងទីក្រុង។
- កត់សម្គាល់ទីកន្លែងសំខាន់ៗក្នុងទីក្រុងភ្នំពេញ។

🕑 ១៥ នាទី

## សេចក្តីផ្តើម

👄 យើងនឹងលេងល្បែងកំសាន្តមួយដែលមានឈ្មោះថា "តើខ្ញុំជាអ្វី"។ សម្រាប់ល្បែងនេះ យើងត្រូវបង្កើតជាបញ្ជីការងារមួយនៅលើក្ដារខៀន។ នោះអាចជាការងារគ្រប់ប្រភេទនៅជនបទ ឬទីក្រុង។ អ្នកគ្រប់គ្នាដែលស្គាល់ពីការងារនោះឡើងមកសរសេរនៅលើក្ដារខៀន។

គូសក្ដារខៀនជាបីជួរ។ ជួរទីមួយសរសេរពាក្យ "ទីក្រុង" ជួរទីពីរ "ជនបទ" និងជួរទីបី "ទីក្រុងនិងជនបទ"។ *អនុញ្ញាតឱ្យសិស្សឡើងមកសរសេរប្រភេទការងារផ្សេងៗ។*

ឥឡូវយើងទទួលបានការងារជាច្រើន។ ខ្ញុំត្រូវការអ្នកស្ម័គ្រចិត្តម្នាក់មកខាងមុខ។ អ្នកនឹងទទួល បានក្រដាសមួយដែលបិទនៅលើថ្ងាស ឬខ្នងរបស់អ្នក។ អ្នកត្រូវស្វែងរកថាការងារណាមួយនៅលើក្រដាសនោះ។ បញ្ហាគឺ អ្នកអាចសួរសំណួរដែលអាចឆ្លើយជាមួយចម្លើយ "បាទ/ចាស និង ទេ" តែប៉ុណ្ណោះ។ តើអ្នកទាំងអស់គ្នាយល់ពីដំណើរការនេះទេ?

✋ អ្នកអាចឱ្យអ្នកស្ម័គ្រចិត្តជាច្រើននាក់មកលេងល្បែងនេះ។ ប្រសិនបើវាពិបាកពេក អ្នកអាចអនុញ្ញាតឱ្យអ្នកស្ម័គ្រចិត្តសុំ "សញ្ញាបង្ហាញ" មួយ។

**សកម្មភាពសំខាន់។** ⏱ ៤០ នាទី

យើងទាំងអស់គ្នាដឹងថា រាជធានីនៃប្រទេសកម្ពុជាគឺ "ភ្នំពេញ"។

តើមានអ្នកណាធ្លាប់ទៅទីក្រុងភ្នំពេញទេ?
តើអ្នកទៅជាមួយអ្នកណា?
តើមូលហេតុអ្វីអ្នកទៅទីនោះ?
តើអ្នកចូលចិត្តឬយល់ឃើញយ៉ាងដូចម្ដេចដែរ?

មុនពេលយើងចាប់ផ្ដើមស្វែងយល់ពីទីក្រុងភ្នំពេញ ខ្ញុំចង់ដឹងថាតើអ្នកបានស្គាល់ទីក្រុងភ្នំពេញប៉ុណ្ណាដែរ។ ចូរពិនិត្យមើលថាតើយើងអាចបង្កើតជាបញ្ជីមួយអំពីអ្វីដែលយើងបានឃើញក្នុងទីក្រុងភ្នំពេញ។ អ្នកទាំងអស់គ្នានៅក្នុងក្រុមមានពេលពីរនាទីដើម្បីគិតពីអ្វីដែលអ្នកអាច គិតឃើញឱ្យច្រើនបំផុតតាមតែអាចធ្វើបាន។ ចូរយកចិត្តទុកដាក់ អ្នកត្រូវ បង្កើតជាក្រុមជាមួយសិស្សដែលមានតួអក្សរត្រកូលដូចគ្នា។ក្រុមខ្លះនឹងជាក្រុមធំហើយខ្លះទៀតជាក្រុមតូច។ចូរចាប់ផ្ដើមស្វែងរកគ្នា។

អនុញ្ញាតឱ្យសិស្សបង្កើតជាក្រុមដោយផ្អែកលើតួអក្សរនៃត្រកូល។ ប្រសិនបើនរណាម្នាក់នៅតែឯង ចូរបញ្ចូលគេទៅក្នុងក្រុមដែលមានសមាជិកតិច។ នៅពេលពួកគេបង្កើតជាក្រុមរួចហើយ ទុកពេលឱ្យពួកគេ២នាទីដើម្បីគិត និងបង្កើតជាបញ្ជីមួយ។ បញ្ជីនោះអាចប្រហែលគ្នា នឹងបញ្ជីនៅក្នុងសេចក្ដីណែនាំគ្រូ។

តើក្រុមណាអាចឡើងមកអានបញ្ជីរបស់ខ្លួននៅខាងមុខក្ដារខៀននេះបាន?
សិស្សទាំងអស់អាចពិនិត្យបញ្ជីរបស់ពួកគេ និងមើលថាមានអ្វីត្រូវបន្ថែមទៀត។
ក្រោយពេលបញ្ចប់កិច្ចការនេះ ណែនាំឱ្យប្រៀបធៀបភូមិរបស់ពួកគេជាមួយទីក្រុងភ្នំពេញ។ តាមតារាងខាងក្រោមៈ

| ទីក្រុងភ្នំពេញ - ភូមិរបស់ខ្ញុំ | | |
|---|---|---|
| ដូចគ្នា | ខុសគ្នា | គំនិតយោបល់ |
| | | |

អ្នកអាចបញ្ចូលចំណុចមួយចំនួនដែលអ្នកបានសរសេរ។ នៅក្នុងប្រអប់ចុងក្រោយ (ប្រអប់គំនិតយោបល់) ខ្ញុំចង់ឱ្យអ្នកសរសេរគំនិតយោបល់របស់អ្នកអំពីវត្ថុនោះ។តើអ្វីខ្លះដែលអ្នកចូលចិត្តអំពីភាពដូចគ្នា ឬខុសគ្នានេះ? ឬក៏ប្រហែលជាអ្នកមិនចូលចិត្តវត្ថុនោះទាល់តែសោះ។ ព្យាយាមពិភាក្សា ជាមួយមិត្តរួមក្រុមរបស់អ្នកដែលទើបតែបានធ្វើការជាមួយអម្បាញ់មិញ។ សកម្មភាពនេះអាចមានការពិបាក ប៉ុន្តែចូរចងចាំនូវអ្វីដែលអ្នកបានរៀនពីមុខងាររបស់អ្នកដឹកនាំក្រុម។ លើកនេះមនុស្សដែលមានអាយុច្រើនជាងគេបំផុតនៅក្នុងក្រុមគឺជាអ្នកដឹកនាំ។ គេត្រូវធ្វើឱ្យប្រាកដថា អ្នកគ្រប់គ្នានៅក្នុងក្រុមបានចែករំលែកព័ត៌មានឱ្យគ្នា។ លេខាគឺជាអ្នកកត់ត្រាគ្រប់ព័ត៌មាននៅក្នុងបញ្ជីនោះ។

ទុកពេល១៥នាទីឱ្យសិស្សធ្វើការពិភាក្សា។ ជាជំហានបន្ទាប់ អ្នកគួរបំបែកក្រុមធំទៅជាក្រុមតូចៗ ដែលមានសមាជិក ៥ ឬ ៦នាក់។ នេះធ្វើឲ្យប្រាកដថា អ្នកគ្រប់គ្នានៅក្នុងក្រុមមានឱកាសក្នុង ការបញ្ចេញមតិ។ បន្ទាប់ពីនេះ អ្នកអាចឱ្យសិស្សផ្ដល់មតិយោបល់។
តើក្រុមណាអាចរៀបរាប់ពីភាពខុសប្លែកគ្នាមួយចំនួន?

តើអ្វីជាមតិយោបល់ទូទៅអំពីភាពខុសប្លែកគ្នា?

ភ្នំពេញជារាជធានីរបស់ប្រទេសកម្ពុជា។ មានប្រជាជនប្រហែល២លាននាក់កំពុងរស់នៅ។ វាគឺជាកន្លែងមួយដែលពោរពេញទៅដោយមនុស្ស ជាពិសេសគឺចំណុចកណ្តាល។ មានរឿងព្រេង មួយដែលដំណាលពីការកកើតទីក្រុងភ្នំពេញ។ រឿងនេះនិយាយថា ភ្នំពេញត្រូវបានបង្កើតឡើង នៅពេលដែលដូនចាស់ម្នាក់ឈ្មោះពេញ បានប្រទះឃើញព្រះពុទ្ធរូប ៤ ព្រះអង្គនៅក្នុងដើមគគីរ ដែលអណ្តែតតាមទឹកទន្លេមេគង្គមកជាប់នឹងច្រាំងទន្លេ។

ដូនពេញបានយកព្រះពុទ្ធរូបទាំងបួនអង្គនោះតម្កល់នៅក្នុងអាស្រមដែលគាត់បានសាងសង់នៅក្បែរទួលមួយ ។ ដោយចេះតែមានការរីកចម្រើន និងមានប្រជាជនតាំងទីលំនៅច្រើនឡើងៗផង ទីនោះក៏ត្រូវគេហៅថា "ភ្នំដូនពេញ" ហើយក្រោយមកក៏ក្លាយជាភ្នំពេញ។ មានផ្លូវធំៗជាច្រើនខ្វាត់ខ្វែងពេញទីក្រុង។ ផ្លូវទាំងនោះពោរពេញទៅដោយឡាន និងម៉ូតូជាច្រើន។ ដូច្នេះចរាចរណ៍គឺពិតជាមានគ្រោះថ្នាក់ណាស់។

អ្នកត្រូវតែដឹងពីច្បាប់ចរាចរណ៍ ព្រោះមានប៉ូលីសជាច្រើនធ្វើការត្រួតពិនិត្យ ថាតើអ្នកបានឈប់ ពេលភ្លើងក្រហម ឬទេ? តើអ្នកបានពាក់មួកសុវត្ថិភាពដែរឬទេ?

នៅក្នុងទីក្រុងមានអគារស្រស់ស្អាតជាច្រើន ហើយខ្លះមានលក្ខណៈចាស់ ដូចជាវត្តភ្នំ ឬព្រះបរមរាជវាំង។ នៅមានអគារថ្មី និងផ្ទះល្វែងធំៗជាច្រើនដូចជា អគារកម្ពស់ ៤២ជាន់ ដែលត្រូវបានសាងសង់ ហើយកន្លែងជាច្រើនដែលអ្នកក្រឡេកមើល គឺមានមនុស្សកំពុងស្ថាបនាផ្ទះ និងហាង ផ្សារទំនើបជាច្រើនទៀត។

រដ្ឋាភិបាលមានអគារ (ក្រសួង) ជាច្រើនក្នុងទីក្រុងភ្នំពេញ រីឯនៅជាយក្រុងគឺមានរោងចក្រធំៗជាច្រើន។ ជារៀងរាល់ព្រឹក អ្នកអាចឃើញរថយន្តដឹកមនុស្ស(ភាគច្រើនជាស្ត្រី)ធ្វើដំណើរឆ្ពោះទៅរោងចក្រទាំងនោះ។

ប្រសិនបើអ្នកមកពីភូមិតូចមួយ វាអាចមានភាពលំបាកក្នុងការស្វែងរកផ្លូវរបស់អ្នក។ វាងាយស្រួលក្នុងការវង្វេងទិស។ ទូរស័ព្ទអាចជួយអ្នកក្នុងការសួរផ្លូវ ពីមនុស្សដែលស្គាល់ទីក្រុងច្បាស់ជាងអ្នក។

មនុស្សជាច្រើននៅក្នុងទីក្រុងភ្នំពេញ ព្យាយាមចងចាំផ្លូវដោយស្គាល់នូវទីតាំងអគារសំខាន់ៗ ដូចជាផ្សារថ្មី ខ្ញុំនឹងពិនិត្យមើលថា តើអ្នកស្គាល់អគារទាំងនោះបានប៉ុណ្ណាដែរ?។

ខ្ញុំនឹងផ្តល់ឱ្យអ្នកនូវឯកសារ ៦.១ និង ៦.២ សម្រាប់សិស្ស ។ នៅលើឯកសារនេះ អ្នកនឹងឃើញអគារជាច្រើន។

នៅលើឯកសារមួយទៀត អ្នកនឹងឃើញការពណ៌នាពីអគារទាំងនោះ។

បង្កើតជាក្រុមតូចដែលមានសមាជិក ៤នាក់ ហើយព្យាយាមធ្វើការផ្គូរផ្គងឱ្យបានត្រឹមត្រូវ។

ចែកឯកសារ ៦.១ និង ៦.២ ទៅក្រុមទាំងអស់ និងអនុញ្ញាតឱ្យពួកគេធ្វើការផ្គូរផ្គង។

## បញ្ចប់មេរៀន

៣៥ នាទី

នៅសប្តាហ៍ក្រោយយើងនឹងទៅក្នុងភូមិ ដើម្បីចែករំលែកចំណេះដឹងរបស់ពួកយើង អំពីការធ្វើបំលាស់ទីទៅកាន់កន្លែងផ្សេងមានសុវត្ថិភាព។ នៅក្នុងក្រុមដែលមានសមាជិកដូចគ្នា នៅពេលដែលបង្កើតជាផ្ទាំងរូបភាព យើងនឹងទៅផ្ទះ ឬទៅគ្រួសារណាមួយ ដើម្បីសួរពួកគេថា តើយើងអាចបិទផ្ទាំងរូបភាពរបស់ពួកយើងនៅក្បែរៗនោះបានដែរឬទេ។ ដូច្នេះយើងត្រូវការពន្យល់ពីអត្ថន័យរបស់រូបភាពដល់ពួកគេ និងប្រាប់ពីអ្វីដែលយើងបានរៀន វាជាការល្អដែលយើងត្រូវរៀបចំវាជាមុន។

កិច្ចការផ្ទះរបស់អ្នកសម្រាប់សប្តាហ៍ក្រោយគឺរៀបចំបទបង្ហាញខ្លីៗ សម្រាប់ប្រជាជនដែលអ្នកចង់ទៅ (ប្រហែលជាអ្នកជ្រើសរើសដោយខ្លួនឯង) និងពន្យល់ពួកគេអំពីផ្ទាំងរូបភាពរបស់យើង។ បន្ទាប់ពីនេះ យើងនឹងសួរពួកគេថាតើយើងអាចបិទផ្ទាំងរូបភាពនៅលើជញ្ជាំងផ្ទះបានដែរឬទេ ឬប្រហែលជានៅ លើអ្វីផ្សេងទៀត ដែលមនុស្សភាគច្រើនឆ្លងកាត់អាចមើលឃើញពីប្រធានបទរបស់ពួកយើង។

? តើអ្នកទាំងអស់គ្នាយល់កិច្ចការផ្ទះនេះឬទេ ?

*ជម្រើស(តាមចិត្ត)៖*

ប្រសិនបើនៅសល់ពេល អ្នកអាចលេងល្បែងកំសាន្តមួយៈ"ខ្ញុំកំពុងបំលាស់ទីទៅកាន់កន្លែងផ្សេង ហើយខ្ញុំយក... ទៅជាមួយខ្ញុំ"

សិស្សទាំងអស់បង្កើតជារង្វង់មួយ ឬជាបន្ទាត់មួយ។ សិស្សទីមួយនិយាយថា " ខ្ញុំនឹងបំលាស់ទីទៅកាន់កន្លែងផ្សេង ហើយខ្ញុំនឹងយក... ទៅជាមួយខ្ញុំ" គេនិយាយពីអ្វីមួយដែលចង់យកទៅជាមួយ ប្រហែលជាអត្តសញ្ញាណប័ណ្ណ អ្នកដែលនៅបន្ទាប់គេត្រូវ និយាយថា "ខ្ញុំនឹងបំលាស់ទីទៅកាន់កន្លែងផ្សេង ហើយខ្ញុំនឹងយកអត្តសញ្ញាណប័ណ្ណ និងប្រាសជុសធ្មេញរបស់ខ្ញុំទៅជាមួយខ្ញុំ"

បន្ទាប់ពីនេះ អ្នកនៅបន្ទាប់ត្រូវបន្ត ៖ "ខ្ញុំនឹងបំលាស់ទីទៅកាន់កន្លែងផ្សេង ហើយខ្ញុំនឹងយកអត្តសញ្ញាណប័ណ្ណ ប្រាសជុសធ្មេញរបស់ខ្ញុំ និងផែនទីក្រុងភ្នំពេញទៅជាមួយខ្ញុំ"

ល្បែងនេះបន្តរហូតដល់របស់ដែលត្រូវចាំមានចំនួនច្រើន ហើយមាននរណាម្នាក់ភ្លេច។ អ្នកដែលភ្លេចនោះអាចចាប់ផ្តើមសាឡើងវិញជាមួយពាក្យថ្មីទៀត។

## សេចក្តីណែនាំគ្រូ

បញ្ជីនៃអាគារ មធ្យោបាយធ្វើដំណើរ និងប្រភេទមនុស្សនៅក្នុងទីក្រុងភ្នំពេញ

| អគារ | មធ្យោបាយធ្វើដំណើរ | មនុស្ស |
|---|---|---|
| ផ្សារជាច្រើន | ឡាន | មន្ត្រីរដ្ឋាភិបាល |
| ហាងទំនិញ | រថយន្តឈ្នួល | បុគ្គលិកអង្គការ |
| គ្លីនិក | រថយន្តដឹកទំនិញ | អ្នកបើកម៉ូតូ |
| សាលារៀន | រថយន្តក្រុង | អ្នកបើករថយន្តឈ្នួល |
| សាកលវិទ្យាល័យ | ម៉ូតូកង់បី | អ្នកបើករថយន្តក្រុង |
| ក្លឹបរាត្រី | ម៉ូតូឌុប | គ្រូពេទ្យ |
| ខារ៉ាអូខេ | កង់ | គ្រូបង្រៀន |
| ភោជនីយដ្ឋាន | យន្តហោះ | អ្នកលក់ទំនិញ |
| ផ្ទះ | រថភ្លើង | បុគ្គលិកក្រុមហ៊ុនឯកជន |
| ស្ថាប័នរដ្ឋាភិបាល | រទេះអូស | អ្នកសុំទាន |
| រោងចក្រ | រឺម៉ក | ជនជាតិបរទេស |
| សណ្ឋាគារ | ម៉ូតូ | កម្មករ |
| ផ្ទះសំណាក់ | ស៊ីក្លូ | |
| ការិយាល័យអង្គការ | | |

ក្នុងការរៀបចំសម្រាប់ដំណើររបស់សិស្សទៅកាន់ភូមិ វាគឺជាការដ៏ល្អមួយ ដែលត្រូវជម្រាបលោកនាយកសាលាអំពីគំនិតដែលត្រូវពាក់ព័ន្ធនៅក្នុងភូមិ។ ប្រសិនបើមានផ្ទាំងរូបភាពជាច្រើន អ្នកអាចជម្រាបមេភូមិផងដែរ។ប្រសិនបើមានម៉ាស៊ីនថតចម្លងនៅក្នុងសាលា អ្នកអាចកែប្រែកិច្ចការបាន ជំនួសឱ្យក្រុមមួយមានផ្ទាំងរូបភាពមួយ អ្នកអាចថតចម្លងផ្ទាំងរូបភាពទាំងនោះជាច្រើនដង និងអនុញ្ញាតឱ្យសិស្សធ្វើយុទ្ធនាការតាមផ្ទះ ជាមួយផ្ទាំងរូបភាពទាំងនោះ។សិស្សអាចដើរគោះទ្វារផ្ទះជាច្រើន និងប្រាប់ប្រជាជនអំពីប្រធានបទការធ្វើបំលាស់ទីទៅកាន់កន្លែងផ្សេងមានសុវត្ថិភាព ដែលរៀនក្នុងសាលា។ កិច្ចការនេះនឹងធ្វើឱ្យផ្ទាំងរូបភាព/ខិត្តប័ណ្ណដំណើរការបានរឹតតែល្អ។ ប្រសិនបើសាលារៀននៅឆ្ងាយពីភូមិ អ្នកអាចឱ្យសិស្សជិះ កង់ទៅបាន។

# ការណែនាំពីទីកន្លែងមួយចំនួននៅទីក្រុងភ្នំពេញ




ប៉ុស្តិ៍ប្រៃសណីយ៍



គុកទួលស្លែង



ស្ថានីយ៍រថភ្លើង



រមណីយដ្ឋាន វត្តភ្នំ



ផ្សារធំថ្មី



កន្លែងកំសាន្តមាត់ទន្លេ




# ការណែនាំពីទីកន្លែងមួយចំនួននៅទីក្រុងភ្នំពេញ


អាកាសយានដ្ឋានអន្តរជាតិ ភ្នំពេញ


វិមានឯករាជ្យ


អាគារភ្លោះ ៤២ ជាន់


សួនកំសាន្តមុខ វត្តបទុមវត្តី



ផ្សារទំនើប សូរិយា


សារមន្ទីរជាតិ


ពហុកីឡាដ្ឋានជាតិអូឡាំពិក

# មេរៀនទី ៧: ផ្សព្វផ្សាយព័ត៌មាន

🕑 រយៈពេលបង្រៀនៈ ១ម៉ោង ៣០នាទី

☑ ការត្រៀមលក្ខណៈ

មុនពេលបង្រៀនលោកគ្រូ អ្នកគ្រូត្រូវ

- អាន និងពិនិត្យមេរៀនដោយហ្មត់ចត់ និងធ្វើកិច្ចតែងការបង្រៀន
- ពិនិត្យមើលឯកសារសិស្ស ដើម្បីចង់ដឹងថាតើមានព័ត៌មាន និងសំណួរ សម្រាប់សកម្មភាពត្រូវនឹងការបង្រៀនដែរឬទេ
- សរសេរសំណួរលើក្តារខៀន ឬនៅលើក្រដាសផ្ទាំងធំ ប្រសិនបើសិស្សមានឯកសារ គេអាចមើលព័ត៌មាននេះនៅក្នុងសៀវភៅរបស់គេបាន
- មើលកាលវិភាគប្រចាំថ្ងៃ
- រៀបចំបន្ទប់រៀន (តុ កៅអី ក្តារខៀន...)។

📖 សម្ភារឧបទេស ធនធានដែលត្រូវការ

- ផ្ទាំងរូបភាពរបស់សិស្ស
- ម៉ាស៊ីនថតរូប
- ស្កុតទុកសម្រាប់បិទផ្ទាំងរូបភាពនៅលើជញ្ជាំង ឬបង្គោល។

☼ វត្ថុបំណង

នៅពេលរៀនមេរៀននេះចប់ សិស្សនឹងអាចៈ

- បង្ហាញចំណេះដឹងរបស់ពួកគេតាមរយៈផ្ទាំងរូបភាព និងការបកស្រាយប្រាប់អ្នកភូមិអំពីការធ្វើបំលាស់ទីទៅកាន់កន្លែងផ្សេងមានសុវត្ថិភាព។
- បង្ហាញពីសុជីវធម៌ក្នុងទំនាក់ទំនងជាមួយប្រជាជនក្នុងភូមិ ។

🕑 ១៥ នាទី

## សេចក្តីផ្តើម

ថ្ងៃនេះ យើងនឹងទៅក្នុងភូមិ ហើយប្រាប់អ្នកភូមិអំពីការធ្វើបំលាស់ទីទៅកាន់កន្លែងផ្សេងមានសុវត្ថិភាព។ មានរបស់មួយចំនួនដែលសំខាន់សម្រាប់កិច្ចការនេះ។ ប្រសិនបើយើងមានផ្ទាំងរូបភាពតែមួយសម្រាប់ចែកយើងគួរតែឱ្យទៅគ្រូសារណាដែលត្រូវការវា។

តើអ្នកធ្វើបែបណានៅពេលមនុស្សចាស់ពីនោក់បើកទ្វារ ?

អ្នកត្រូវណែនាំខ្លួនរបស់អ្នក ប្រាប់ឈ្មោះសមាជិកក្នុងក្រុម និងមូលហេតុដែលអ្នកគោះទ្វារ របស់ពួកគាត់។ ការណែនាំខ្លួន មានលក្ខណៈបែបនេះ "ជម្រាបសួរ ពួកយើងខ្ញុំគឺជា... ពួកយើងរៀននៅសាលា...។ ពីរ-បីសប្តាហ៍កន្លងមកនេះ យើងបានរៀនបំណិនជីវិតស្តីអំពីការទប់ស្កាត់ការជួញដូរមនុស្ស។ កិច្ចការមួយរបស់ពួកយើង គឺផ្សព្វផ្សាយចំណេះដឹងរបស់ពួកយើងទៅឱ្យមនុស្សនៅក្នុងសហគមន៍របស់យើងនេះ។ តើយើងខ្ញុំអាចប្រាប់លោកពូ អ្នកមីងលោកអ៊ំបន្ថែម ទៀតអំពីគម្រោង របស់យើងខ្ញុំបានដែរឬទេ ?"

ប្រសិនបើគាត់ឆ្លើយ "បាន" អ្នកអាចបន្តទៀត។ ប៉ុន្តែបើ "មិនបានទេ" អ្នកត្រូវនិយាយពាក្យ "អរគុណសម្រាប់ការចំណាយពេលវេលាសូមជម្រាបលា"។ ផ្ទាំងរូបភាពអាចភ្ជាប់ជាមួយស្កុតខ្ញុំមានស្កុតមួយចំនួននៅលើតុរបស់ខ្ញុំសម្រាប់ខ្ចី។ វិន័យខ្លះៗ ៖

១. កុំចូលទៅក្នុងផ្ទះណាមួយតែម្នាក់ឯង
២. នៅពេលជិះកង់ កុំជិះទន្ទឹមគ្នាលើសពីពីរនាក់
៣. ត្រូវចេះគួរសមចំពោះមនុស្សគ្រប់គ្នា
៤. ប្រសិនបើប្រជាជន អ្នកភូមិចង់ដឹងបន្ថែមទៀតអំពីគម្រោង ឬមានមតិយោបល់ អ្នកអាចប្រាប់ពួកគេឱ្យមកទាក់ទងសាលារៀន។ ឱ្យលេខទូរស័ព្ទរបស់អ្នកទៅសិស្សទុកសម្រាប់ទាក់ទងពេលមានបញ្ហាបន្ទាន់ ណែនាំសិស្សឱ្យត្រឡប់មកសាលារៀនវិញតាមពេលកំណត់។

## សកម្មភាពសំខាន់។ ⏲ ៦០ នាទី

សិស្សទៅក្នុងភូមិ ឬសហគមន៍។ វាជាការល្អ ដែលអ្នកចូលរួមជាមួយក្រុមមួយចំនួន ដើម្បីពិនិត្យរបៀបសហការនិងជម្រាបអ្នកភូមិ។ ការយកម៉ាស៊ីនថតរូបទៅជាមួយអ្នក ដើម្បីថតការខំប្រឹងប្រែងនេះទុកជាឯកសារ អាចមានប្រយោជន៍ដើម្បីបង្ហាញសិស្សដទៃ និងឪពុកម្តាយ ហើយប្រហែលជាអាចប្រើនៅក្នុងព្រឹត្តិប័ត្រព័ត៌មានផងដែរ។

## បញ្ចប់មេរៀន ⏲ ១៥ នាទី

ល្បែងនេះលេងនៅពេលសិស្ស ដែលត្រឡប់មកសាលាវិញ។ អ្នកនឹងត្រូវការប័ណ្ណពីឯកសារ ៦.១ និង ៦.២ សម្រាប់សិស្ស។រៀបប័ណ្ណជារង្វង់ធំមួយលើទីធ្លា(លើដី)។ ប័ណ្ណទាំងនោះត្រូវតែអាចមើលឃើញ ប៉ុន្តែសិស្សមិនចាំបាច់ឃើញអ្វីដែល សរសេរនៅលើនោះទេ ពេលឈរនៅកណ្តាលរង្វង់នៃប័ណ្ណនោះ។

អ្នកនៅក្នុងទីក្រុងភ្នំពេញជាមួយមិត្តរបស់អ្នកត្រូវកាន់ដៃមិត្តរបស់អ្នក។ អ្នកត្រូវការបង្កើតជាដៃគូ។ បន្ទាប់ពីនោះអ្នកត្រូវទៅឈរនៅចំណុចកណ្តាលនៃរង្វង់ ខ្ញុំនឹងប្រាប់ពីដំណើរក្នុងទីក្រុងដែលយើងទៅ។ យើងនឹងឈប់នៅចំណុចណាមួយច្បាស់លាស់ ហើយខ្ញុំនឹងណែនាំអ្នក។ ខ្ញុំនឹងប្រាប់អ្នកខ្លះៗអំពីអគារនេះ ហើយពេលដៃគូរបស់អ្នកដឹងថាអគារណាមួយនោះអ្នកត្រូវរត់ទៅកាន់វា។ គូទីមួយដែលចាប់បានប័ណ្ណត្រឹមត្រូវគឺជាអ្នកឈ្នះ។ បន្ទាប់ពីនេះ យើងត្រឡប់មកកណ្តាលរង្វង់ ហើយលេងម្តងទៀត។

លេងល្បែងនេះ អាស្រ័យលើព័ត៌មានដែលជារបស់រូបភាពទាំងនោះ។ អ្នកអាចនិយាយអំពីរូបភាព ប្រវត្តិ និងមុខងាររបស់វា។ នៅពេលសិស្សទាំងអស់បានត្រឡប់មកពីភូមិវិញ អ្នកអាចឱ្យពួកគេផ្តល់មតិយោបល់ ប្រសិនបើនៅសល់ពេល។

តើប្រតិកម្មណាខ្លះដែលអ្នកទទួលបាន?
តើប្រជាជនបានដឹងរួចហើយអំពីប្រធានបទនេះឬ?
តើអ្នកបានបិទផ្ទាំងរូបភាពរបស់អ្នកនៅកន្លែងណាខ្លះ?
អរគុណជាអនេកសម្រាប់ការខំប្រឹងប្រែងរបស់អ្នក ចំពោះយុទ្ធនាការនេះ។ ខ្ញុំនឹងជួបអ្នកទាំងអស់គ្នា នៅសប្តាហ៍ក្រោយទៀត។

## សេចក្តីណែនាំគ្រូ

ប្រសិនបើមានម៉ាស៊ីនថតចម្លងនៅក្នុងសាលា អ្នកអាចកែប្រែកិច្ចការបាន។ ជំនួសឱ្យក្រុមមួយមានផ្ទាំងរូបភាពមួយ អ្នកអាចថតចម្លងផ្ទាំងរូបភាពទាំងនោះជាច្រើនដង និងអនុញ្ញាតឱ្យសិស្ស ធ្វើយុទ្ធនាការតាមផ្ទះ ជាមួយផ្ទាំងរូបភាពទាំងនោះ។ សិស្សអាចដើរទៅតាមផ្ទះជាច្រើន និងប្រាប់ប្រជាជនអំពីប្រធានបទ ការទប់ស្កាត់ការជួញដូរមនុស្ស ដែលរៀនក្នុងសាលា។ កិច្ចការនេះនឹងធ្វើឱ្យផ្ទាំងរូបភាព ខិត្តប័ណ្ណដំណើរការបានរឹតតែល្អ។

*ចូរធ្វើការទំនាក់ទំនងជាមួយប៉ូលីសមូលដ្ឋាន និងមេភូមិ ប្រសិនបើចាំបាច់។*

# មេរៀនទី ៨: ការមកដល់ទីក្រុង

🕑 រយៈពេលបង្រៀនៈ ១ម៉ោង ៣០នាទី

☑ ការត្រៀមលក្ខណៈ

មុនពេលបង្រៀនលោកគ្រូ អ្នកគ្រូត្រូវ

- អាន និងពិនិត្យមេរៀនដោយហ្មត់ចត់ និងធ្វើកិច្ចតែងការបង្រៀន
- ពិនិត្យមើលឯកសារសិស្ស ដើម្បីចង់ដឹងថាតើមានព័ត៌មាន និងសំណួរ សម្រាប់សកម្មភាពត្រូវនឹងការបង្រៀនដែរឬទេ
- សរសេរសំណួរលើក្តារខៀន ឬនៅលើក្រដាសផ្ទាំងធំ ប្រសិនបើសិស្សមានឯកសារ គេអាចមើលព័ត៌មាននេះនៅក្នុងឯកសាររបស់គេបាន
- មើលកាលវិភាគប្រចាំថ្ងៃ
- រៀបចំបន្ទប់រៀន (តុ កៅអី ក្តារខៀន...)។

📖 សម្ភារឧបទេស ធនធានដែលត្រូវការ

- ឯកសារ ៨.១ សម្រាប់សិស្ស រឿងរបស់.... (នៅលើក្រដាសពីរដាច់ពីគ្នា បើអាចបាន)
- សៀវភៅកំប្លែងដើម្បីបង្ហាញសិស្សទុកជាឧទាហរណ៍

☼ វត្ថុបំណង

នៅពេលរៀនមេរៀននេះចប់ សិស្សនឹងអាច ៖

- បង្ហាញពីបញ្ហាសាមញ្ញៗបំផុតរបស់អ្នកធ្វើចំណាកស្រុកវ័យក្មេង
- ធ្វើសកម្មភាពការពារ/រារាំងចំពោះឈ្មួញជួញដូរដែលអាចកើតមាន ។

🕑 ២០ នាទី

## សេចក្តីផ្តើម

👄 ក្រោយពីរៀនទទួលបាននូវគំនិតសំខាន់ៗជាច្រើនអំពីកន្លែងដែលត្រូវយកចិត្តទុកដាក់ នៅពេលនរណាម្នាក់ហៅបបួលអ្នកឱ្យទៅធ្វើការនៅទីក្រុង។ យើងក៏បានរៀនអំពីល្បិចកលនិងយុទ្ធសាស្ត្រ ដែលត្រូវបានប្រើប្រាស់ដើម្បីល្បួងបញ្ឆោតអ្នកឱ្យធ្លាក់ក្នុងស្ថានភាពគ្រោះថ្នាក់។ប៉ុន្តែនៅក្នុងទីក្រុងក៏អាចមានឱកាសល្អផងដែរវាមិនសុទ្ធតែអាក្រក់ក្នុងការធ្វើចំណាកស្រុក និងស្វែងរកការងារល្អៗនោះទេ។ ថ្ងៃនេះនឹងសន្មត់ថា យើងរកបានការងារមួយនៅក្នុងទីក្រុង ហើយយើងទើបតែមកដល់។ យើងនៅឆ្ងុំ...ក្នុងទីក្រុងភ្នំពេញ មានឡានជាច្រើនបើកទៅមកៗ មានអគារធំៗជាច្រើនមានមនុស្សម្នាជាច្រើន។ មានចំណុចមួយចំនួន ដែលអ្នកអាចប្រើប្រាស់បាន នៅពេលអ្នកមកដល់ទីក្រុងភ្នំពេញជាលើកដំបូង។

១. កុំធ្វើដំណើរតែម្នាក់ឯង

*ក្រុមផ្តល់នូវការគាំទ្រ បណ្តាញសង្គម និងសុវត្ថិភាពខ្ពស់។*

២. កុំទាក់ទងជាមួយមនុស្សប្លែកមុខដែលមកទាក់ទងអ្នកនៅតាមផ្លូវ ឬលើឡាន

*ពួកគេអាចជាឈ្មួញជួញដូរមនុស្ស ហើយនេះជាវិធីមួយដែលពួកគេប្រើ។*

៣. កុំឱ្យលិខិតឆ្លងដែន ឬអត្តសញ្ញាណប័ណ្ណទៅមនុស្សដែលអ្នកមិនស្គាល់។

*ប្រសិនបើអ្នកមានមន្ទិលសង្ស័យ ត្រូវធ្វើការទំនាក់ទំនងជាមួយអាជ្ញាធរ ឬលេខទូរស័ព្ទ មួយក្នុងចំណោមលេខទូរស័ព្ទនានាក្នុងមេរៀនទី៨ សុវត្ថិភាពកុមារ ឬប៉ូលីស។ វាជាការឆ្លាតវៃក្នុងការដាក់ឯកសារថតចម្លងនៃ អត្តសញ្ញាណ*

*ប័ណ្ណតាមខ្លួនដើម្បីឱ្យនរណាម្នាក់ដែលទាមទារចង់បានវា។*

ស្វែងរកកន្លែងសុវត្ថិភាពដើម្បីរស់នៅគឺជារឿងសំខាន់។
តើអ្នកមានជម្រើសណាខ្លះ ក្នុងការស្វែងរកផ្ទះ?

តើអ្នកមានបងប្អូនដែរឬទេ? (មិនមានទ)។ តើអ្នកគួរទៅជាមួយបុរសម្នាក់ ដែលបបួលអ្នកឱ្យទៅរស់នៅជាមួយគាត់ ព្រោះគាត់មានបន្ទប់ទំនេរមួយ? (ទេ) អ្នកគួរស្វែងរកព័ត៌មានបន្ថែម ទៀតសិន។

វាជាការល្អប្រសើរបំផុត ប្រសិនបើអ្នកជួលផ្ទះ ។ អ្នកអាចជួលនៅម្នាក់ឯង ឬជាមួយអ្នកដទៃ ដើម្បីកាត់បន្ថយការចំណាយថ្លៃឈ្នួល។ ផ្ទះនៅក្នុងទីក្រុងភ្នំពេញមានតម្លៃថ្លៃ ហើយវាមិនដូចនឹងផ្ទះដែលអ្នកមាន នៅក្នុងភូមិរបស់អ្នកទេ។ មានឱកាសជាច្រើនក្នុងការស្វែងរកផ្ទះ ឱកាសទាំងនោះមានដូចជា :

១. ថៅកែផ្តល់កន្លែងស្នាក់នៅដោយមិនគិតថ្លៃ ប៉ុន្តែត្រូវចែករំលែកជាមួយអ្នកដទៃ។
២. សុំដំបូន្មានពីអ្នកធ្វើបំលាស់ទីទៅកាន់កន្លែងផ្សេងៗទៀត។
៣. ប្រើភ្នាក់ងារ តែត្រូវប្រយ័ត្នជាមួយជម្រើសនេះដោយសារមនុស្សមួយចំនួនមានបំណងមិនល្អ។
៤. ស្វែងរកផ្ទះដោយខ្លួនឯងដោយការរកមើលស្លាក "សម្រាប់ជួល" ក្នុងតំបន់ដែលអ្នកធ្វើការ។

ប្រសិនបើអ្នករកផ្ទះបានហើយ វាជាការល្អដែលត្រូវធ្វើកិច្ចសន្យាជួល។
ហេតុអ្វីការធ្វើកិច្ចសន្យាមានសារៈសំខាន់?
តើអ្នកគួរដាក់បញ្ចូលក្នុងកិច្ចសន្យានោះនូវចំណុចសំខាន់អ្វីខ្លះ?

កិច្ចសន្យាគឺជាឯកសារដែលអាចយកជាការបាន ប្រសិនបើត្រូវបានចុះហត្ថលេខាដោយភាគីទាំងពីរគឺជាឯកសារច្បាប់ពេញលេញដើម្បីការពារសិទ្ធិរបស់អ្នក។ នេះគឺខុសគ្នាពីការព្រមព្រៀងតាមពាក្យសំដីដែលមិនអាចបញ្ជាក់ចំពោះអ្នកដទៃ។ នៅក្នុងឯកសារជួល អ្នកគួរតែដាក់បញ្ចូលនូវចំណុចខាងក្រោម៖

១. អត្តសញ្ញាណលម្អិតអំពីអ្នកជួលឱ្យ និងអ្នកជួល(ម្ចាស់ផ្ទះ និងអ្នក)។ នេះរួមមាន៖ អាសយដ្ឋាន លេខទូរស័ព្ទ លេខអត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែន។
២. អាសយដ្ឋាន ឬទីតាំងនៃអចលនទ្រព្យ(ផ្ទះ)ដែលអ្នកចង់ជួល។
៣. ចំនួនថ្លៃឈ្នួលផ្ទះដែលបានព្រមព្រៀងក្នុងមួយខែៗ និងអ្វីខ្លះដែលវាបានគិតបញ្ចូលដូចជាថ្លៃទឹក ថ្លៃភ្លើងជាដើម។
៤. ចំនួនប្រាក់កក់ដែលអ្នកបានបង់។
៥. នៅពេលណាដែលកិច្ចសន្យាចាប់ផ្តើម និងពេលណាបញ្ចប់។
៦. លក្ខខណ្ឌនៃកិច្ចសន្យាមានអ្វីខ្លះ (ពេលណា និងរបៀបដែលអ្នកអាចបញ្ចប់កិច្ចសន្យាមុនពេលកំណត់)

កិច្ចសន្យាគឺមានសុពលភាព លុះត្រាតែភាគីទាំងពីរបានចុះហត្ថលេខាលើវា។ ចូរប្រាកដថា អ្នកយកកិច្ចសន្យាមួយច្បាប់មករក្សាទុកផ្ទាល់ខ្លួន។ វាមិនមែនតែងតែងាយស្រួលក្នុងការរស់នៅក្នុងទីក្រុងភ្នំពេញនោះទេ។

តើអ្នកគិតថាអ្នកនឹងជួបប្រទះបញ្ហាណាខ្លះ?
*ចម្លើយអាចមាន ៖ ភាពឯកោ វង្វេងផ្លូវ មិនដឹងពីកន្លែងទិញម្ហូប...។*

បញ្ហាមួយទៀតគឺ ពេលខ្លះមនុស្សនៅក្នុងទីក្រុងមើលងាយអ្នកដែលមកពីជនបទ។ នេះដោយសារតែពួកគេមិនបានស្វែងយល់ស៊ីជម្រៅពីជីវិតនៅតាមខេត្ត/ជនបទ។ ពួកគេមិនយល់ពីស្ថានភាព ដែលអ្នកកំពុងរស់ ហើយអ្នកក៏ប្រហែលជាគិតថា វាពិបាកស្វែងយល់ពីរបៀបរស់នៅក្នុងទីក្រុងរបស់ពួកគេ (អ្នកទីក្រុង)។ នេះជាការធម្មតាទេ។

វាជាការល្អក្នុងការនិយាយជាមួយអ្នកធ្វើការធ្វើបំលាស់ទីទៅកាន់កន្លែងផ្សេងផ្សេងទៀតអំពីបញ្ហានេះ។ ប្រសិនបើអ្នកគិតថា

ពិបាកក្នុងការរស់នៅក្នុងទីក្រុង អ្នកអាចធ្វើកិច្ចការជាច្រើនបានដូចជា ៖

- បង្កើតមិត្តភាពជាមួយអ្នកដទៃ។
- បរិភោគអាហារដែលនាំឱ្យមានសុខភាពល្អ និងរក្សាភាពឧស្សាហ៍ព្យាយាមដែលអាច ធ្វើឱ្យអារម្មណ៍អ្នកបានប្រសើរ។
- ស្វែងរកមជ្ឈមណ្ឌលសហគមន៍ដើម្បីប្រាប់អ្នកអំពីសេវាកម្មនានាសម្រាប់អ្នកធ្វើបំលាស់ទីទៅកាន់កន្លែងផ្សេង
- រក្សាទំនាក់ទំនងជាធម្មតាជាមួយគ្រួសារ ប្រាប់ពួកគេអំពីភាពលំបាក និងការខំប្រឹងប្រែងរបស់អ្នក
- សរសេរសៀវភៅកំណត់ហេតុប្រចាំថ្ងៃដើម្បីបង្ហាញពីអារម្មណ៍របស់អ្នក ឬគូរជាគំនូរ ដើម្បីឱ្យមានភាពច្បាស់លាស់។ នេះក៏អាចជួយអ្នកឱ្យមើលឃើញពីដំណោះស្រាយ ចំពោះបញ្ហារបស់អ្នក។

## សកម្មភាពសំខាន់។

🕑 ៦០ នាទី

ដូចអ្វីដែលអ្នកបានឃើញ មានភាពលំបាក និងបញ្ហាជាច្រើនដែលអ្នកត្រូវយកចិត្តទុកដាក់។ ចូរពិនិត្យមើលតើអ្នកអាចចាំអ្វីទាំងអស់នោះបានប៉ុណ្ណា ឬអ្នកប្រហែលជាមើលក្នុងសៀវភៅ របស់អ្នក។

ខ្ញុំនឹងនិយាយរឿងមួយឱ្យអ្នកទាំងអស់គ្នាស្តាប់ (សេចក្តីណែនាំគ្រូ)។

នេះជារឿងកំប្លែងដែលអ្នកអាចគូរ ឬបង្កើតជារូបភាពដោយខ្លួនរបស់អ្នក។

គោលបំណងគឺដើម្បីបង្កើតរឿងមួយអំពីមនុស្សម្នាក់ ឬពីរនាក់ដែលកំពុងធ្វើចំណាកស្រុកទៅទីក្រុង។ ពួកគេជួបប្រទះឧបសគ្គជាច្រើន ហើយត្រូវដោះស្រាយវា។ អ្នកអាចគិតអំពីគ្រោះថ្នាក់ដែលអាចកើតមាន (ស្ថានភាពល្អឬអាក្រក់ដែលអាចកើតឡើងចំពោះពួកគេ) ។ អ្នកក៏អាចគិតអំពីរបៀបដោះស្រាយឧបសគ្គទាំងនោះសម្រាប់ពួកគេផងដែរ។

ចែកឯកសារ ៨.១ សម្រាប់សិស្ស និងខ្មៅដៃពណ៌ទៅឱ្យសិស្ស។

អ្នកអាចធ្វើការដោយម្នាក់ឯង ឬជាដៃគូដើម្បីបង្កើតរឿងមួយតាមរបៀបដែលអ្នកចង់។ នៅចុងបញ្ចប់ យើងនឹងមានរឿងជាច្រើន។ វាក៏អាចបង្កើតរឿងថ្មីមួយដោយខ្លួនរបស់អ្នក និងមិនប្រើឯកសារសម្រាប់សិស្ស។ ប្រសិនបើអ្នកចង់ធ្វើបែបនោះ អ្នកអាចយកក្រដាសរាមសមួយសន្លឹក និងគូរស៊ុមរូបភាពដោយខ្លួនឯង។ ខ្ញុំមានសៀវភៅរឿង កំប្លែងជាឧទាហរណ៍នៅទីនោះ។

អនុញ្ញាតឱ្យសិស្សសរសេររឿងរបស់ពួកគេ ព្យាយាមលើកទឹកចិត្តពួកគេដោយសួរសំណួរ។

- តើអ្វីដែលកើតឡើងបន្ទាប់នៅក្នុងរឿង ?
- តើគេមានប្រតិកម្មតបវិញបែបណា ?
- តើតួអង្គក្នុងរឿងរបស់អ្នកមានឈ្មោះអ្វី ?
- តើគេធ្វើការងារប្រភេទណា ?

នៅពេលសិស្សសរសេរចប់ ឱ្យពួកគេបិទ
រឿងកំប្លែងនោះនៅលើជញ្ជាំង។




**បញ្ចប់មេរៀន** ១០ នាទី

មានរឿងជាច្រើននៅតាមជញ្ជាំង។ ចូរចំណាយពេលខ្លះដើម្បីមើលវា។ ខ្ញុំចង់ឱ្យអ្នកគ្រប់គ្នាទៅតាមជញ្ជាំងដើម្បីមើលរឿងទាំងនោះ។

ប្រសិនបើអ្នកនៅសល់ពេល អ្នកអាចលេងល្បែង "រឿងមួយប្រយោគ"។
សិស្សទាំងអស់អាចឈរជារង្វង់មួយ។ គ្រូជាអ្នកចាប់ផ្តើមដោយនិយាយថា "ភាពចង់ធ្វើដំណើរ ទៅទីក្រុងធំមួយ"។ បន្ទាប់ពីប្រយោគនេះ សិស្សបន្ទាប់នៅក្នុងជួរត្រូវបន្តសាច់រឿងជាមួយប្រយោគផ្សេងទៀត។ ឧទាហរណ៍ៈ "ប៉ុន្តែគាត់មិនដឹងទៅដោយរបៀបណា"។ បន្ទាប់មកអ្នកទីបីនិយាយ ប្រយោគមួយទៀតដើម្បីបន្តសាច់រឿង។ ចូរប្រាកដថា ប្រយោគថ្មីត្រូវជាសាច់រឿងតភ្ជាប់ជាមួយប្រយោគមុន ដូច្នេះរឿងគឺមានលក្ខណៈរលូនបន្តជាប់គ្នាតែមួយ។

## សេចក្តីណែនាំគ្រូ

ព័ត៌មានមួយចំនួនអាចត្រូវចែករំលែកពេលដែលគ្រូមានអារម្មណ៍ថា វាមានសេចក្តីត្រូវការ ធ្វើបែបនេះ។ បើមិនដូច្នេះទេ នេះអាចប្រើជាព័ត៌មានបន្ថែមតាមក្រោយ។ ព័ត៌មាននេះត្រូវបានទាញចេញពីការសិក្សាមួយរបស់ CDRI ឆ្នាំ២០០៧ "អ្នកចំណាកស្រុកវ័យក្មេង និងការអភិវឌ្ឍទីក្រុង"។ ចំនួនម៉ោងធ្វើការក្នុងមួយថ្ងៃ ជាមធ្យមអ្នកចំណាកស្រុកវ័យក្មេងមកទីក្រុងធ្វើការ ១០,៦២ម៉ោងក្នុងមួយថ្ងៃ។ ការងារប្រចាំសប្តាហ៍របស់ពួកគេគឺ ៧២ម៉ោង ដែលគួរឱ្យភ្ញាក់ផ្អើល។

អាយុមធ្យមនៃជនចំណាកស្រុកវ័យក្មេងក្នុងការស្រាវជ្រាវនេះ

| ប្រភេទការងារ | ឆ្នាំ |
|---|---|
| អ្នករត់ម៉ូតូឌុប | 22.95 |
| អ្នកធ្វើការក្នុងកាស៊ីណូ | 21.73 |
| អ្នកធ្វើការជាអ្នកសាងសង់ | 21.44 |
| អ្នកធ្វើការរោងចក្រកាត់ដេរ | 20.87 |
| អ្នកធ្វើការជាអ្នកបម្រើ | 20.20 |
| អ្នកលក់ឥវ៉ាន់កំប៉ិកកំប៉ុក | 19.70 |
| អ្នកលាងឡាន | 18.87 |
| អ្នកអូសរទេះ | 18.73 |

ការធ្វើបំលាស់ទីទៅកាន់ទីកន្លែងផ្សេង ត្រូវបានគេចាត់ទុកជាប្រភេទមួយ នៃការវិនិយោគជាយូរយារណាស់មកហើយ។ គោលបំណងចម្បងក្នុងការធ្វើបំលាស់ទីទៅកាន់ទីកន្លែងផ្សេងពីជនបទមកទីក្រុងដើម្បីធ្វើឱ្យសេដ្ឋកិច្ច មានភាពល្អប្រសើរឡើង។ គួយ៉ាងដូចជានៅតាម ជនបទ ក្នុងប្រទេសកម្ពុជា ដើមទុនគឺត្រូវការប្រើប្រាស់ដើម្បីឱ្យសមាជិកគ្រួសារអាចធ្វើ បំលាស់ទីទៅកាន់ទីកន្លែងផ្សេង បាន។ ភាគច្រើននៃប្រាក់ ទាំងនោះ គឺចំណាយទៅលើសោហ៊ុយធ្វើដំណើរ អាហារ និងការស្នាក់នៅ រហូតដល់រកបានការងារធ្វើ។ ការសិក្សាបាន រកឃើញថា ជាមធ្យមដើម្បីការងារវ័យក្មេងអ្នកធ្វើបំលាស់ទីទៅកាន់ទីកន្លែងផ្សេងចំណាយអស់ចំនួន ២៧៨០០រៀល ក្នុងអំឡុងពេលចាក ចេញពីផ្ទះរហូតដល់ទទួលបានការងារ។ ភាគច្រើននៃប្រាក់ទាំងនោះគឺចំណាយទៅលើសោហ៊ុយធ្វើដំណើរ និងអាហារ។ ក្នុងករណីភាគច្រើនបំផុតការស្នាក់នៅដោយឥតគិតថ្លៃត្រូវបានផ្តល់ឱ្យដោយបងប្អូន ឬមិត្តភក្តិមកពីភូមិដូចគ្នា។

អ្នកធ្វើបំលាស់ទីទៅកាន់ទីកន្លែងផ្សេង ដើម្បីធ្វើការម្នាក់ចំណាយរយៈពេល ៦ថ្ងៃចាប់តាំងពីចាកចេញពីផ្ទះ រហូតដល់ទទួលបានការងារធ្វើ។ ពួកគេមួយចំនួនមានការងារបណ្តោះអាសន្នមួយ ដែលធានាដោយបងប្អូន ឬមិត្តភក្តិមុនពេលចេញដំណើរហើយពួកគេនឹងចាប់ផ្តើមការងារភ្លាមៗ នៅពេលមកដល់កន្លែងធ្វើការ។

## ប្រភពហិរញ្ញវត្ថុ

នៅពេលសួរពួកគេអំពីប្រភពហិរញ្ញវត្ថុ (ប្រាក់ឬធនធាន) ប្រហែលមួយភាគបីបានមកពី គ្រួសារ។ ទីពីរគឺបានមកពីប្រាក់សន្សំផ្ទាល់ខ្លួន រីឯការខ្ចីនិងលក់ទ្រព្យសម្បត្តិស្ថិតក្នុងលំដាប់ទីបី និងទីបួន។ ៥%ទទួលបានប្រាក់ពីបងប្អូនខណៈពេលដែល ៣%ទទួលបានមកពីថៅកែ ដែលត្រូវទៅធ្វើការជាមួយ។ ជាការពិត ៣៧% នៃអ្នកយកប្រាក់កម្ចី ឬលក់ទ្រព្យសម្បត្តិមានកម្រិតជីវភាពធ្លាក់ចុះ ក្រោយពីការធ្វើចំណាកស្រុកមិនបានសម្រេច។ ប្រាក់កម្ចីបានដាក់សម្ពាធ ទៅលើអ្នកធ្វើចំណាកស្រុកវ័យក្មេង ដើម្បីរកប្រាក់ឱ្យបានកាន់តែច្រើន ដើម្បីសងបំណុលគេក្រោយពេលចាកចេញទៅ។

## ប្រភេទនៃការស្នាក់នៅ

ប្រភេទនៃការស្នាក់នៅ មានភាពខុសប្លែកគ្នាយ៉ាងខ្លាំង ដោយផ្អែកលើប្រភេទនៃការងារ។ ជាទូទៅ មួយភាគបីនៃអ្នកធ្វើចំណាកស្រុក ដើម្បីការងារវ័យក្មេងដែលត្រូវបានសម្ភាសរស់នៅក្នុងផ្ទះជួល ហើយច្រើនជាងមួយភាគបួនបន្តិចរស់នៅកន្លែងស្នាក់នៅដោយឥតគិតថ្លៃ ដែលផ្តល់ដោយថៅកែ និងច្រើនជាងមួយភាគប្រាំមួយ រស់នៅកន្លែងសាងសង់។ អ្នកធ្វើការតាមភោជនីយដ្ឋានចំនួន ១០៤នាក់ ក្នុងចំណោម១២០នាក់ស្នាក់នៅកន្លែងដែលឥតគិតថ្លៃ។

ច្រើនជាងពាក់កណ្តាលនៃអ្នករត់ម៉ូតូឌុប រស់នៅក្នុងផ្ទះជួល ហើយអ្នកដទៃទៀតភាគច្រើនរស់នៅជាមួយបងប្អូន។ បីភាគបួននៃអ្នកធ្វើការនៅរោងចក្រកាត់ដេរ ក៏រស់នៅតាមផ្ទះជួលផងដែរ ហើយអ្នកដទៃទៀតរស់នៅកន្លែងស្នាក់នៅបង់ប្រាក់ កន្លែងស្នាក់នៅដោយមិនគិតថ្លៃ ឬរស់នៅជាមួយបងប្អូន។ ដោយឡែកអ្នកលាងឡានទាំងអស់ រស់នៅកន្លែងស្នាក់នៅដោយមិនគិតថ្លៃ ក្នុងករណីដែលកន្លែងនោះផ្តល់ដោយម្ចាស់យានដ្ឋាន។ កន្លែងស្នាក់នៅរបស់អ្នកលក់ដូរកំប៉ិកកំប៉ុក គឺស្មើរតែទាំងអស់អាចចែកដោយស្មើគ្នា រវាងការរស់នៅក្នុងផ្ទះផ្ទាល់ខ្លួន និងរស់នៅជាមួយបងប្អូនអាស្រ័យតាមការពិត ដែលអ្នកលក់ដូរវ័យក្មេងទាំងនោះ ធ្វើចំណាកស្រុកមកជាមួយគ្រួសាររបស់ពួកគេ។ អ្នកអូសរទេះមួយចំនួនក៏ធ្វើចំណាកស្រុក មកជាមួយគ្រួសាររបស់ពួកគេផងដែរ ដោយលទ្ធផលបង្ហាញថាមួយភាគប្រាំនៃពួកគេរស់នៅក្នុងផ្ទះរបស់ពួកគេផ្ទាល់ខ្លួន ច្រើនជាងមួយភាគប្រាំរស់នៅជាមួយបងប្អូន និងពាក់កណ្តាលនៃពួកគេរស់នៅតាមផ្ទះជួល។ ពីរភាគបីនៃអ្នកធ្វើការក្នុងកាស៊ីណូរស់នៅតាមផ្ទះជួល ហើយបីភាគទៀតរស់នៅកន្លែងស្នាក់នៅ ដោយឥតគិតថ្លៃ។

អ្នកដែលចំណាយសម្រាប់កន្លែងរស់នៅ(ផ្ទះជួល ឬកន្លែងស្នាក់នៅ) ជាមធ្យមចំណាយអស់ ៤២ ៦០០រៀលក្នុងមួយខែ។ មួយក្នុងចំណោមការរស់នៅដ៏សាមញ្ញបំផុតនោះ គឺអ្នកធ្វើចំណាកស្រុកវ័យក្មេង បង្កើតជាក្រុមមួយជាមួយមិត្តរួមការងារដែលមានគ្នាចាប់ពី៤ ដល់ ៧ នាក់ ឬច្រើនជាងនេះដើម្បីរស់នៅក្នុងផ្ទះជួលជាមួយគ្នា។ ដើម្បីកាត់បន្ថយការចំណាយ ជាធម្មតាពួកគេស្ម័គ្រចិត្តរស់នៅប្រជ្រៀតគ្នា ។ ស្ថានភាពនៃអ្នកអូសរទេះនៅប៉ោយប៉ែត កាន់តែគួរឱ្យស្លុតចិត្ត។ ផ្ទះជួលដែលមានតម្លៃថោករបស់ពួកគេ គឺនៅក្បែរភក់ គំនរសំរាម គ្មានភ្លើង ឬទឹកស្អាតឡើយ។ រីឯស្ថានភាពនៃអ្នកដែលទទួលបានកន្លែងស្នាក់នៅ ដោយឥតគិតថ្លៃ ក៏មិនជាល្អប្រសើរណាស់ណាដែរ។ នៅក្នុងទីក្រុងសៀមរាបក្រុមអ្នកធ្វើការសាងសង់ ចំនួន១៥នាក់ រស់នៅជាមួយគ្នាក្នុងកន្លែងស្នាក់នៅបណ្តោះអាសន្ន ដែលមានទំហំ ៥ គុណ ៦ម៉ែត្រ ហើយគ្មានភ្លើងអគ្គិសនី គ្មានទឹក និងសូម្បីតែបង្គន់ក៏គ្មានដែរ។ បង្គន់មួយ ត្រូវបានប្រើប្រាស់ដោយកម្មករជាច្រើនរយនាក់ ដែលធ្វើការក្នុងគម្រោងសាងសង់ដ៏ធំមួយ។



## រឿងរបស់...













# មេរៀនទី ៩: ច្បាប់ស្តីពីការបង្ក្រាបអំពើពង្រត់ និងជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មលើមនុស្ស

រយៈពេលបង្រៀនៈ ១ម៉ោង ៣០នាទី

☑ ការត្រៀមលក្ខណៈ

មុនពេលបង្រៀនលោកគ្រូ អ្នកគ្រូត្រូវ

- អាន និងពិនិត្យមេរៀនដោយហ្មត់ចត់ និងធ្វើកិច្ចតែងការបង្រៀន
- ពិនិត្យមើលឯកសារសិស្ស ដើម្បីចង់ដឹងថាតើមានព័ត៌មាន និងសំណួរ សម្រាប់សកម្មភាពគ្រូនឹងការបង្រៀនដែរឬទេ
- សរសេរសំណួរលើក្តារខៀន ឬនៅលើក្រដាសផ្ទាំងធំ ប្រសិនបើសិស្សមានឯកសារ គេអាចមើលព័ត៌មាននេះនៅក្នុងឯកសាររបស់គេបាន
- មើលកាលវិភាគប្រចាំថ្ងៃ
- រៀបចំបន្ទប់រៀន (តុ កៅអី ក្តារខៀន...)។

សម្ភារឧបទេស ធនធានដែលត្រូវការ

- ច្បាប់បង្ក្រាបការជួញដូរមនុស្សរបស់ប្រទេសកម្ពុជាក្នុងឯកសារសម្រាប់សិស្ស ៩.១
- ប្រសិនបើអាច អញ្ជើញសមាជិកម្នាក់នៃក្រុមប្រឹក្សាឃុំ-សង្កាត់ដើម្បីឆ្លើយតបនឹងសំណួររបស់សិស្សអំពីការជួញដូរមនុស្ស។ នេះក៏អាចជានរណាម្នាក់ដែលមកពីក្រសួង អង្គការលីកាដូ ឬអង្គការប្រឆាំងការជួញដូរមនុស្សផ្សេងទៀត។ *(មើលសេចក្តីណែនាំគ្រូ)*

☼ វត្ថុបំណង

នៅពេលរៀនមេរៀននេះចប់ សិស្សនឹងអាច ៖

- ស្វែងយល់ពីច្បាប់ក្នុងប្រទេសកម្ពុជាទាក់ទងនឹងការជួញដូរមនុស្ស
- បញ្ជាក់ពីចំណុចសំខាន់នៅក្នុងច្បាប់នីមួយៗ

**សេចក្តីផ្តើម** ២០ នាទី

ថ្ងៃនេះ យើងនឹងសិក្សាអំពីច្បាប់ របស់ប្រទេសកម្ពុជា។ កម្ពុជាជាប្រទេសប្រកាន់ទិទ្ធិប្រជាធិបតេយ្យ ដែលច្បាប់ត្រូវបានបង្កើតឡើងដោយរដ្ឋាភិបាល។ ប៉ុន្តែតើអ្វីដែលមានពិតប្រាកដនៅក្នុងច្បាប់នោះ? ចូរស្វែងយល់ទាំងអស់គ្នា។ ខ្ញុំនឹងនិយាយប្រយោគជាច្រើន អ្នកគ្រប់គ្នាត្រូវក្រោកឈរ។ ប្រសិនបើអ្នកគិតថា ប្រយោគណាមួយជាច្បាប់ អ្នកត្រូវលើក ដៃទាំងពីរឡើង តែប្រសិនបើអ្នកគិតថាមិនមែនជាច្បាប់នោះទេ អ្នកគ្រាន់តែឈរធម្មតាបានហើយ។

*ឧទាហរណ៍ ៖ អ្នកគ្រប់គ្នាគួរបរិភោគចេកពីរផ្លែក្នុងមួយសប្តាហ៍ម្តង។* តើអ្នកគិតបែបណា? ប្រសិនបើនេះជាច្បាប់ចូរលើកដៃឡើង។ ប្រសិនបើអ្នកគិតថានេះមិនមែននៅក្នុងច្បាប់នោះទេ អ្នកឈរធម្មតាដដែល។

អ្នកដែលឆ្លើយមិនត្រូវអាចអង្គុយចុះ ហើយនិងអាចលេងបន្តទៀតនៅជុំបន្ទាប់។

១. មនុស្សគ្រប់គ្នាដែលបើកបរម៉ូតូគួរពាក់មួកសុវត្ថិភាព។ - ច្បាប់

២. នៅពេលអ្នកទៅចូលរួមបុណ្យសព អ្នកត្រូវពាក់សម្លៀកបំពាក់ពណ៌ស។ - មិនមែន

៣. កាំភ្លើងបាញ់ទឹកមិនត្រូវប្រើប្រាស់ក្នុងអំឡុងពេលបុណ្យចូលឆ្នាំខ្មែរទេ។ - ច្បាប់

៤. ស្ត្រីត្រូវទទួលបានប្រាក់ខែច្រើនដូចបុរសដែរ ប្រសិនបើពួកគេធ្វើការងារដូចគ្នា។ - ច្បាប់

៥. ប្រសិនបើអ្នកចូលទៅក្នុងផ្ទះរបស់មនុស្សចាស់ណាម្នាក់ អ្នកគួរឱនក្បាល និងគោរពគាត់។ - មិនមែន
៦. អ្នកធ្វើការនៅក្នុងរោងចក្រកាត់ដេរគួរទទួលបានប្រាក់ខែយ៉ាងតិចបំផុត ៥០ដុល្លារ ក្នុងមួយខែ។ - ច្បាប់
៧. អ្នកមិនអាចធ្វើការនៅក្នុងរោចក្របានទេ ប្រសិនបើអ្នកមានអាយុតិចជាង១៥ឆ្នាំ។ - ច្បាប់
៨. ប្រសិនបើអ្នកឆ្លងទន្លេ (សម្រាលកូន) អ្នកមានសិទ្ធិទទួលបានប្រាក់ខែពាក់កណ្តាលនៃរយៈពេល៩០ថ្ងៃ សម្រាប់ច្បាប់មាតុភាព។ - ច្បាប់
៩. ប្រសិនបើអ្នកធ្វើឱ្យស្មារបស់អ្នកបាក់ អ្នកគួរទៅមន្ទីរពេទ្យ។ - មិនមែន
១០.សិស្សម្នាក់ៗគួរមានពេលយ៉ាងតិចណាស់ ២ម៉ោងសិក្សា សម្រាប់ការបណ្តុះបណ្តាលបំណិនជីវិត នៅក្នុងមធ្យមសិក្សាបឋមភូមិ។ - ច្បាប់

ដូចអ្វីដែលអ្នកបានឮ នៅក្នុងច្បាប់គឺមាននិយាយពីអ្វីៗយ៉ាងច្បាស់ ហើយពេលខ្លះអាចជាអ្វីដែលមិនបានរំពឹងទុក ផងដែរ ព្រោះតែច្បាប់អាចត្រូវបានបង្កើតឡើង ដោយប្រទេសខ្លួនឯងបាន។ ច្បាប់នៅក្នុងប្រទេសកម្ពុជាមិនដូចច្បាប់ ក្នុងប្រទេសចិន ឬប្រទេសផ្សេងៗទៀតនោះទេ ប៉ុន្តែមានមួយផ្នែកធំគឺមានភាពដូចគ្នា។ នេះដោយសារតែរដ្ឋា ភិបាលនានាក្នុងពិភពលោក សម្រេចចិត្តឱ្យតម្លៃទៅលើអ្វីមួយស្មើភាពគ្នា។ ឧទាហរណ៍ ៖ ស្ទើរតែប្រទេសទាំងអស់បានចុះហត្ថលេខា លើកិច្ចព្រមព្រៀងអំពីសិទ្ធិមនុស្ស ព្រោះប្រទេសទាំងអស់គិតថាវាមានសារៈសំខាន់។

តើច្បាប់មានន័យថា វាគ្មានបញ្ហាអ្វីកើតឡើងដែលទាក់ទងនឹងខ្លឹមសារឬ?

ច្បាប់មានន័យថាគួរបែបនេះ តែជាញឹកញាប់វាមិនបែបនោះទេ។ ប៉ុន្តែវាជាសិទ្ធិរបស់អ្នក ដូចបាននិយាយនៅក្នុងច្បាប់ ដូច្នេះអ្នកគួរតែស្វះស្វែងរកវា! នេះជាបញ្ហាសំខាន់នៅក្នុងលទ្ធិប្រជាធិបតេយ្យ។ នៅក្នុងប្រទេសកម្ពុជាយើង គឺមានច្បាប់ទាក់ទងនឹងការជួញដូរមនុស្សផងដែរ។ មុនពេលយើងចាប់ផ្តើមសិក្សាពីច្បាប់នេះ ខ្ញុំចង់ឱ្យអ្នកគូសចែកជាពីរជួរក្នុងសៀវភៅរបស់អ្នក។ នៅផ្នែកម្ខាងអ្នកសរសេរ *វត្ថុដែលខ្ញុំចង់ដឹងអំពីច្បាប់ជួញដូរមនុស្សរបស់កម្ពុជា។* នៅផ្នែក ម្ខាងទៀតទុកវាឱ្យទទេ។

ទុកពេលពីរឬបីនាទីឱ្យសិស្សសរសេរសំណួរចូលក្នុងសៀវភៅ។
បន្ទាប់ពីពួកគេបានបញ្ចប់ការសរសេរនោះ ចែកឯកសារ ៩.១ សម្រាប់សិស្សឱ្យពួកគេ។

អ្នកអាចអានច្បាប់នេះចំនួនមួយដងដើម្បីស្វែងរកចម្លើយទៅនឹងសំណួររបស់អ្នក។
សិស្សអានឯកសារនេះជាលើកដំបូងដើម្បីស្វែងរកចម្លើយរៀងៗខ្លួន។ ប្រសិនបើអ្នកបញ្ចប់ អ្នកអាចអានម្តងទៀត និងគូសបន្ទាត់ពីក្រោមពាក្យពិបាកដែលអ្នកមិនសូវច្បាស់ ឬមិនយល់ពីអត្ថន័យ។

ទុកពេលឱ្យសិស្សគូសបន្ទាត់ពីក្រោមពាក្យពិបាក និងផ្តល់ការពន្យល់ពាក្យទាំងនោះ ពេលសិស្សគូសរួច ព្រមទាំង ពិនិត្យការយល់ដឹងពីចំណុចសំខាន់ៗនៅក្នុងច្បាប់នេះដោយសួរពួកគេនូវសំណួរខាងក្រោម។

តើច្បាប់បញ្ជាក់ថាអ្នកប្រព្រឹត្តការជួញដូរមនុស្សនឹងត្រូវជាប់គុកប៉ុន្មានឆ្នាំ? ចម្លើយ៖ មាត្រា ៣ : ១០ - ១៥ឆ្នាំ
តើមានលក្ខណៈខុសគ្នាដូចម្តេចដែរ ប្រសិនបើជនរងគ្រោះមានអាយុក្រោម ១៥ឆ្នាំ? ចម្លើយ ៖ មាត្រា ៣ : នឹងបង្កើនដល់ ១៥ - ២០ឆ្នាំ។
តើច្បាប់នេះត្រូវបានអនុវត្តដូចគ្នាដែរឬទេ សម្រាប់អ្នកសមគំនិត ឈ្មួញជួញដូរមនុស្ស អ្នកលក់ អ្នកទិញ និងនរណាដែលបានផ្តល់ប្រាក់ ឬមធ្យោបាយ (ដូចជារថយន្ត ឬកន្លែងស្នាក់នៅ) ដើម្បីប្រព្រឹត្តបទល្មើសនេះ? ចម្លើយ៖ គឺដូចៗគ្នា

តើច្បាប់បញ្ជាក់ថាអ្នកប្រព្រឹត្តអនាចារចំពោះអនីតិជន (អ្នកដែលមានអាយុក្រោម១៥ឆ្នាំ)នឹង ត្រូវជាប់គុកប៉ុន្មាន ឆ្នាំ? ចម្លើយ ៖ មាត្រា៨ : ១០ - ២០ឆ្នាំ។

## សកម្មភាពសំខាន់។

⌚ ៦០ នាទី

ក្នុងរយៈពេល ៣០នាទី យើងនឹងធ្វើកិច្ចសម្ភាស ជាមួយវាគ្មិនកិត្តិយសមួយរូប អំពីការជួញដូរមនុស្ស ។ ដើម្បីត្រៀមលក្ខណៈសម្រាប់កិច្ចការនេះ យើងនឹងធ្វើការជាក្រុមដើម្បីត្រៀមសំណួរ។ នេះអាចប្រហែលជារួមបញ្ចូលទាំងសំណួរដែលមិនទាន់បានឆ្លើយ នៅក្នុងសៀវភៅរបស់អ្នក។

អនុញ្ញាតឱ្យសិស្សធ្វើការនេះជាក្រុម។ ប្រសិនបើអ្នកចង់ អ្នកអាចលើកពីប្រធានបទផ្សេងៗទៀត ដែលអ្នកអាចផ្តោតការយកចិត្តទុកដាក់បានដូចជា ៖

- ព័ត៌មានអំពីករណីនៃការជួញដូរមនុស្សក្នុងសហគមន៍ ឬក្នុងស្រុក
- ប្រភេទនៃការជួញដូរមនុស្សដែលតែងតែកើតឡើង
- ពលកម្ម កេងចំនេញផ្លូវភេទមនុស្សពេញវ័យ ក្មេងប្រុស ក្មេងស្រី
- ប្រភេទនៃល្បិចកលដែលឈ្មួញជួញដូរមនុស្សប្រើប្រាស់ និងថាតើវាកើតឡើងនៅក្នុងសហគមន៍ តាមផ្លូវធ្វើដំណើរ ឬពេលនៅដល់កន្លែងធ្វើការ
- ថាតើមានករណីក្នុងមូលដ្ឋានណាមួយ ដែលឈ្មួញជួញដូរមនុស្ស ត្រូវបានគេធ្វើការចោទប្រកាន់ដាក់ទោស
- ឧបសគ្គក្នុងការនាំជនល្មើសទៅកាន់តុលាការ
- អ្វីដែលបានកើតឡើងចំពោះជនរងគ្រោះ និងសេវាកម្មនានាដែលមាន
- អ្វីដែលកំពុងត្រូវបានគេធ្វើក្នុងសហគមន៍ដើម្បីបង្កើនការយល់ដឹងអំពីការជួញដូរមនុស្ស និងរបៀបក្នុងការការពារវា
- អ្វីផ្សេងទៀតដែលអាចធ្វើបានដើម្បីការពារ និងជួយជនរងគ្រោះ។

មុនពេលវាគ្មិនកិត្តិយសមកដល់ យើងត្រូវសម្រេចថានរណានឹងធ្វើជាអ្នកសម្របសម្រួល ក្នុងវគ្គសួរសំណួរ និង នរណាជាអ្នកថ្លែងអំណរគុណដល់វាគ្មិន នៅចុងបញ្ចប់។ តើនរណាអាចជួយយើងបានចំពោះកិច្ចការនេះ ?យើងមិនត្រូវភ្លេចកត់ត្រាអំពីការសម្ភាស ព្រមទាំងចម្លើយទៅក្នុងសៀវភៅរបស់អ្នកផងដែរ។

ស្វាគមន៍វាគ្មិនកិត្តិយស និងណែនាំគាត់ថានរណាជាអ្នកសម្របសម្រួលក្នុងការសួរសំណួរ។

## បញ្ចប់មេរៀន

⌚ ១០ នាទី

ប្រសិនបើនៅសល់ពេល អ្នកអាចឱ្យសិស្សធ្វើការឆ្លុះបញ្ចាំង និងចែករំលែកចម្លើយជាមួយសិស្សក្នុងថ្នាក់ទាំងអស់។ ព្រមទាំងសួរពួកគេអំពីអ្វីគួរឱ្យចាប់អារម្មណ៍បំផុតដែលគេបានរៀន។

ប្រសិនបើនៅមានសំណួរមួយចំនួនមិនទាន់បានឆ្លើយ អ្នកអាចលើកទឹកចិត្តសិស្សឱ្យស្វែងរកចម្លើយ ចំពោះសំណួរទាំងនោះតាមកាសែត អ៊ីនធើណេត ឬទូរស័ព្ទទៅអង្គការណាមួយនៅ ក្នុងសេចក្តីណែនាំគ្រូ។

កិច្ចការផ្ទះ៖ នៅសប្តាហ៍បន្ទាប់ ក្នុងមេរៀនទី៩ អ្នកអាចនាំសិស្សដទៃ(មិត្តភក្តិ) ឬសមាជិកគ្រួសារមកថ្នាក់រៀនបាន។ យើងនឹងធ្វើពុតថា គេគឺជាអ្នកធ្វើបំលាស់ទីទៅកាន់ទីកន្លែងផ្សេងថ្មី។ អ្នកទាំងអស់គ្នាគឺជាអ្នក ធ្វើបំលាស់ទីទៅកាន់ទីកន្លែងផ្សេងដែលមានបទ ពិសោធន៍ដែលអាចប្រាប់គេអំពីទិដ្ឋភាពផ្សេងៗ និង ការងារដែលយើងបានធ្វើ។ យើងមានប្រធានបទ ជាច្រើន៖

● ទីកន្លែងដែលគ្រួសាររបស់ខ្ញុំបានធ្វើបំលាស់ទីទៅ
● គ្រោះថ្នាក់ និងគុណប្រយោជន៍នៃការធ្វើបំលាស់ទីទៅកាន់ទីកន្លែងផ្សេង
● ករណីសិក្សា
● ភ្នំពេញ - ពន្យល់អំពីទីក្រុង និងអគាររបស់វា
● ការធ្វើយុទ្ធនាការ - លទ្ធផលនៃដំណើរទៅកាន់ភូមិរបស់យើង
● ការជួញដូរមនុស្ស - កត្តាជំរុញ និងកត្តាអូសទាញផ្សេងៗ និងយុទ្ធសាស្ត្រ
● ច្បាប
● ទីក្រុង

សប្តាហ៍ក្រោយ គឺជាឱកាសមួយដើម្បីបង្ហាញពីអ្វីដែលអ្នកបានដឹងរួចមកហើយ ហើយថាតើ អ្នកអាចពន្យល់ប្រាប់ មិត្តភក្តិ ឬបងប្អូនរបស់អ្នកអំពីប្រធានបទនេះដែរឬទេ។ អ្នកក៏អាចធ្វើអ្វី ម៉្យាងក្នុងករណីសិក្សាជាមួយពួកគេ ឬបង្ហាញ ពួកគេអំពីរឿងកំប្លែង ឬផ្ទាំងរូបភាពរបស់អ្នក។ ការលេងល្បែងសត្វពស់ក៏ជាឱកាសដ៏ល្អមួយ ដើម្បីឱ្យអ្នកដទៃបានរៀនពីសុវត្ថិភាពចំណាកស្រុក ដូចអ្វីដែលយើងបានធ្វើរួចមកហើយ។ ការទស្សនានឹងមានរយៈពេលប្រមាណជា៤៥នាទី ហើយនឹងចាប់ផ្តើមនៅពេលដល់ម៉ោងសិក្សារបស់យើងនៅសប្តាហ៍ក្រោយ។

## សេចក្តីណែនាំគ្រូ

ការអញ្ជើញវាគ្មិនកិត្តិយស នឹងបង្កើតកម្រិតទាក់ទងនៃកម្មវិធីបានយ៉ាងច្រើន។ វាជាគំនិតដ៏ល្អមួយ ដើម្បីអញ្ជើញនរណាម្នាក់ពីក្រុមប្រឹក្សាឃុំ-សង្កាត់ ឬអាជ្ញាធរខេត្ត ដែលមានចំណេះដឹងអំពីប្រធានបទនេះ។ ប្រសិនបើមិនមានទេ គឺនៅមានអង្គការជាច្រើន ដែលកំពុងធ្វើការនៅក្នុងផ្នែកនេះ។ព្យាយាមទាក់ទងជាមួយអង្គការណាមួយក្នុងចំណោមអង្គការនានាខាងក្រោមនេះ។

មជ្ឈមណ្ឌលជួយស្ត្រីកម្ពុជាមានវិបត្តិ (CWCC) ផ្តល់ជំនួយដល់ស្ត្រី និងកុមារដែលជាជនរងគ្រោះដោយអំពើហិង្សាក្នុងគ្រួសារ ការរំលោភបំពានផ្លូវភេទ និងការជួញដូរ។ ពួកគេមានមណ្ឌល ជួយអ្នកមានវិបត្តិដោយរក្សាការសម្ងាត់នៅទីក្រុងភ្នំពេញ សៀមរាប និងបន្ទាយមានជ័យ។ មណ្ឌលទាំងនោះផ្តល់នូវការស្នាក់នៅ ការប្រឹក្សា ថ្នាំព្យាបាល ការរៀនសូត្រ បំណិនជីវិត និង ការបណ្តុះបណ្តាលវិជ្ជាជីវៈ។ CWCCក៏ផ្តល់ផងដែរនូវជំនួយផ្នែកច្បាប់ដល់ជនរងគ្រោះ និងជួយនាំយក ស្ត្រីដែលត្រូវបានគេជួញដូរ និងរំលោភបំពានទៅកាន់សហគមន៍របស់ពួកគេវិញ។ CWCC ផ្តល់នូវការបង្រៀនពីរបៀបគ្រប់គ្រងកំហឹង/ការប្រឹក្សាសម្រាប់បុរសប្រព្រឹត្តការរំលោភបំពាន ឬបុរសដែលប្រឈមនឹងការក្លាយជាអ្នករំលោភបំពាន។ ទន្ទឹមនឹងនោះ CWCC ក៏ជួញជនរងគ្រោះពលកម្មកុមារនៅឯបរទេសផងដែរ។

អាសយដ្ឋាន៖ ផ្ទះលេខ៤៧F ផ្លូវលេខ៤៨៨ សង្កាត់ផ្សារដើមថ្កូវ ខណ្ឌចំការមន ក្រុងភ្នំពេញ ប្រទេសកម្ពុជា<br>
ប្រអប់សំបុត្រលេខ : PO Box ២៤២១<br>
លេខទូរស័ព្ទ/ទូរសារ : (៨៥៥-២៣) ៩៨៧ ១៥៨<br>
អ៊ីម៉ែល : cwccpnp@cwcc.org.kh

អង្គការគាំទ្រផ្នែកច្បាប់ដល់ស្ត្រី និងកុមារ (LSCW)៖ គឺធ្វើការដើម្បីលើកតម្កើងពីភាពស្មើគ្នាខាងផ្នែកយេនឌ័រ ការពារកុមារនិងស្ត្រីពីគ្រប់រូបភាពនៃការជួញដូរ ជំរុញឱ្យមានការគោរព សិទ្ធិរបស់ពួកគេ និងបង្កើនការយល់ដឹងរបស់ស្ត្រី និងកុមារអំពីសិទ្ធិទាំងនោះ។ អង្គការនេះ មានការិយាល័យក្នុងទីក្រុងភ្នំពេញ កោះកុង និងព្រៃវែង។ LSCW ក៏បានពង្រីកការងាររបស់ ខ្លួនសម្រាប់ជួយបុរស ស្ត្រី និងកុមារដែលត្រូវបានគេជួញដូរអំឡុងពេលធ្វើចំណាកស្រុក។ LSCW ផ្តល់ជំនួយ និងគាំទ្រផ្នែកច្បាប់ ដល់ជនរងគ្រោះ តាមរយៈក្រុមមេធាវីដែលទទួលបានការបណ្តុះបណ្តាល និងបន្តស្រាវជ្រាវលក្ខខណ្ឌដែលប៉ះពាល់ដល់ស្ត្រី និងកុមារ ព្រមទាំងអ្នកធ្វើចំណាកស្រុកកម្ពុជាដើម្បីធ្វើការ។ គេហទំព័រ

: *http://www.lscw.org/eindex.html*

- **ការិយាល័យកណ្តាល៖** ផ្ទះលេខ១៣២E-F ផ្លូវលេខ ១៣៥ សង្កាត់ផ្សារដើមថ្កូវ<br>ខណ្ឌចំការមន ក្រុងភ្នំពេញ ប្រទេសកម្ពុជា លេខទូរស័ព្ទ/ទូរសារ : (៨៥៥) ២៣ ២២០ ៦២៦<br>លេខទូរស័ព្ទដៃ : (៨៥៥) ១២ ៩៨៥ ៦៤៣
- **ការិយាល័យខេត្តព្រៃវែង៖** ផ្ទះលេខ៥០ ភូមិលេខ៥ ឃុំកំពង់លាវ ស្រុកកំពង់លាវ<br>ខេត្តព្រៃវែង លេខទូរស័ព្ទ : (៨៥៥) ៤៣ ៩៤៤ ៧១៥

សម្ព័ន្ធខ្មែរជំរឿននិងការពារសិទ្ធិមនុស្ស (លីកាដូ)

លីកាដូគឺជាអង្គការជាតិដែលធ្វើការលើបញ្ហាសិទ្ធិមនុស្ស។ ចាប់តាំងពីបង្កើតឡើងនៅក្នុងឆ្នាំ១៩៩២ លីកាដូបានចេញមុខជាងគេក្នុងការប្រឹងប្រែងដើម្បីការពារសិទ្ធិពលរដ្ឋ នយោបាយ សេដ្ឋកិច្ច និងសង្គមក្នុងប្រទេសកម្ពុជា ព្រមទាំងដើម្បីបង្កើតការគោរពសិទ្ធិទាំងនោះពីរដ្ឋាភិបាល និងស្ថាប័នកម្ពុជានានា។ ការរីកចម្រើនដោយសារស្នាដៃនាពេលកន្លងមក លីកាដូបន្តធ្វើជាអ្នកការពារប្រជាជនកម្ពុជា និងជាអ្នកត្រួតពិនិត្យរដ្ឋាភិបាលតាមរយៈកម្មវិធីសិទ្ធិមនុស្សជាច្រើនពីទីការិយាល័យកណ្តាលក្នុងទីក្រុងភ្នំពេញ និងការិយាល័យតាមបណ្តា ១២ខេត្ត ទៀត។

កំពង់ចាម៖ ក្រុមទី៤ ភូមិ៦ ឃុំវាលវង់ ស្រុកកំពង់ចាម ខេត្តកំពង់ចាម<br>
ទូរស័ព្ទ : ០៤២ ៩៤១ ៤៦៤

កំពង់ធំ ៖ ផ្ទះលេខ២៥៤ ក្រុមទី៤៤ ភូមិកំពង់ធំ ឃុំកំពង់រទេះ ស្រុកស្ទឹងសែន ខេត្តកំពង់ធំ<br>
ទូរស័ព្ទ : ០៦២ ៩៦១ ២៩២

សៀមរាប ៖ ផ្ទះលេខ៤៥៩ ភូមិដកពរ ឃុំស្លក្រាម ស្រុកសៀមរាប ខេត្តសៀមរាប<br>
ទូរស័ព្ទ : ០៦៣ ៩៦៤ ០៦៦



**ដកស្រង់ចេញពីច្បាប់របស់ប្រទេសកម្ពុជាស្តីពី ការបង្ក្រាបអំពើពង្រត់ និងជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មលើមនុស្ស**

## ជំពូកទី ១
## បទបញ្ញត្តិទូទៅ

**មាត្រា ១:** ច្បាប់នេះមានគោលដៅបង្ក្រាបអំពើពង្រត់មនុស្សយកទៅលក់ដូរ និងអំពើធ្វើអាជីវកម្មលើមនុស្ស ដើម្បីធ្វើនិតិសម្បទាន និងលើកកម្ពស់ការគោរពប្រពៃណីជាតិល្អ ការការពារសេចក្តីថ្លៃថ្នូររបស់មនុស្ស និងការការពារសុខភាព និងសុខុមាលភាពរបស់ប្រជាជន។

**មាត្រា ២:** ត្រូវហាមឃាត់ជាដាច់ខាតអំពើពង្រត់មនុស្សយកទៅលក់ដូរ ឬយកទៅធ្វើពេស្យាចារ និងអំពើធ្វើអាជីវកម្មលើមនុស្សនៅក្នុង ឬក្រៅទឹកដីនៃព្រះរាជាណាចក្រកម្ពុជា។

## ជំពូកទី ២
## អំពីអំពើពង្រត់មនុស្សយកទៅលក់ ឬយកទៅធ្វើពេស្យាចារ

**មាត្រា ៣:** ជនណាអូសទាញមនុស្ស ទោះបីស្រី ឬប្រុស អនីតិជន ឬនីតិជន មានសញ្ជាតិអ្វីក៏ដោយ ដោយវិធីល្បួងលោម សន្យាឱ្យប្រាក់កាស ឬគ្រឿងអលង្ការ ឬតាមវិធីណាក៏ដោយ ទោះបីសាមីខ្លួនសុខចិត្ត ឬមិនសុខចិត្ត ដោយវិធីបង្ខិតបង្ខំ គំរាមកំហែង ឬប្រើថ្នាំសណ្តំស្មារតី និងសតិអារម្មណ៍ ដើម្បីពង្រត់យកទៅលក់ ឬយកទៅធ្វើពេស្យាចារ ជននោះត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១០ឆ្នាំ ដល់ ១៥ឆ្នាំ។ បើជនរងគ្រោះជាអនីតិជនអាយុតិចជាង ១៥ឆ្នាំ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១៥ឆ្នាំ ដល់ ២០ឆ្នាំ។

អ្នកសមគំនិត អ្នកលក់ អ្នកទទួលទិញ ឬទទួលយក ត្រូវមានទោសដូចអ្នកប្រព្រឹត្តដែរ។

ត្រូវចាត់ទុកជាអ្នកសមគំនិតដែរ អ្នកដែលផ្តល់ប្រាក់ ឬផ្តល់មធ្យោបាយផ្សេងៗសម្រាប់ប្រព្រឹត្តិបទល្មើស។

មធ្យោបាយដឹកជញ្ជូន សម្ភារៈ និងទ្រព្យសម្បត្តិប្រើប្រាស់ក្នុងពេលប្រព្រឹត្តបទល្មើសត្រូវរឹបអូសជាសម្បត្តិរដ្ឋ។

## ជំពូកទី ៣
## អំពីសញ្ជារកម្ម

**មាត្រា ៤:** នឹងត្រូវចាត់ទុកជាសញ្ជារិក ឬសញ្ជារិកា ឬជនមេពេស្យា ជនណា៖

១. ដែលទំនុកបំរុង ឬការពារជនណាម្នាក់ ឬច្រើននាក់ ទោះបីតាមមធ្យោបាយណាក៏ដោយ ហើយដោយបានដឹងជាមុននូវអំពើពេស្យាចាររបស់ជននោះ ឬក៏ទាក់ទាញឱ្យជននោះ ក្នុងគោលដៅពេស្យាចារ ឬ

២. ដែលចែកភាគផល ដែលបានមកពីអំពីអំពើពេស្យាចារជាប្រក្រតី ទោះជាក្នុងទ្រង់ទ្រាយណាក៏ដោយ ឬ

៣. ដែលយកស្ត្រី ឬបុរស ទោះបីតាមមធ្យោបាយណាក៏ដោយ ទៅបង្ហាត់បង្រៀនបញ្ចុះបញ្ចូលឱ្យធ្វើជាស្ត្រី ឬបុរសពេស្យា ឬ

ដកស្រង់ពីគេហទំព័រ: http://www.protectionproject.org

៤. ដែលធ្វើជាអ្នកកណ្តាល ទោះបីជាតាមរូបភាពណាក៏ដោយ បង្កើតឱ្យមានទំនាក់ទំនងរវាងបុរសពេស្យា ឬស្ត្រីពេស្យា ជាមួយនឹងមេបនពេស្យាចារ ឬជាមួយអ្នកផ្តល់កម្រៃលើពេស្យាចារអ្នកដទៃ ឬ

៥. ដែលឱ្យបុរសឬស្ត្រី នៅក្នុងផ្ទះរបស់ខ្លួន ឬកន្លែងណាមួយ ក្នុងគោលដៅឱ្យជនទាំងនោះធ្វើពេស្យាចារយកប្រាក់ឱ្យខ្លួន។

**មាត្រា ៥:** សញ្ជារិក ឬសញ្ជារិកា ឬជនជាមេពេស្យា ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ឆ្នាំ ដល់ ២០ឆ្នាំ។ ក្នុងករណីមិនរាងចាលត្រូវយកទ្វេរគុណនៃទោសមកអនុវត្ត។

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១០ឆ្នាំ ដល់ ២០ឆ្នាំ ក្នុងករណីសញ្ជារកម្មៈ

១. ប្រព្រឹត្តបទល្មើសលើអនីតិជនក្រោមអាយុ ១៥ឆ្នាំ ឬ

២. ប្រព្រឹត្តបទល្មើសដោយបង្ខិតបង្ខំវិហិង្សា ឬដោយមានការគំរាមកំហែង ឬដោយមានអាវុធ ឬ

៣. ប្រព្រឹត្តដោយជាស្វាមី ភរិយា ឬសង្សារ ឬឪពុកម្តាយ ឬអាណាព្យាបាលដែលបង្ខំបុរស ឬស្ត្រីឱ្យធ្វើពេស្យាចារ ឬ

៤. ជាការដាក់បង្ខំឱ្យជនរងគ្រោះធ្វើពេស្យាចារនៅក្រៅប្រទេស ឬបង្ខំជនរងគ្រោះដែលជាបរទេសឱ្យធ្វើពេស្យាចារនៅលើទឹកដីកម្ពុជា។

**មាត្រា ៦:** អ្នកសមគំនិត ឬអ្នកប៉ុនប៉ងប្រព្រឹត្តបទល្មើសដូចមានចែងក្នុងមាត្រា ៤ និង ៥ ត្រូវទទួលទោសដូចអ្នកប្រព្រឹត្តដែរ។

## ជំពូកទី៤
## អំពើអនាចារ

**មាត្រា ៧:** ជនណាដែលបើកកន្លែងសម្រាប់ប្រព្រឹត្តអំពើអនាចារ ឬអំពើអាសអាភាសផ្សេងៗ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ឆ្នាំ ដល់ ៥ឆ្នាំ និងពិន័យជាប្រាក់ពី ៥ ០០០ ០០០៛ "ប្រាំលានរៀល" ដល់ ៣០០០០ ០០០៛ "សាមសិបលានរៀល"។ ក្នុងករណីមិនរាងចាលត្រូវផ្តន្ទាទោសទ្វេជាពីរ។

**មាត្រា ៨:** ជនណាដែលបានប្រព្រឹត្តអំពើអនាចារ លើអនីតិជនអាយុក្រោម ១៥ឆ្នាំ ទោះបីអនីតិជននោះស្ម័គ្រចិត្តក្តី ឬដោយទិញក្មេងនោះពីអ្នកដទៃក្តី ឬទិញពីជនជាមេពេស្យាក្តី ជននោះត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១០ឆ្នាំ ដល់ ២០ឆ្នាំ។ ក្នុងករណីមិនរាងចាល ត្រូវយកអតិបរមានៃទោសមកអនុវត្ត។




ដកស្រង់ពីគេហទំព័រ: http://www.protectionproject.org

# មេរៀនទី ១០: ការវាយតម្លៃចំណេះដឹង

🕑 រយៈពេលបង្រៀនៈ ១ម៉ោង ៣០នាទី

☑ ការត្រៀមលក្ខណៈ

មុនពេលបង្រៀនលោកគ្រូ អ្នកគ្រូត្រូវ

- អាន និងពិនិត្យមេរៀនដោយហ្មត់ចត់ និងធ្វើកិច្ចតែងការបង្រៀន
- ពិនិត្យមើលឯកសារសិស្ស ដើម្បីចង់ដឹងថាតើមានព័ត៌មាន និងសំណួរ សម្រាប់សកម្មភាពត្រូវនឹងការបង្រៀនដែរឬទេ
- សរសេរសំណួរលើក្តារខៀន ឬនៅលើក្រដាសផ្ទាំងធំ
- មើលកាលវិភាគប្រចាំថ្ងៃ
- រៀបចំបន្ទប់រៀន (តុ កៅអី ក្តារខៀន...)។

📖 សម្ភារឧបទេស ធនធានដែលត្រូវការ

- វង្វាយតម្លៃ "ការទប់ស្កាត់ការជួញដូរមនុស្ស" សម្រាប់សិស្សនីមួយៗ
- ឯកសារ ១០.១ សម្រាប់សិស្ស

☼ វត្ថុបំណង

នៅពេលរៀនមេរៀននេះចប់ សិស្សនឹងអាច ៖

- ចែករំលែកចំណេះដឹងពីម៉ូឌុលនេះជាមួយសិស្សដទៃ ឬបងប្អូន
- បង្ហាញថាពួកគេមានជំនាញ និងចំណេះដឹងគ្រប់គ្រាន់អំពីប្រធានបទផ្អែកលើលក្ខណៈវិនិច្ឆ័យដែលបានផ្តល់ឱ្យក្នុងវង្វាយតម្លៃ។

🕑 ៥០ នាទី

## សេចក្តីផ្តើម

ស្វាគមន៍សិស្សទាំងអស់ ដែលបានមករៀន នូវមេរៀនចុងក្រោយនេះ។ ខ្ញុំបានអានកាសែត កាលពីពេលកន្លងទៅឃើញថា ការជួញដូរមនុស្សគឺជាបញ្ហាមួយ ដែលកំពុងតែកើនឡើងក្នុងប្រទេសកម្ពុជា។ ជាការសំខាន់ណាស់ ដែលប្រជាជននៅតាមជនបទ ត្រូវសិក្សាអំពីការទប់ស្កាត់ការជួញដូរមនុស្សនៅទីក្រុង ពីរបៀបដែលពួកគេអាចរស់នៅ និងធ្វើការដោយសុវត្ថិភាព។
ថ្ងៃនេះ សិស្សទាំងឡាយនឹងបង្ហាញអ្វីដែលពួកគេបានរៀននិងបានធ្វើ។ ពួកគេនឹងពន្យល់អំពីអ្វី ដែលមានសារៈសំខាន់ និងគួរត្រូវដឹង។

- ទីកន្លែងដែលគ្រួសាររបស់ខ្ញុំធ្វើបំលាស់ទីទៅកាន់កន្លែងផ្សេង
- គ្រោះថ្នាក់ និងគុណប្រយោជន៍នៃការធ្វើបំលាស់ទីទៅកាន់កន្លែងផ្សេង
- ករណីសិក្សា - អំពីរឿងជីវិតពិត
- ភ្នំពេញ - ពន្យល់អំពីទីក្រុង និងអគាររបស់វា
- ការធ្វើយុទ្ធនាការ - លទ្ធផលនៃដំណើរទៅកាន់ភូមិរបស់យើង
- ការជួញដូរមនុស្ស - កត្តាជំរុញនិងកត្តាអូសទាញផ្សេងៗ និងយុទ្ធសាស្ត្រ

- ច្បាប់
- ទីក្រុង

ក្នុងរយៈពេល៤៥នាទីខាងមុខនេះ សិស្សចាប់ដៃគូរដើម្បីពិភាក្សា អំពីអ្វីដែលពួកគេបានរៀន និងបានធ្វើ។ ប្រសិនបើអ្នកមានសំណួរ សូមមករកខ្ញុំខណៈពេលដែលអ្នកនៅទីនេះ។

ក្នុងចន្លោះពេលនោះ អ្នកអាចបំពេញ "ក្រដាសវាយតម្លៃសិស្ស"។ ប្រសិនបើសិស្សមិនច្បាស់ពីអ្វីដែលត្រូវនិយាយ អ្នកអាចជួយពួកគេដោយឱ្យនរណាម្នាក់មកជំនួស។

## សកម្មភាពសំខាន់។

៣០ នាទី

បន្ទាប់ពីបទបង្ហាញនេះ យើងនឹងធ្វើការវាយតម្លៃតូចមួយ ។ អ្នកគ្រប់គ្នានឹងទទួលបានក្រដាសមួយដែលមានសំណួរអំពីម៉ូឌុលនេះ។ ចូរធ្វើឱ្យអស់ពីសមត្ថភាព ដើម្បីបំពេញវាឱ្យបានល្អ និងច្រើនបំផុតតាមតែអ្នកអាច។ បន្ទាប់ពីបញ្ចប់ អ្នកអាចប្រគល់ក្រដាសនេះមកឱ្យខ្ញុំវិញ។

ចែកក្រដាសវាយតម្លៃទៅឱ្យសិស្ស និងទុកពេល ៣០នាទីឱ្យពួកគេធ្វើកិច្ចការនេះដោយរៀងៗខ្លួន។

## បញ្ចប់មេរៀន

១០ នាទី

ប្រសិនបើសិស្សបានបញ្ចប់កិច្ចការវាយតម្លៃ អ្នកអាចឱ្យពួកគេកែកិច្ចការរបស់ពួកគេ ដោយខ្លួនពួកគេផ្ទាល់។ នេះមានន័យថា ពួកគេនឹងទទួលបានការផ្តល់មតិយោបល់ភ្លាមៗ។ ជាការពិតណាស់ អ្នកត្រូវការត្រួតពិនិត្យដោយខ្លួនរបស់អ្នកផងដែរ ប៉ុន្តែជាមួយការអនុញ្ញាតឱ្យសិស្សជួយក្នុងកិច្ចការនេះ អ្នកអាចសន្សំពេលវេលា ហើយសិស្សនឹងអាចពិនិត្យមើលចំណេះដឹងរបស់ពួកគេផងដែរ។

ប្រធានបទផ្សេងៗទៀតដែលអ្នកអាចវាយតម្លៃជាមួយសិស្សមានៈ

តើរបស់សំខាន់អ្វីដែលអ្នកបានរៀនពីក្នុងម៉ូឌុលនេះ ?

ប្រសិនបើនរណាម្នាក់សួរអ្នកអំពីការទប់ស្កាត់ការជួញដូរមនុស្ស តើអ្នកអាចធ្វើការពន្យល់ពីបញ្ហានេះបានដែរឬទេ ?

តើអ្នកមានដំបូន្មានអ្វីសម្រាប់យើងដើម្បីធ្វើការកែលម្អវគ្គបំណិនជីវិតនេះ នៅលើកក្រោយៗ ទៀតដែរឬទេ ?

អរគុណអ្នកទាំងអស់គ្នា សម្រាប់ការចូលរួមក្នុងវគ្គបំណិនជីវិតនេះ។ អ្នកបានធ្វើកិច្ចការជាច្រើន ហើយខ្ញុំប្រាកដណាស់ថា អ្នកក៏បានរៀនបញ្ហាជាច្រើនផងដែរ។ ចូរកុំភ្លេចថា អ្នកអាចត្រឡប់មករកខ្ញុំ ប្រសិនបើអ្នកចង់ដឹងពីលេខទូរស័ព្ទសំខាន់ៗ ឬអ្នកចង់ពិនិត្យអ្វីមួយ ដោយបងប្អូនណាម្នាក់របស់អ្នកចង់ធ្វើចំណាកស្រុក!

# សំណួរវាយតម្លៃ ការទប់ស្កាត់ការជួញដូរមនុស្ស

1.តើអ្នកអាចរៀបរាប់ពីមូលហេតុ ៣យ៉ាងដែលមនុស្សធ្វើបំលាស់ទីទៅកាន់កន្លែងផ្សេងបានដែរឬទេ?

______________________________

______________________________

______________________________

2. គ្រោះថ្នាក់ ឬ អត់?

| | គ្រោះថ្នាក់ | សុវត្ថិភាព |
|---|---|---|
| ភាពគ្មានការងារធ្វើនៅក្នុងភូមិ។ គាត់បានឮពីមិត្តភក្តិរបស់គាត់ថា នៅសៀមរាបមានការងារជាច្រើន។ គាត់សម្រេចចិត្តយកប្រាក់សន្សំ និងលាប្រពន្ធរបស់គាត់ទៅសៀមរាបហើយសន្យាថាគាត់នឹងផ្ញើប្រាក់មកឱ្យពេលគាត់រកបានការងារធ្វើ។ | | |
| រ៉ាវិនមិនចង់ឱ្យលិខិតឆ្លងដែនទៅមេកើយ ប៉ុន្តែគាត់និយាយថាគាត់អាចឱ្យច្បាប់ថតចម្លងទៅគាត់។ | | |
| នៅឯចំណតរថយន្តក្រុង បុរសដែលមានរូបរាងស្រស់ស្អាតម្នាក់ស្នើសុំនាំអ្នកទៅផ្ទះដ៏ល្អមួយ។ | | |
| ស្រីយ៉ា សន្យាថានឹងទិញទូរស័ព្ទមួយគ្រឿងនៅក្នុងទីក្រុង និងទូរស័ព្ទទៅម្តាយរបស់នាង។ នាងមិនទាន់ច្បាស់ពីផ្ទះរបស់នាងនៅឡើយ ប៉ុន្តែនាងជាមនុស្សស្រីដ៏រឹងមាំម្នាក់។ | | |

3. តើអ្នកដឹងថានេះជាអ្វីដែរឬទេ?







______________ ______________ ______________

______________ ______________ ______________

4. ចូររៀបរាប់ពីភាពខុសប្លែកគ្នារវាងការរស់នៅក្នុងទីក្រុង និងការរស់នៅក្នុងភូមិ។

______________________________

______________________________

______________________________

______________________________

______________________________




5. តើអ្វីជាភាពខុសប្លែកគ្នារវាងការធ្វើបំលាស់ទីទៅកាន់កន្លែងផ្សេង និងការជួញដូរមនុស្ស?

______________________________

______________________________

______________________________

6. នៅក្នុងស្ថានភាពជួញដូរមួយអ្នកអាចកំណត់ពី *"កត្តាជំរុញនិងកត្តាអូសទាញ"* *"តួអង្គសំខាន់ៗ"* *"យុទ្ធសាស្ត្រ និងល្បិចកល"* និង *"របៀបក្នុងការកេងប្រវ័ញ្ច"*។ តើអ្នកអាចរៀបរាប់យ៉ាងតិចណាស់ ២ ចំណុចសម្រាប់ផ្នែកនីមួយៗបានទេ? ឧ: "តើតួអង្គសំខាន់ៗណាខ្លះដែលអាចចូលរួមក្នុងការជួញដូរ?"

- កត្តាជំរុញនិងកត្តាអូសទាញសម្រាប់ការជួញដូរមនុស្ស ______________________________
- តួអង្គសំខាន់ៗ ______________________________
- យុទ្ធសាស្ត្រ និងល្បិចកល ______________________________
- របៀបក្នុងការកេងប្រវ័ញ្ច ______________________________

7. យើងបានសិក្សាអំពីច្បាប់ប្រឆាំងការជួញដូរនៅកម្ពុជា។ តើអ្នកអាចសរសេរកត្តាសំខាន់៣យ៉ាង ដែលអ្នកអាចចាំបានដែរឬទេ?

1.

2.

3.

ពិន្ទុសរុប:

និទេស:

# ចម្លើយរង្វាយតម្លៃការទប់ស្កាត់ការជួញដូរមនុស្ស-ចម្លើយ

**ក្រដាសចម្លើយ**

**១. តើអ្នកអាចរៀបរាប់ពីមូលហេតុ ៣យ៉ាងដែលមនុស្សធ្វើបំលាស់ទីទៅកាន់ទីកន្លែងផ្សេងបានដែរឬទេ?**

*ចម្លើយអាចមាន: ឱកាសការងារ ប្រាក់ចំណូលកាន់តែខ្ពស់ គុណភាពសិក្សាកាន់តែល្អ ផ្សេងព្រេង/បានឃើញទីក្រុង ឱកាសរៀនជំនាញថ្មីៗ ឱកាសក្នុងការជួបមនុស្សថ្មី ឱកាសរកស៊ីកាន់តែល្អ ដើម្បីរស់នៅកន្លែងមានសុវត្ថិភាព ដើម្បីចាប់ផ្តើមជាថ្មី ដើម្បីគាំទ្រគ្រួសារ...។ល។*

**២. គ្រោះថ្នាក់ ឬ អត់?**

| | គ្រោះថ្នាក់ | សុវត្ថិភាព |
|---|---|---|
| ភាពគ្មានការងារធ្វើទេនៅក្នុងភូមិ។ គាត់បានឮពីមិត្តភក្តិរបស់គាត់ថា នៅសៀមរាបមានការងារជាច្រើន។ គាត់សម្រេចចិត្តយកប្រាក់សន្សំ និងលាប្រពន្ធរបស់គាត់ទៅសៀមរាប ហើយសន្យាថាគាត់នឹងផ្ញើប្រាក់មកឱ្យពេលគាត់រកបានការងារធ្វើ។ | X | |
| រ៉ាំនិមិនចង់ឱ្យលិខិតឆ្លងដែនទៅមេកើយប៉ុន្តែគាត់និយាយថាគាត់អាចឱ្យច្បាប់ចតចម្លងទៅគាត់។ | | X |
| នៅឯចំណតឡានក្រុង បុរសដែលមានរូបរាងស្រស់ស្អាតម្នាក់ស្នើសុំនាំអ្នកទៅផ្ទះដ៏ល្អមួយ។ | X | |
| ស្រីយ៉ា សន្យាថានឹងទិញទូរស័ព្ទមួយគ្រឿងនៅក្នុងទីក្រុង និងទូរស័ព្ទទៅម្តាយរបស់នាង។ នាងមិនទាន់ច្បាស់ពីផ្ទះរបស់នាងនៅឡើយ ប៉ុន្តែនាងជាមនុស្សស្រីដ៏រឹងមាំម្នាក់។ | X | |

ត្រឹមត្រូវទាំងអស់ = ២ពិន្ទុ
ត្រឹមត្រូវ ២-៣ = ១ពិន្ទុ

**៣. តើអ្នកដឹងថានេះជាអ្វីដែរឬទេ?**


អគារមាស៤២ជាន់


ផ្សារថ្មី


ស្ថានីយរថភ្លើង

ត្រឹមត្រូវ ៣ = ២ពិន្ទុ
ត្រឹមត្រូវ ១-២ = ១ពិន្ទុ

**៤. ចូររៀបរាប់ពីភាពខុសប្លែកគ្នារវាងការរស់នៅក្នុងទីក្រុង និងការរស់នៅក្នុងភូមិ**

*ចម្លើយអាចមាន:*

- *ទីក្រុងធំជាង*
- *ទីក្រុងមានឡាន មនុស្ស និងអគារច្រើនជាង*
- *មនុស្សមិនសូវស្គាល់គ្នាទៅក្នុងទីក្រុង*
- *មានជម្រើសជាច្រើនសម្រាប់ការសប្បាយ ឬកំសាន្តក្នុងទីក្រុង*
  ** ភាពខុសប្លែកគ្នាក្នុងការស្លៀកពាក់*
- *ទីក្រុមានគ្រោះថ្នាក់ និង បទឧក្រិដ្ឋច្រើនជាង*

** មានការងារច្រើនប្រភេទខុសៗគ្នា*
** អគារខ្ពស់ៗក្នុងទីក្រុង*
** ភាពខុសប្លែកគ្នាក្នុងការនិយាយស្តី*

ត្រឹមត្រូវ ៥ = ២ពិន្ទុ
ត្រឹមត្រូវ ៤ = ១ពិន្ទុ

# សេចក្តីណែនាំគ្រូ

ក្រោយពេលសិស្សបញ្ចប់ការវាយតម្លៃ អ្នកអាចឱ្យពួកគេយកសម្ភារៈដែលពួកគេបានធ្វើទៅផ្ទះរបស់ពួកគេ។ នេះអាចជះឥទ្ធិពលដល់ចំណេះដឹង និងជំនាញរបស់សមាជិក គ្រួសារដទៃទៀតនៅក្នុងផ្ទះផងដែរ។

**៥. តើអ្វីជាភាពខុសប្លែកគ្នារវាងការធ្វើបំលាស់ទីទៅកាន់ទីកន្លែងផ្សេង និងការជួញដូរមនុស្ស?**

*ចម្លើយអាចមាន:*

| | |
|---|---|
| ចំណាកស្រុក | ការជួញដូរមនុស្ស |
| ការសម្រេចចិត្តធ្វើឡើយដោយសេរី | គ្មានជម្រើ - ប្រើប្រាស់ការបង្ខិតបង្ខំ ប្រើកម្លាំង ឬការកៀបសង្កត់ |
| | ធ្លាក់ក្នុងស្ថានភាពកេងប្រវ័ញ្ចដែលឈ្មួញជួញដូរមនុស្សអាចទទួលប្រយោជន៍ |
| | អាចជាការកេងប្រវ័ញ្ចកម្លាំងពលកម្ម និងជាញឹកញាប់គឺកេងប្រវ័ញ្ចផ្លូវភេទ |

ភាពខុសប្លែកគ្នាដែលសំខាន់បំផុតគឺថាចំណាកស្រុកគឺជាជម្រើសដោយសេរី រីឯការជួញដូរមនុស្សគឺជាការបង្ខំ។ ប្រសិនបើសិស្សឆ្លើយអ្វីទាំងអស់នេះ = ២ពិន្ទុ

ប្រសិនបើសិស្សគ្រាន់តែរៀបរាប់ពីការធ្លាក់ទៅក្នុងស្ថានភាពរំលោភបំពាន = ១ពិន្ទុ

**៦. នៅក្នុងស្ថានភាពជួញដូរមួយអ្នកអាចកំណត់ពី *"កត្តាជំរុញ និងកត្តាអូសទាញ" "តួអង្គសំខាន់ៗ" "យុទ្ធសាស្ត្រ និងល្បិចកល" និង "របៀបក្នុងការកេងប្រវ័ញ្ច"*។ តើអ្នកអាចរៀបរាប់យ៉ាងតិចណាស់ ២ ចំណុចសម្រាប់ផ្នែកនីមួយៗបានទេ? ឧ: "តើតួអង្គសំខាន់ៗណាខ្លះដែលអាចចូលរួមក្នុងការជួញដូរ?"**

*ចម្លើយ: សម្រាប់ចម្លើយជាទូទៅដែលអាចអាចមាន សូមមើលសេចក្តីណែនាំគ្រូក្នុងមេរៀនទី ៧*

២ចំណុចត្រឹមត្រូវក្នុងផ្នែកនីមួយៗ = ៣ពិន្ទុ

២ចំណុចត្រឹមត្រូវតែក្នុង ៣ផ្នែក = ២ពិន្ទុ

២ចំណុចត្រឹមត្រូវតែក្នុង ២ផ្នែក = ១ពិន្ទុ

**៧. យើងបានសិក្សាអំពីច្បាប់ប្រឆាំងការជួញដូរនៅកម្ពុជា។ តើអ្នកអាចសរសេររបស់សំខាន់៣យ៉ាងដែលអ្នកអាចចាំបានដែរឬទេ?**

*ចម្លើយ: សម្រាប់ចម្លើយជារួមដែលអាចអាចមានសម្រាប់ច្បាប់នេះ សូមមើលឯកសារសម្រាប់សិស្ស ៨.១*

ត្រឹមត្រូវ ៣ = ២ពិន្ទុ

ត្រឹមត្រូវ ២ = ១ពិន្ទុ

## កម្រិតនៃការផ្តល់ពិន្ទុ-ពិន្ទុនៅក្នុងការធ្វើតេស្តនេះ គឺទាក់ទងទៅនឹងពិន្ទុទូទៅ

| %ឆ្លើយបានត្រឹមត្រូវ | ពិន្ទុ | និទ្ទេស |
|---|---|---|
| ៦៦%ទៅ១០០%ល្អ | ច្រើនជាង៩ពិន្ទុ | ល្អ |
| ៥១%ទៅ៦៥%ល្អ | ៨ទៅ៩ពិន្ទុ | បង្គួរ |
| ក្រោម៥០%ល្អ | តិចជាង៨ពិន្ទុ | ខ្សោយ |

## ឧបសម្ព័ន្ធ ១.១ : គំរូប័ណ្ណវាយតម្លៃ (សម្រាប់គ្រូ)

# ប័ណ្ណវាយតម្លៃការសិក្សារបស់សិស្សម្នាក់ៗ

ឈ្មោះសិស្ស ........................ សាលា..................... . ខេត្ត.............. ស្រុក................ ថ្នាក់ទី ........ ប្រធានបទ................

| ចំណុចត្រូវដាក់ពិន្ទុ | | ពិន្ទុ (១-១៥) | និទ្ទេស |
|---|---|---|---|
| **កិច្ចការទី ១: តេស្តចំណេះដឹង (សំណួរសរសេរ)** | | | |
| សំណួរសរសេរមានពិន្ទុសរុប ១៥ ពិន្ទុ បើពិន្ទុ 0 ដល់ ៧=ខ្សោយ/ បើ ៨ ដល់ ១០=មធ្យម / បើ ១១ ដល់ ១៥=ល្អ) | | | |
| **សង្កេតឥរិយាបថសិស្ស** | | ពិន្ទុ (១-៥) | និទ្ទេស |
| ១ | **ការប្រាស្រ័យទាក់ទង និងការសហការ :** សកម្មភាពពិភាក្សាជាមួយសមាជិកទាំងអស់ក្នុងក្រុម និងធ្វើការបានប្រសើរ ជាមួយក្រុម ។ សិស្សស្តាប់គ្នាទៅវិញទៅមក និងផ្តល់យោបល់គ្នាទៅវិញទៅមក ។ | | |
| ២ | **ការវិភាគល្អិតល្អន់ និងការដោះស្រាយបញ្ហា :** ផ្តល់ចម្លើយដោយមានហេតុផល និងអំណះអំណាងច្បាស់លាស់ និងអាចកំណត់ដំណោះស្រាយចំពោះបញ្ហាងាយៗដែលជួបប្រទះ ។ | | |
| ៣ | **ការធ្វើសេចក្តីសម្រេចចិត្តដោយខ្លួនឯង :** មិនមានការបារម្ភច្រើន ក្នុងការធ្វើសេចក្តីសំរេចចិត្ត និងដឹងច្បាស់ថាខ្លួនគេកំពុងនិយាយឬធ្វើអ្វីមួយ ។ | | |
| ៤ | **ទំនុកចិត្តលើខ្លួនឯង :** កំឡុងពេលធ្វើបទបង្ហាញនិងពិភាក្សាក្រុម សិស្សមានទំនុកចិត្តក្នុងការនិយាយ និងចូលរួមក្នុងក្រុម | | |
| ៥ | **ការលើកទឹកចិត្ត និងការយល់ចិត្ត:** សិស្សចង់បន្តរៀនសូត្របន្ថែមពីប្រធានបទនេះ ហើយយល់ច្បាស់ខ្លឹមសារក្នុង ប្រធានបទ និងការអនុវត្តផ្ទាល់ ។ | | |
| ៦ | **ចរិត : សិស្ស**មានចិត្តអំណត់និងអារម្មណ៍ល្អនៅក្នុងការសិក្សា ។ | | |
| ៧ | **ការបង្កើតថ្មី :** សិស្សបង្ហាញនូវភាពច្នៃប្រឌិតក្នុងការរៀបចំការធ្វើបទបង្ហាញផលិតផល នៅកំឡុងពេលសិក្សា ដោយបង្ហាញចេញនូវគំនិតជាច្រើន ។ | | |
| | **សរុបសង្កេតឥរិយាបថសិស្ស** | | |
| សង្កេតឥរិយាបថសិស្សមានពិន្ទុសរុប ៣៥ ពិន្ទុ ( បើពិន្ទុ 0 ដល់ ១៧ =ខ្សោយ/ បើ ១៨ ដល់ ២៣=មធ្យម / បើ ២៤ ដល់ ៣៥=ល្អ) | | | |
| ពិន្ទុសរុបសំណួរសរសេរ និងសង្កេតឥរិយាបថសិស្ស ( បើពិន្ទុ 0 ដល់ ២៤=ខ្សោយ/ បើ ២៥ ដល់ ៣៣=មធ្យម / បើ ៣៤ ដល់ ៥0=ល្អ) | | | |

ថ្ងៃទី .......... ខែ ........... ឆ្នាំ ..........

ហត្ថលេខា និងឈ្មោះគ្រូ

## ឧបសម្ព័ន្ធ ១.២ : តារាងបូកសរុបវាយតម្លៃការសិក្សារបស់សិស្សប្រចាំថ្នាក់

ខេត្ត ........................ ស្រុក ........................សាលា .............................. ថ្នាក់ទី .......... ប្រធានបទ ....................

| ល.រ | ឈ្មោះសិស្ស | សំណួរសរសេរ | | ឥរិយាបថ | | សរុប | |
|---|---|---|---|---|---|---|---|
| | | ពិន្ទុ | និទ្ទេស | ពិន្ទុ | និទ្ទេស | ពិន្ទុ | និទ្ទេស |
| ១ | | | | | | | |
| ២ | | | | | | | |
| ៣ | | | | | | | |
| ៤ | | | | | | | |
| ៥ | | | | | | | |
| ៦ | | | | | | | |
| ៧ | | | | | | | |
| ៨ | | | | | | | |
| ៩ | | | | | | | |
| ១០ | | | | | | | |
| ១១ | | | | | | | |
| ១២ | | | | | | | |
| ១៣ | | | | | | | |
| ១៤ | | | | | | | |
| ១៥ | | | | | | | |
| ១៦ | | | | | | | |
| ១៧ | | | | | | | |
| ១៨ | | | | | | | |
| ១៩ | | | | | | | |
| ២០ | | | | | | | |
| ២១ | | | | | | | |
| ២២ | | | | | | | |
| ២៣ | | | | | | | |
| ២៤ | | | | | | | |
| ២៥ | | | | | | | |
| ២៦ | | | | | | | |

បានឃើញ និងឯកភាព ថ្ងៃទី .......... ខែ ............ ឆ្នាំ ..........

នាយកសាលា ហត្ថលេខា និងឈ្មោះគ្រូបង្រៀន

| **ការអង្កេតថ្នាក់រៀន** | | | | | **ការវាយតម្លៃគ្រូបំណិនជីវិត** |
|---|---|---|---|---|---|
| សាលារៀន | | | | គ្រូ | អ្នកសង្កេត |
| | | | | | |
| កាលបរិច្ឆេទ | ការចាប់ផ្តើមមេរៀន | ការបញ្ចប់មេរៀន | ថ្នាក់ | ចំនួនសិស្សដែលបានចុះឈ្មោះ/មានវត្តមាន | ប្រធានបទបំណិនជីវិត: |
| | | | | | |
| តើមេរៀនបង្ហាញពីអ្វី? | | | | | |
| | | | | | |

| លក្ខណៈវិនិច្ឆ័យ – ការរៀបចំ – តើបន្ទប់រៀន.. | ពិន្ទុ | កំណត់សម្គាល់យោងតាមភស្តុតាង |
|---|---|---|
| មានសណ្តាប់ធ្នាប់ ហើយ ត្រៀមសម្ភារៈរួចជាស្រេចសម្រាប់ប្រើប្រាស់ក្នុងមេរៀននេះ? | 1-2-3-4-5 | |
| បង្ហាញសិស្សនូវសម្ភារៈដែលបានធ្វើកាលពីមេរៀនមុន | 1-2-3-4-5 | |
| **លក្ខណៈវិនិច្ឆ័យ - ការសិក្សា - តើសិស្ស...** | **ពិន្ទុ** | **កំណត់សម្គាល់យោងតាមភស្តុតាង** |
| មានចំណាប់អារម្មណ៍ និងចូលរួមក្នុងការងាររបស់ពួកគេដែរឬទេ? | 1-2-3-4-5 | |
| ធ្វើការក្នុងក្រុមខុសៗគ្នាក្នុងកំឡុងពេលបង្រៀនដោយមានតួនាទីក្រុមច្បាស់លាស់ | 1-2-3-4-5 | |
| រីករាយជាមួយមេរៀនដែលគ្រូបង្រៀន | 1-2-3-4-5 | |
| បង្ហាញចំណេះដឹង ឬបំណិនពីមេរៀនមុន | 1-2-3-4-5 | |
| **លក្ខណៈវិនិច្ឆ័យ – ការបង្រៀន – តើគ្រូ..** | **ពិន្ទុ** | **កំណត់សម្គាល់យោងតាមភស្តុតាង** |
| អនុវត្តតាមកិច្ចតែងការបង្រៀនដែលមានឬទេ? | 1-2-3-4-5 | *សូមបញ្ជាក់ធាតុណាមួយដែលត្រូវបានប្រើ* |
| ប្រើប្រាស់ធនធានសហគមន៍ក្នុងការបង្រៀនមេរៀននេះ ឬប្រើប្រាស់សហគមន៍ទាំងស្រុង? | 1-2-3-4-5 | |

| | | |
|---|---|---|
| ប្រើប្រាស់វិធីសាស្ត្របង្រៀនបែបអន្តរកម្ម/សកម្ម ឧ.ផែនទីគំនិត, ករណីសិក្សា, ការសម្តែងតួ, ល្បែងកំសាន្ត... | 1-2-3-4-5 | |
| ប្រើប្រាស់ប្រភេទសំណួរផ្សេងៗ | 1-2-3-4-5 | |
| ប្រើប្រាស់ធនធានបង្កើតឡើងដោយខ្លួនឯង ឬឯកសារបន្ថែមដើម្បីពន្យល់មេរៀន | 1-2-3-4-5 | |
| ចាប់ផ្តើមតាមពេលកំណត់ និងប្រើប្រាស់ពេលវេលាយ៉ាងមានប្រសិទ្ធភាព | 1-2-3-4-5 | |
| ផ្តល់មតិយោបល់វិជ្ជមានដើម្បីជំរុញការសិក្សា និងបង្កើនទំនុកចិត្តដល់សិស្ស | 1-2-3-4-5 | |
| ជួយសិស្សជាលក្ខណៈបុគ្គលចំពោះសិស្សណាដែលមានការលំបាក | 1-2-3-4-5 | |
| កត់ត្រាការវិវត្តនៃអត្តចរិតសិស្សក្នុងតារាងវាយតម្លៃការសិក្សារបស់សិស្ស? | 1-2-3-4-5 | |

បន្ទាប់ពីផ្នែកនេះ ចូរប្រើប្រាស់កំណត់ត្រារបស់អ្នកដើម្បីពិភាក្សាជាមួយគ្រូ។ **សុំឱ្យគ្រូកំណត់ចំណុចល្អរបស់មេរៀន** ហើយស្នើសុំការផ្លាស់ប្តូរ ឬការកែលម្អ។ ធ្វើការជាមួយគ្រូដើម្បីកំណត់ភាពខ្លាំង។ ធ្វើការផ្តល់គំនិតចំពោះការកែលម្អ។ ការសង្កេតត្រូវបានបញ្ចប់ ដោយធ្វើការសម្ភាសន៍។

| ចំណុចខ្លាំង | គំនិតសម្រាប់កែលម្អ |
|---|---|
| | |

ហត្ថលេខា និងឈ្មោះរបស់អ្នកវាយតម្លៃ .......................

ហត្ថលេខា និងឈ្មោះរបស់គ្រូ .....................................

# ការធ្វើបំលាស់ទីទៅកន្លែងផ្សេង ដោយសុវត្ថិភាព



ពិភាក្សាជាមួយនឹងប្រធានភូមិ និងអ្នកដែលមានបទពិសោធន៍ក្នុងការចំណាកស្រុក មុនពេលធ្វើដំណើរ

យកអត្តសញ្ញាណប័ណ្ណទៅជាមួយ ហើយទុកវានៅជាប់ខ្លួន អ្នកជានិច្ច






ចុះហត្ថលេខាលើកិច្ចសន្យា ប្រសិនបើអ្នកយល់នូវអ្វីដែលបានពណ៌នា។ តើអ្នកមានស្គាល់នរណាម្នាក់ដែលអាចជួយអ្នកបានដែរឬទេ?



ស្គាល់លេខទូរស័ព្ទប៉ូលិស
០២៣ ៩៩៧ ៩១៩



ស្គាល់ពីសិទ្ធិរបស់អ្នក ហើយអនុវត្តវានៅពេលមាននរណាម្នាក់ធ្វើអ្វីមួយ មិនល្អមកលើអ្នក



រៀបចំពេលវេលាសម្រាប់លេងកំសាន្តជាមួយអ្នកដទៃ។ ការធ្វើបែបនេះនឹងជួយឲ្យអ្នកមានអារម្មណ៍ល្អ។



តែងតែប្រាប់ញាតិមិត្តរបស់អ្នកពីគម្រោងដែលអ្នកនឹងត្រលប់មកវិញ និងប្រាប់ពួកគេពីទីកន្លែងដែលអ្នករស់នៅ

# ការធ្វើបំលាស់ទីទៅកន្លែងផ្សេង មិនមានសុវត្ថិភាព

ចាប់ផ្តើមធ្វើការងារដោយមិនបានដឹងពីគ្រោះថ្នាក់របស់វា។ ចូរពិភាក្សាជាមួយនឹងអ្នកធ្វើការជាមួយអ្នកអំពីប្រាក់ឈ្នួល និងល័ក្ខខ័ណ្ឌការងារ



អត់ស្គាល់ "មេខ្យល់" ប៉ុន្តែគាត់សន្យាថានឹងឲ្យលុយ ជាច្រើន



ចាកចេញពីភូមិរបស់អ្នកនៅពេលដែលអ្នកនៅក្មេងពេក ព្រមទាំងមិនមានការអប់រំបានត្រឹមត្រូវ





អ្នកមិនដែលបានរៀនពីច្បាប់ចរាចរណ៍នៅក្នុងទីក្រុង។ ឥឡូវអ្នកត្រូវទៅមន្ទីរពេទ្យ តែអ្នកមិនដឹងថាវានៅឯណាទេ។



ខ្ចីលុយពីមនុស្សដែលអ្នកមិនស្គាល់។



ការជួញដូរនិងការធ្វើអាជីវកម្មផ្លូវភេទ គឺជាគ្រោះថ្នាក់ដ៏ចម្បងចំពោះក្មេងស្រី និងក្មេងប្រុស។

ក្រសួងកិច្ចការនារី

កិច្ចសហប្រតិបត្តិការ
អាល្លឺម៉ង់
DEUTSCHE ZUSAMMENARBEIT

Implemented by giz Deutsche Gesellschaft für Internationale Zusammenarbeit (GIZ) GmbH

MINISTERIO
DE ASUNTOS EXTERIORES
Y DE COOPERACIÓN

aecid